សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de Droit et des Science Economique

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# សន្តិកម្ម

ស្រាវជ្រាវពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២១ ដល់ថ្ងៃទី  ១៣ ខែសីហា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **១. អ៊ី តារាវិមាន**

**២. ម៉ៃ ស្រីពេជ**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ប៊ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des Science Economique**

**Royal University of Law and Economic**


## សារណាបញ្ចប់ការសិក្សា

# សន្តិកម្ម

ស្រាវជ្រាវពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២១ ដល់ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **១. អ៊ី តារាវិមាន**

**២. ម៉ៃ ស្រីពេជ**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ម៉ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទ ឈ្មោះ **អ៊ី តារាវិមាន** និង នាងខ្ញុំឈ្មោះ **ម៉ៃ ស្រីពេជ** ដែលជាសិស្សនិស្សិតបរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា ២០១៧-២០២១ ។

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖**

**លោកឪពុក និង អ្នកម្តាយ** របស់យើងខ្ញុំដែលធ្វើការ ចំណាយសព្វគ្រប់បែបយ៉ាង ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ ទំនុកបម្រុងដល់រូបកូនគ្រប់បែបយ៉ាង ទាំងស្មារតី និងសម្ភារៈ ព្រមទាំងបានខិតខំប្រឹងប្រែងដើម្បីកូនបានសិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ មិនត្រឹមតែប៉ុណ្ណោះ លោកទាំងពីបានគង់នៅជាម្លប់ដ៏ត្រជាក់ដល់កូនចៅដើម្បីឆ្ពោះទៅរកភាពជោគជ័យ និង ក្តីស្រមៃទៅថ្ងៃអនាគត ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំពង្រីកនូវចំណេះដឹង និងបង្កើតនូវជំនាញតាមរយៈការចងក្រង តាក់តែងកិច្ចការស្រាវជ្រាវសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះឡើង។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ **ថ្នាក់ដឹកនាំនៃសកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំគិតគូរដល់សិស្សានុសិស្ស ទាំងឡាយ នូវចំណេះដឹង អនាម័យ ផាសុខភាព និងសុវត្ថិភាពដល់សិស្សានុសិស្សទាំងឡាយ ។

ជាពិសេសជាងនេះទៅទៀត យើងខ្ញុំទាំងពីនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **លោកជំទាវ សាស្ត្រាចារ្យ ម៉ួយ ធីតា** ព្រឹទ្ធបុរសនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលជាសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ការសិក្សាដល់រូបខ្ញុំទាំងពីរនាក់។ លោកស្រីសាស្ត្រាចារ្យបានផ្តល់ឱកាស ដល់យើងខ្ញុំទាំងពីរនាក់ ក្លាយទៅជាចំណែកនៃកាតព្វកិច្ចមួយរបស់លោកស្រី ក្នុងការផ្តល់ដំបូន្មានល្អៗលើកទឹកចិត្ត និងត្រួសត្រាយផ្លូវ ឲ្យក្លាយចេញទៅជាផ្លែផ្កាដ៏ស្រស់បំព្រង ។

ជាចុងក្រោយយើងខ្ញុំសូមបួងសួងដល់ទេវតា និងវត្ថុស័ក្តសិទ្ធិនៅក្នុងលោក សូមឲ្យអ្នកមានគុណ មាតាបិតា និងថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាស្ត្រាចារ្យដែលបានយកចិត្តទុកដាក់ ក្នុងការអប់រំទូន្មានប្រៀនប្រដៅ ដល់យើងខ្ញុំទាំងពីរនាក់ ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំបាទឈ្មោះ **អ៊ី តារាវិមាន** និងនាងខ្ញុំឈ្មោះ **ម៉ៃ ស្រីពេជ** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី ២១ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** មានកិត្តិយសនៅក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងការតាក់តែង ចងក្រងនូវប្រធានបទមួយនៃសារណាបញ្ចប់ការសិក្សាស្តីពី«**សន្តតិកម្ម**» ដែលទាក់ទងទៅនឹងការសិក្សាលើមុខវិជ្ជានីតិរដ្ឋប្បវេណី នីតិបេតិកភ័ណ្ឌនៃគ្រួសារ និងនីតិវិធីរដ្ឋប្បវេណីដែលបានសិក្សាកន្លងមក ដើម្បីយកជាទ្រឹស្តីនៃមុខវិជ្ជាទាំងអស់នេះមកធ្វើជាការចងក្រងជាស្នាដៃនេះឡើង។

ម្យ៉ាងវិញទៀត មូលហេតុដែលជម្រុញឲ្យយើងខ្ញុំស្រាវជ្រាវអំពីប្រធានបទ«**សន្តតិកម្ម**» នេះឡើងគឺដើម្បីទុកជាឯកសារជំនួយស្មារតី សម្រាប់និស្សិតទាំងឡាយ ដែលមានគោលបំណងស្វែងយល់ និងសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ។ មូលហេតុដែលនាំឱ្យយើងខ្ញុំជ្រើសរើសប្រធានបទនេះឡើង ពិព្រោះយល់ឃើញថា ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អ្នកច្បាប់ ក្នុង ការសិក្សាស្រាវជ្រាវស្វែងយល់ដោយសារតែគ្រួសារណាក៏ដោយតែងតែមានបញ្ហាជៀសមិនផុតឡើយជាពិសេសទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់បុគ្គលដែលបានស្លាប់បាត់បង់ជីវិតទៅហើយ។ មិនត្រឹមតែប៉ុណ្ណោះចំពោះប្រជាពលរដ្ឋ ក៏មានសារៈសំខាន់ចំពោះពួកគាត់ផងដែរ ដោយសារតែអាចធ្វើ ឲ្យពួកគាត់បានស្វែងយល់អ្វីទៅជាសន្តតិកម្ម ការបែងចែកទ្រព្យរបស់មតកជន និងនរណាខ្លះ ដែលមានសិទ្ធិកាតព្វកិច្ចនិងលក្ខណៈសម្បត្តិជាសន្តតិជន។ ដោយសារតែពួកយើងមានរយៈពេលនៃការស្រាវជ្រាវមានកំណត់ ដូចនេះលទ្ធផលនៃការស្រាវជ្រាវនេះពិតជាមានកង្វះខាតចន្លោះប្រហោងផ្សេងៗ ដោយមិនបានវិភាគឲ្យល្អិតល្អន់ គ្រប់ជ្រុងជ្រោយនោះទេ។

យើងខ្ញុំសង្ឃឹមយ៉ាងខ្លាំងថា តាមរយៈការសិក្សាស្រាវជ្រាវពីសន្តតិកម្មដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ពិតជាបានចូលរួមក្នុងការកាត់បន្ថយនូវជម្លោះ និងបញ្ហាគ្រួសារនានា តាមរយៈការចែករំលែកនូវចំណេះដឹងច្បាប់ទៅដល់ប្រជាពលរដ្ឋក្នុងសង្គម ដើម្បីឲ្យសង្គមមួយ ឬប្រទេសមួយពោរពេញទៅដោយការអត់ឱនយោគយល់ អធ្យាស្រ័យគ្នា ជាពិសេសនៅក្នុងរង្វង់គ្រួសារ។

យើងខ្ញុំសូមសំដែងការត្រេកអរជាអនេកក្នុងការរៀបរៀងកិច្ចការស្រាវជ្រាវនេះ ជាឯកសារសំរាប់ការសិក្សាឡើង ហើយក៏សូមខន្តីអភ័យទោសជាមុននូវរាល់កំហុសឆ្គង និងរាល់ចំណុចខ្វះខាតទាំងឡាយដែលកើតឡើងដោយអចេតនាដូចជា ពាក្យពេចន៍ អក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ ផងដែរ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកជំទាវ សាស្ត្រាចារ្យ ម៉ួយ ធីតា** ដែលបានបង្ហាត់បង្រៀន និងពន្យល់ណែនាំដោយយកចិត្តទុកដាក់ និងសូមជូនពរឱ្យអ្នកគ្រូជួបតែ ពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃសន្តតិកម្ម**

**១.១.និយមន័យ** ........ **៣**

**១.២.មូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម** ........ **៣**

**១.៣.ទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្ម** ........ **៤**

**១.៤.មត៌ក** ........ **៥**

**១.៥.អានុភាពនៃសន្តតិកម្ម** ........ **៦**

១.៥.១.ការទទួលបន្តនូវមត៌ក ........ ៦

១.៥.២.ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីសន្តតិជនច្រើននាក់........ ៦

**១.៦.បុគ្គលដែលមាន និង ពុំមានសមត្ថភាពទទួលសិទ្ធិ (សន្តតិជន)**........ **៧**

១.៦.១.បុគ្គលដែលមានសមត្ថភាពទទួលសិទ្ធិ (សន្តតិជន) ........ ៧

១.៦.២.បុគ្គលដែលពុំមានសមត្ថភាពទទួលសិទ្ធិ ........ ៨

១.៦.២.១.អភ័ព្វបុគ្គល........ ៨

១.៦.២.២.ជនដែលផ្តាច់ចេញពីមត៌ក ........ ៨

**១.៧.ប្រភេទនៃសន្តតិកម្ម** ........ **៩**

**១.៨.ការបោះបង់សន្តតិកម្ម និងការយល់ព្រមដោយមានកម្រិត**........ **៩**

១.៨.១.ការបោះបង់សន្តតិកម្ម ........ ៩

១.៨.២.ការយល់ព្រមដោយមានកម្រិត ........ ១០

## ជំពូកទី២

## សន្តតិកម្មតាមមតកសាសន៍

**២.១.សញ្ញាណទូទៅ.......... ១១**

២.១.១.និយមន័យ .......... ១១

២.១.២.លក្ខណៈនៃមតកសាសន៍.......... ១២

**២.២.លក្ខខណ្ឌក្នុងការបង្កើតនូវមតសាសន៍ .......... ១២**

២.២.១.សមត្ថភាពក្នុងការធ្វើមតកសាសន៍ (មតកជន).......... ១២

២.២.១.១.នីតិជន.......... ១២

២.២.១.២.អត្តាធីនភាព .......... ១២

២.២.១.៣.ជននៅក្រោមអាណាព្យាបាលទូទៅ .......... ១២

២.២.២.ទម្រង់នៃមតកសាសន៍ .......... ១៣

២.២.២.១.ទម្រង់នៃមតកសាសន៍ធម្មតា.......... ១៣

ក.មតកសាសន៍ដោយលិខិតយថាភូត (មាត្រា១១៧៣).......... ១៣

ខ.មតកសាសន៍ដោយលិខិតសម្ងាត់ (មាត្រា១១៧៥).......... ១៣

គ.មកតសាសន៍ដោយលិខិតឯកជន (មាត្រា១១៧៤).......... ១៤

២.២.២.២.ទម្រង់នៃមតកសាសន៍ពិសេស .......... ១៥

ក.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា១១៧៦) .......... ១៥

ខ.មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (មាត្រា ១១៧៧).......... ១៥

គ.មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ (មាត្រា ១៧៧៨) .......... ១៦

ឃ. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍ (មាត្រា ១១៧៩).......... ១៧

ង.មតកសាសន៍ចំពោះជនជាតិខ្មែរដែលរស់នៅបរទេស (មាត្រា ១១៨១).......... ១៧

**២.៣.ខ្លឹមសារនៃមតកសាសន៍ .......... ១៨**

២.៣.១.សន្តតិជន .......... ១៨

២.៣.២.ការកំណត់ចំណែកមត៌ក.......... ១៨

២.៣.៣.ការកំណត់នូវវិធីបែងចែកមត៌ក.......... ១៩

២.៣.៤.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ...................................................... ២០
២.៣.៥.ករណីមតកជនហាមមិនឲ្យបែងចែកក្នុងរយៈពេលកំណត់ ...................................... ២០
**២.៤.អានុភាពនៃមតកសាសន៍ ...................................................... ២០**
២.៤.១.អានុភាពនៃមតកសាសន៍ក្នុងករណីមានលក្ខខណ្ឌបង្អង់ ...................................... ២០
២.៤.២.អានុភាពនៃការកំណត់ចំណែកមត៌ក ...................................................... ២១
២.៤.២.១.មរណភាពរបស់ជនដែលត្រូវបានសន្មត់ថាជាសន្តតិជន ...................................... ២១
២.៤.២.២.ការកម្រិតនូវមតកសាសន៍ចំពោះអ្នកអាណាព្យាបាល ...................................... ២១
២.៤.២.៣.សិទ្ធិទទួលនូវទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានត្រូវបានមោឃភាព ...................... ២២
**២.៥.អច្ច័យទាន ...................................................... ២២**
២.៥.១.អច្ច័យទានសកល និងអច្ច័យទានមានកំណត់ ...................................................... ២២
២.៥.២.សកម្មភាពឯកតោភាគី ...................................................... ២៣
២.៥.៣.អានុភាពនៃអច្ច័យទាន ...................................................... ២៣
២.៥.៤.មរណភាពរបស់អច្ច័យលាភី ...................................................... ២៣
២.៥.៥. អច្ច័យទានភ្ជាប់បន្ទុក ...................................................... ២៥
២.៥.៦.ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក ...................................................... ២៦
២.៥.៧.ការទទួលខុសត្រូវរបស់អច្ច័យលាភីនៅក្នុងអច្ច័យទានជាប់បន្ទុក ...................................... ២៦
២.៥.៨.ការយល់ព្រម និងការបោះបង់អច្ច័យទាន ...................................................... ២៧
២.៥.៨.១.ការបោះបង់អច្ច័យទាន ...................................................... ២៧
២.៥.៨.២.ការទទួលស្គាល់ ឬបោះបង់ ក្នុងករណីដែអច្ច័យលាភីជាសន្តតិជន ...................................... ២៧
២.៥.៨.៣.ការបោះបង់ ឬ ការទទួលស្គាល់ដោយសន្តតិជនរបស់អច្ច័យលាភី ...................................... ២៨
២.៥.៨.៤.ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ...................................... ២៨
២.៥.៨.៥.ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់ ...................................... ២៨
២.៥.៩.អានុភាពនៃអច្ច័យទាន ...................................................... ២៨
២.៥.៩.១.អច្ច័យទានមានកំណត់ ...................................................... ២៨
ក.សិទ្ធិទទួលផលរបស់អច្ច័យលាភី ...................................................... ២៩

ខ.អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតក្នុងមត៌ក ........ ២៩

គ.អច្ច័យទាននៃវត្ថុ ឬសិទ្ធិ ដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន ........ ៣០

ឃ.ឧបាទេសកម្មលើវត្ថុ ........ ៣០

ង.ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល ........ ៣០

២.៥.៩.២.អច្ច័យទានសកល ........ ៣១

**២.៦. ការលុបចោលមតកសាសន៍ ........ ៣១**

២.៦.១.ទម្រង់នៃការលុបចោលមតកសាសន៍ ........ ៣២

២.៦.១.១.ការលុបចោលដោយទម្រង់នៃមតកសាសន៍ ........ ៣២

២.៦.១.២.ការលុបចោលដោយការចាត់ចែងនាពេលនៅរស់ ........ ៣២

២.៦.១.៣.ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍ ........ ៣២

**២.៧.ការប្រតិបត្តិមតកសាសន៍ ........ ៣៣**

២.៧.១.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ ........ ៣៣

២.៧.២.សិទ្ធិ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ ........ ៣៤

២.៧.២.១. ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ........ ៣៤

២.៧.២.២.សិទ្ធិ និងករណីកិច្ចក្នុងការគ្រប់គ្រងមត៌ក ........ ៣៥

២.៧.២.៣.សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍ ........ ៣៦

២.៧.២.៤.សិទ្ធិលាឈប់ពីអ្នកប្រតិបត្តិមតកសាសន៍ ........ ៣៦

២.៧.៣.សហអ្នកប្រតិបត្តិមតកសាសន៍ ........ ៣៧

២.៧.៤.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ ........ ៣៧

២.៧.៥.សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍ ........ ៣៨

**២.៨.ភាគបម្រុង ........ ៣៨**

២.៨.១.អ្នកមានសិទ្ធិលើភាគបម្រុង ........ ៣៩

២.៨.២.ការគណនាភាគបម្រុង ........ ៤០

២.៨.២.១.ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុង ........ ៤០

២.៨.២.២.វិធីគណនានៃចំនួនដែលបំពានភាគបម្រុង ........ ៤១

២.៨.២.៣.ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ............ ៤២

២.៨.២.៤.ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ............ ៤៣

២.៨.២.៥.លំដាប់នៃការកាត់បន្ថយ ............ ៤៣

២.៨.២.៦.អានុភាពនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង............ ៤៥

## ជំពូកទី៣

## សន្តតិកម្មតាមច្បាប់

**៣.១. សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់ ............ ៤៦**

៣.១.១. និយមន័យ ............ ៤៦

៣.១.២. លំដាប់សន្តតិជន ............ ៤៧

៣.១.២.១ សន្តតិជនលំដាប់ទី១ ៖ បច្ឆាញាតិ............ ៤៨

៣.១.២.២ សន្តតិជនលំដាប់ទី២ (បុព្វញាតិថ្នាក់ទី១ ឬ ថ្នាក់ទី២)............ ៤៨

៣.១.២.៣ សន្តតិជនលំដាប់ទី៣ ( បងប្អូនបង្កើត)............ ៤៩

៣.១.២.៤ សន្តតិជនជំនួស ............ ៤៩

៣.១.២.៥ សន្តតិជនជានិច្ច ............ ៥០

**៣.២. ការអនុវត្តនៃសន្តតិកម្មតាមច្បាប់ ............ ៥១**

៣.២.១ ការយល់ព្រម និងការបោះបង់ចោលសន្តតិកម្ម ............ ៥១

៣.២.១.១ ការយល់ព្រមមានកម្រិត៖ ............ ៥១

៣.២.១.២ ការយល់ព្រមទាំងស្រុង៖ ............ ៥៣

៣.២.១.៣ ការបោះបង់សន្តតិកម្ម៖............ ៥៤

៣.២.២ របបនៃការគ្រប់គ្រងសន្តតិកម្មតាមច្បាប់............ ៥៤

៣.២.២.១ ការសម្រួលរវាងម្ចាស់បំណុល ............ ៥៤

៣.២.២.២ ការគ្រប់គ្រងមត៌ក............ ៥៦

៣.២.២.៣ ស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់ ............ ៥៨

ក. នត្ថិភាពនៃសន្តតិជន............ ៥៩

ខ. បដិទានសន្តតិកម្ម ............ ៦០

**៣.៣ ការបែងចែកមត៌ក ........................................................................ ៦១**

៣.៣.១ ការបែងចែកមត៌ក........................................................................................ ៦១

៣.៣.១.១ ការពិភាក្សាបែងចែកមត៌ក ........................................................................៦១

៣.៣.១.២ ការបែងចែកដោយតុលាការ ......................................................................... ៦២

៣.៣.១.៣ អានុភាពនៃការបែងចែក ............................................................................ ៦៣

៣.៣.២ រូបមន្តនៃការបែងចែកមត៌ក .......................................................................៦៣

៣.៣.២.១ សហព័ទ្ធ និងបច្ឆាញាតិផ្ទាល់.......................................................................៦៤

៣.៣.២.២ សហព័ទ្ធ និងបុព្វញាតិផ្ទាល់.........................................................................៦៤

៣.៣.២.៣ សហព័ទ្ធ និងបងប្អូនបង្កើត ឬសន្តតិជនជំនួស...............................................៦៥

៣.៣.៣ ការសម្រួលចំណែកមត៌ក ........................................................................... ៦៥

៣.៣.៣.១ ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស........................................៦៦

៣.៣.៣.២ វិភាគទាន ............................................................................................៦៩

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

នៅក្នុងប្រទេស កម្ពុជាយើងបានឆ្លងកាត់ជាច្រើនសម័យកាល ក្នុងនោះយើងនិងលើកយកសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងបច្ចុប្បន្ន មកសិក្សាទៅលើពាក្យ «**សន្តតិកម្ម**» ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យសម័យនោះគឺមិនមានទ្រព្យសម្បត្តិឯកជននោះទេ គឺគ្រប់ទ្រព្យសម្បត្តិទាំងអស់សុទ្ធសឹងតែជារបស់អង្គការ។ នៅក្នុងសម័យនោះគ្មានទ្រព្យសម្បត្តិឯកជន លើកលែងតែ ចានឆ្នាំង សម្លៀកបំពាក់មួយសម្រាប់លើខ្លួនតែប៉ុណ្ណោះក្រៅពីនោះសុទ្ធសឹងតែជាទ្រព្យសមូហភាពទាំងអស់ ដូចនេះគ្មានការធ្វើសន្តតិកម្មទៅឲ្យអ្នកជំនាន់ក្រោយរបស់ខ្លួន នោះឡើយ។ នាសម័យនោះប្រជារាស្ត្ររស់នៅដោយភាពភ័យខ្លាច ដោយគ្មានសិទ្ធិគ្រប់បែបយ៉ាង ដោយអំណាចផ្តាច់ការ យ៉ាងព្រៃផ្សៃបំផុត ។ បន្ទាប់ពីឆ្លងកាត់សម័យកាលដ៏គួរឲ្យខ្លាចរួចមក កម្ពុជាក៏បានរះសារជាថ្មី ច្បាប់ភូមិបាលក៏បានចាប់បដិសន្ធិឡើងដើម្បីកំណត់កម្មសិទ្ធិឯកជន ដោយឈរលើមូលដ្ឋាននៃក្រមរដ្ឋប្បវេណី ។ ក្រោយពីព្រះរាជាណាចក្រកម្ពុជាបានប្រកាសរដ្ឋធម្មនុញ្ញថ្មី ឆ្នាំ១៩៩៣ របបកម្មសិទ្ធិឯកជនត្រូវបានបញ្ជាក់សារជាថ្មីថា របបកម្មសិទ្ធិឯកជនមានចំពោះតែប្រជាជនតែប៉ុណ្ណោះ។ ក្រោយពីប្រកាសរដ្ឋធម្មនុញ្ញនេះគេចាប់ផ្តើមរៀបចំច្បាប់ភូមិបាលឡើងវិញ ដោយប្រើរយៈពេលច្រើនឆ្នាំទើបអាចដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនាឆ្នាំ ១៩៩៤ ហើយមានការពិភាក្សាគ្នាជាច្រើនលើកច្រើនសារ ទើបអាចចេញច្បាប់ភូមិបាល ២០០១។ ប៉ុន្តែរហូតដល់ឆ្នាំ២០០៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចាប់បដិសន្ធិឡើងក្រោមការឧបត្ថម្ភគាំទ្រ ពីប្រទេសជប៉ុនដែលជាមិត្ត ហើយនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នេះបានកំណត់យ៉ាងច្បាស់ ពីកម្មសិទ្ធិឯកជន និងការធ្វើសន្តតិកម្ម ។ បន្ទាប់ពីនោះ ក្នុងឆ្នាំ២០១១ ក៏បានបង្កើតឲ្យមាន ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ដើម្បីនិរាករណ៍នូវច្បាប់ភូមិបាលមួយចំនួនចេញ ។

របបសន្តតិកម្មនៅក្នុងពិភពលោក ចែកចេញជាពីរ គឺ សន្តតិកម្មដោយឈរលើគោលការណ៍ជម្រះបញ្ជីនិងសន្តតិកម្មឈរលើគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ។ គោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់មតកជននៅពេលដែលសន្តតិកម្មកើតមានឡើង ហើយសន្តតិជននឹងស្នងតែទ្រព្យសកម្មតែប៉ុណ្ណោះ ប៉ុន្តែត្រូវឆ្លងកាត់នីតិវិធីស្មុគស្មាញច្រើន ។ ចំណែកឯគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិវិញ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីកិច្ចទាំងអស់របស់មតកជន ។ ក្រឡេកមកមើលប្រទេសកម្ពុជាយើងទទួលយកការធ្វើសន្តតិកម្មដោយឈរលើគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មូលហេតុដោយសារតែ ប្រជាជនដែលមានទ្រព្យសម្បត្តិច្រើន ងាយស្រួលក្នុងការទូទាត់ដោយងាយស្រួល ដើម្បីសងបំណុលទ្រព្យសម្បត្តិជាក់លាក់ ។

យើងបានដឹងហើយថារូបវន្តបុគ្គលតែងតែមាននូវញាតិ ហើយអំឡុងពេលដែលខ្លួននៅរស់ខិតខំប្រឹងប្រែងបង្កើនទ្រព្យសម្បត្តិរបស់ខ្លួន នៅមុនពេលទទួលមរណភាព នៅពេលដែលខ្លួនបានទទួលមរណភាពទៅមតកជនដែលជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងអស់នោះមិនអាចយកទៅតាមបានទេ ។ នៅក្នុងករណីនេះក្រមរដ្ឋប្បវេណីបានរំលេចឡើងនូវ ពាក្យថាសន្តតិកម្ម ឡើងមក ។

តើសន្តតិកម្មមានប៉ុន្មានប្រភេទ ? និងការអនុវត្តបែបណាខ្លះ ?

ដើម្បីឆ្លើយតបនឹងបញ្ហាខាងលើនេះ យើងនឹងធ្វើការសិក្សាទៅលើ សន្តតិកម្ម ឲ្យបានលម្អិតដែលទាក់ទងនឹង ទិដ្ឋភាពទូទៅនៃសន្តតិកម្ម (ជំពូកទី១) មិនតែប៉ុណ្ណោះយើងក៏នឹងសិក្សាទៅលើប្រភេទនៃសន្តតិកម្មផងដែរ នៅក្នុង ជំពូកទី២ (សន្តតិកម្មតាមមតកសាសន៍) និងជំពូកទី៣ (សន្តតិកម្មតាមច្បាប់) ។

# ជំពូកទី១

# និន្នភាពទូទៅនៃសន្តតិកម្ម

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃសន្តតិកម្ម

នៅពេលបុគ្គលម្នាក់ចាប់កំណើត រមែងតែងតែទទួលបាននូវបុគ្គលភាពគតិយុត្ត ហើយបាត់បង់ទៅវិញ នៅពេលដែលទទួលមរណភាព ។ ទោះបីជាបាត់បង់នូវបុគ្គលភាពគតិយុត្តក៏ពិតមែន ក៏ប៉ុន្តែគោលការណ៍មួយចំនួននៅតែចាត់ចែងឲ្យបុគ្គលនោះឲ្យសមស្របទៅតាមបរិបទរស់នៅ ។ បុគ្គលម្នាក់ៗពេលនៅរស់រមែងចង់បង្កើននូវទ្រព្យសម្បត្តិដើម្បីជាការផ្គត់ផ្គង់នូវជីវភាពរស់នៅក្នុងសង្គម និងគ្រួសារ ។ ក៏ប៉ុន្តែយើងសង្កេតឃើញថា បុគ្គលដែលបាត់បង់នូវបុគ្គលភាពគតិយុត្ត (មរណភាព) មិនអាចយកនូវសិទ្ធិ និងទ្រព្យសម្បត្តិទៅតាមខ្លួនបានទេ ។ ដូចនេះហើយទើបច្បាប់បានបង្កើន នូវពាក្យ««**សន្តតិកម្ម**»» និងក៏ដូចជាការអនុវត្តទៅតាមនីតិវិធីតាមច្បាប់ដែលបានចែងអំពីសន្តតិកម្មនេះ ។

យ៉ាងណាមិញ បុគ្គលដែល បាត់បង់នូវ បុគ្គលភាពគតិយុត្ត ដែលបានបន្សល់នូវទ្រព្យសម្បត្តិ ច្បាប់នឹងធ្វើការបែងចែក ទៅតាមគោលការណ៍នៃសន្តតិកម្ម ។

ដើម្បីឲ្យកាន់តែច្បាស់ យើងគួរតែយល់អំពី (១.១.)និយមន័យនៃសន្តតិកម្មជាមុនសិន ។

## ១.១.និយមន័យ

**សន្តតិកម្ម** គឺជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់ ។

## ១.២.មូលហេតុនៃការចាប់ផ្ដើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមដោយសារមរណភាពរបស់មតកជន[1] មានន័យថានៅពេលដែលមតកជននៅរស់ ពោលគឺមិនអាចចាប់ផ្តើមសន្តតិកម្មបានទេ ហើយក៏មិនត្រូវបានទទួលស្គាល់ចំពោះការធ្វើ។ ការបើកសន្តតិកម្មមិនអាចចាប់ផ្តើមបើកនៅក្នុងអំឡុងពេលដែលបុគ្គលម្ចាស់ទ្រព្យរស់រានមានជីវិតនោះទេ។

បើនិយាយអំពីមរណភាពនោះគឺ នឹងពិតជានិយាយអំពីសាកសព នៅពេលមរណភាពគ្មានសាកសពនោះនឹងត្រូវបង្ហាញពីការបាត់ខ្លួន ឬការអវត្តមានរបស់ជននោះ។ ទាំងអវត្តមាន ទាំងការបាត់ខ្លួន សុទ្ធតែជាមូលហេតុនៃការបើកសន្តតិកម្មដូចគ្នា ប៉ុន្តែដោយសារគ្មានសាកសពបញ្ជាក់ឲ្យបានច្បាស់លាស់ដែលជាសំអាងមិនអាចបដិសេធបានថាជននោះបាត់បង់ជីវិតហេតុដូច្នេះ,ផលវិបាកនៃការបើកសន្តតិកម្មនៃបុគ្គលអវត្តមាន ឬ

[1] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៤៥ កថាខណ្ឌទី ១

បុគ្គលបាត់ខ្លួន,នឹងទាមទារដីកាពីតុលាការប្រកាសអំពីការទទួលស្គាល់ហេតុកការណ៍នោះទើបដំណើរការនីតិវិធីបន្តទៅមុខទៀតបាន។[2]

ចំពោះបញ្ញត្តិដែលបានដែលបានចែងអំពីការបាត់ខ្លួន អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាពតាមរយៈការប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា ៤១ នៃក្រមរដ្ឋប្បវេណី នោះសន្តតិកម្មត្រូវចាប់ផ្តើមផងដែរ។

ក្នុងករណីនៃការអវត្តមាន ឬការបាត់ខ្លួនបុគ្គលម្នាក់ ដែលការអវត្តមានដោយពុំដឹងច្បាស់ថា បុគ្គលនោះនៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ហើយតុលាការបានប្រកាសថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ន្ធ ឬអ្នកដែលសន្មត់ថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុក ម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។[3]

បុគ្គលដែលបាត់ខ្លួននៅតំបន់មានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗទៀតដែលអាចនាំឲ្យមានទទួលមរណភាព ដោយពុំដឹងច្បាស់ថាអ្នកបាត់ខ្លួន ឬអវត្តមាននោះនៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយពីគ្រោះថ្នាក់ផ្សេងៗទៀតនោះបានកន្លងផុត ហើយតុលាការបានប្រកាសថាបុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់អ្នកដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។[4]

## ១.៣.ទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។[5] មានន័យថា ក្នុងករណីដែលចាំបាច់មានអន្តរាគមន៍របស់តុលាការចំពោះសន្តតិកម្ម ដូចជាការបោះបង់នូវសន្តតិកម្ម ការយល់ព្រមដោយមានកម្រិត ការបែងចែកមត៌ក ជាអាទិ៍ តុលាការដែលមានសមត្ថកិច្ចនៅលំឋានរបស់មតកជន នៅពេលដែលមតកជននោះបានទទួលមរណភាព ជាតុលាការដែលមានសមត្ថកិច្ច ។

[2] សៀវភៅ នីតិបេតិកភណ្ឌ និងគ្រួសារ របស់សាស្ត្រាចារ្យ អ្នកស្រី វណ្ណធី ១២៦ បោះពុម្ពលើកទី ៣ ខែ មករា ឆ្នាំ ២០១៨

[3] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៤១ កថាខណ្ឌទី ១

[4] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៤១ កថាខណ្ឌទី ២

[5] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៤៦

## ១.៤.មត៌ក

មត៌កអាចមានជាប្រាក់ បំណុល និង វត្ថុ (អចលនវត្ថុ និងចលនវត្ថុ)។ នៅក្នុងចំណោមមត៌ក មានតែអចលនវត្ថុទេ ដែលមានការលំបាកក្នុងការប៉ាន់ពីតម្លៃ ប៉ុន្តែប្រសិនបើ គ្មានការយល់ព្រម ឬព្រមព្រៀងគ្នាទេនោះ តម្រូវឲ្យមានអ្នកជំនាញ មកវាយតម្លៃ។

ពាក្យថាទ្រព្យមានន័យថា វត្ថុ (រាប់បញ្ចូលទាំងចលនវត្ថុ និងអចលនវត្ថុ) ឬយើងហៅថាជាធនធាន ឬសម្បត្តិដែលបុគ្គលម្នាក់ៗមាន។[6] ប្រសិនបើន័យគតិយុត្តវិញ ទ្រព្យជាបេតិកភ័ណ្ឌរបស់បុគ្គលម្នាក់ៗដែលមាន ឬដែលបានបន្សល់ទុកដោយមតកជន ដែលក្នុងនោះរួមមានទាំងវត្ថុ និងសិទ្ធិជាមួយគ្នា ឬយើងអាចហៅថា ជាទ្រព្យរូបីយ និងទ្រព្យអរូបីយ។

បេតិកភ័ណ្ឌ គឺជាទ្រព្យដែលបុគ្គលម្នាក់មាន ក្នុងនោះរួមមានទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។

- **ទ្រព្យសកម្ម** គឺជាទ្រព្យរបស់បុគ្គលម្នាក់ៗដែលមាន។ ពោលជាទ្រព្យសម្បត្តិដែលនីតិបុគ្គលមាន។[7]
- **ទ្រព្យអកម្ម** គឺជាទ្រព្យដែលជាប់បំណុលរបស់បុគ្គលដទៃ។ ទ្រព្យអកម្មមានដូចតទៅៈ

**បំណុលផ្ទាល់ខ្លួនៈ** ប្តីប្រពន្ធដែលស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ នៅពេលដែលលែងលះ ទោះបីជាច្បាប់បានចែងថាប្តីប្រពន្ធមានការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះបំណុលក៏ដោយ ប៉ុន្តែសកម្មភាពមួយចំនួនមិនចាត់ចូលជាសកម្មភាពបំណុលរួមរបស់គ្រួសារឡើយដូចជា ការប្រព្រឹត្តល្បែងស៊ីសង ផឹកស្រា...ជាដើម ហើយត្រូវបានជំពាក់បំណុលគេ ទោះបីជាបំណុលនោះមាននៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ក៏ដោយ សកម្មភាពទាំងនោះមិនចាត់ចូលជាបំណុលរួមរបស់គ្រួសារឡើយ គឺជាបំណុលផ្ទាល់ខ្លួនរបស់សហព័ទ្ធ។

**បំណុលរួមៈ** ជាបំណុលទាំងឡាយណាកើតឡើងដើម្បីផលប្រយោជន៍គ្រួសារ នោះមិនមែនជាបំណុលបុគ្គល ឬបំណុលផ្ទាល់ខ្លួនរបស់សហព័ទ្ធឡើយ[8]។ ហេតុនេះបំណុលដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍លោកជំទាវ សាស្ត្រាចារ្យត្រូវចាត់ទុកជាទ្រព្យរួមរបស់សហព័ទ្ធ។ ហើយទ្រព្យរួមនោះហៅថាទ្រព្យអកម្ម ចំពោះការបែងចែកទ្រព្យអកម្ម ចៅក្រមត្រូវធ្វើការបែងចែកបំណុលជាពីរដោយឲ្យសហព័ទ្ធក្លាយជាកូនបំណុល និងធ្វើការចេញសងបំណុលរួមគ្នានេះជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្តីប្រពន្ធចំពោះ

[6] វចនានុក្រមខ្មែរ សម្តេចសង្ឃ ជួនណាត

[7] សន្ទានុក្រម រដ្ឋប្បវេណី ទំព័រទី ៨ លេខរៀង ៥៩

[8] សៀវភៅ នីតិបេតិកភណ្ឌ និងគ្រួសារ របស់សាស្ត្រាចារ្យ អ្នកស្រី វណ្ណធី ទំព័រ ៣៧ បោះពុម្ពលើកទី ៣ ខែ មករា ឆ្នាំ ២០១៨

ម្ចាស់បំណុល។ ដូច្នេះសបញ្ជាក់ឲ្យឃើញថា តុលាការមិនអាចធ្វើការបែងចែកបំណុលបានទេ គឺវានាំឲ្យប៉ះពាល់ដល់កាតព្វកិច្ចសាមគ្គីរបស់សហាព័ន្ធ[9]។

ជាទូទៅសិទ្ធិលើបំណុលនេះនឹងបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ប៉ុន្តែ បើសិនជាមានការព្រមព្រៀងរវាងសន្តតិជនសិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែក។

តាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន។ សន្តតិកម្មត្រូវធ្វើឡើងតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ យោងតាមសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី សន្តតិកម្មអាចធ្វើឡើងតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ឬតាមគោលការណ៍ជម្រះបញ្ជី ក៏ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណី បានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មិនជ្រើសរើសយកគោលការណ៍ជម្រះបញ្ជីទេ។

## ១.៥.អានុភាពនៃសន្តតិកម្ម

សន្តតិកម្ម មានអានុភាព នៅពេលដែលមតកជនទទួលមរណភាព ។ ក្រៅពីនេះអានុភាពនៃសន្តតិកម្មក៏មានធ្វើការបកស្រាយតាមប្រភេទនៃសន្តតិកម្មនីមួយៗផងដែរ គឺ ចំណុច ២.៤. អានុភាពនៃមតកសាសន៍ ជាដើម ។

### ១.៥.១.ការទទួលបន្តនូវមត៌ក

សន្តតិជន ត្រូវតែទទួលបន្តនូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និងករណីកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន ។[10]

ដោយឡែកចំពោះកម្មសិទ្ធិលើកម្មវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលវត្ថុដែលជារតនសម្បត្តិ (ជើងធូប កោដ្ឋិ ដែលជាជំនឿរបស់បុព្វជន) បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជនដែលត្រូវបានដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវបានទទួលបន្តនោះ ។[11]

[9] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៩៧៥

[10] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៤៧ កថាខណ្ឌទី ១

[11] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៤៧ កថាខណ្ឌទី ២

### ១.៥.២.ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីសន្តតិជនច្រើននាក់

ការទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតកជន ដោយសហសន្តតិជនម្នាក់ៗ ទៅតាមសមាមាត្រនៃចំណែកមត៌កដែលខ្លួនត្រូវស្នង ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ។ តាមលទ្ធផលនៃសន្តតិកម្មនេះ ក្នុងករណីដែលមតកជនមានសិទ្ធិលើបំណុលចំពោះតតិយជន ប្រសិនបើសិទ្ធិលើបំណុលនោះ ជាប្រាក់ ជាអាទិ៍ ដែលអាចបែងចែកបាន សិទ្ធិលើបំណុលនេះត្រូវបែងចែក តាមមត៌កដែលច្បាប់បានកំណត់របស់សហសន្តតិជននីមួយៗ ដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់រង់ចាំពេលបែងចែកមត៌កទេ ។ម្យ៉ាងទៀត ក្នុងករណីដែលមកតជនមានកាតព្វកិច្ច ចំពោះតតិយជន ប្រសិនបើកាតព្វកិច្ចនោះជាប្រាក់ ជាអាទិ៍ ដែលអាចបែងចែកបាន ត្រូវបែងចែកតាមចំណែកមត៌កដែលច្បាប់បានកំណត់ ហើយប្រសិនបើសហសន្តតិជនមិនបានបោះបង់ចោលការស្នងនោះទេ ត្រូវទទួលករណីកិច្ចសងកាតព្វកិច្ចរបស់មតកជន ទៅតាមសមាមាត្រនៃចំណែកមត៌កដែលច្បាប់បានកំណត់ លើកលែងតែសហសន្តតិជនមិនបានបោះបង់សន្តតិកម្មនៅទេ ។ មាត្រា ១២៦៩ និងមាត្រា ១២៧៥ ត្រូវបានបញ្ញត្តឡើង ដោយយកគោលគំនិតនេះជាមូលដ្ឋាន ។ ហើយមត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ១.៦.បុគ្គលដែលមាន និង ពុំមានសមត្ថភាពទទួលសិទ្ធិ (សន្តតិជន)

ដូចចំណាងជើងខាងលើមានន័យថា មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែមានលក្ខណៈសម្បត្តិជាសន្តតិជនទាំងអស់នោះទេ ដើម្បីជាការសម្គាល់ នឹងការទទួលស្គាល់ថាជាសន្តតិជន បានយើងនឹងធ្វើការសិក្សានៅចំណុចខាងក្រោម ៖

### ១.៦.១.បុគ្គលដែលមានសមត្ថភាពទទួលសិទ្ធិ (សន្តតិជន)

បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពី បុគ្គលដែលពុំមានសមត្ថភាពទទួលសិទ្ធិ (១.៦.២) ទើបអាចទទួលបន្តសន្តតិកម្មបាន ។[12]

យ៉ាងណាមិញ ចំពោះទារកនៅដែលនៅក្នុងគភ៌ ក៏មានលក្ខណៈសម្បត្តិទទួលនូវសន្តតិកម្មបានដែរ ។[13]

ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌កដោយសន្តតិកម្មនោះបាន ។[14]

ទារកដែលនៅក្នុងគភ៌ពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន ។

[12] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៤៩ កថាខណ្ឌទី ១

[13] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៤៩ កថាខណ្ឌទី ២

[14] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៩ កថាខណ្ឌទី ២

### ១.៦.២.បុគ្គលដែលពុំមានសមត្ថភាពទទួលសិទ្ធិ

#### ១.៦.២.១.អភ័ព្វបុគ្គល

អភ័ព្វបុគ្គល គឺជាជនដែលគ្មានលក្ខណៈសម្បត្តិក្នុងការទទួលបានសន្តតិកម្ម ដោយមានហេតុណាមួយក្នុងចំណោមហេតុដូចខាងក្រោម៖

- ទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតមតកជន ឬអ្នកមានលំដាប់សន្តតិកម្មមុន ឬស្មើ ទោះបីដោយប្រយោល ឬផ្ទាល់ក្តី
- បុគ្គលដែលបានដឹងអំពីការសម្លាប់មតកជន ប៉ុន្តែមិនរាយការណ៍ ឬមិនប្តឹង លើកលែងតែបុគ្គល នោះមិនអាចវិនិច្ឆ័យល្អ ឬអាក្រក់ ឬអ្នកសម្លាប់ជាសហព័ន្ធ ឬញាតិលោហិតខ្សែផ្ទាល់
- បុគ្គលដែលបានរារាំងមតកជន ក្នុងការលុបចោល ឬកែប្រែមតកសាសន៍ដោយឆបោក ឬគម្រាមកំហែង
- បុគ្គលដែលបានឲ្យមតកជនធ្វើ ឬលុបចោល ឬកែប្រែមតកសាសន៍ដោយឆបោក ឬគម្រាមកំហែង
- បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញ ឬលាក់ទុកនូវមតកសាសន៍របស់មតកជន។[15]

យើងអាចនិយាយបានថាបុគ្គលដែលមានចែងក្នុងមាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី មិនអាចក្លាយជាសន្តតិជនទេ ហើយក៏មិនអាចធ្វើសន្តតិកម្មតាមមតកសាសន៍បានដែរ (បើទោះបីជាមានឆន្ទៈរបស់មតកជនក៏ដោយ)។[16]

ទោះជាយ៉ាងណាក៏ដោយ កូនរបស់បុគ្គលនោះពុំមានកំហុសទេ ដូច្នេះគេអាចក្លាយជាសន្តតិជនដោយផ្អែកតាមសន្តតិកម្មជំនួសបាន (មាត្រា ១១៥៧-១)។

#### ១.៦.២.២.ជនដែលផ្តាច់ចេញពីមត៌ក

ប្រសិនបើម្ចាស់ទ្រព្យ មានឆន្ទៈមិនប្រគល់ទ្រព្យសម្បត្តិឲ្យទៅសន្តតិជន នៅពេលខ្លួនទទួលមរណភាព ម្ចាស់ទ្រព្យអាចផ្តាច់មត៌កពីសន្តតិជន តាមផ្លូវតុលាការ ឬកំណត់ក្នុងមតកសាសន៍។ ប្រសិនបើម្ចាស់ទ្រព្យមានឆន្ទៈផ្តាច់មត៌កពីសន្តតិកម្មតាមផ្លូវតុលាការ ត្រូវដាក់ពាក្យសុំដីកាសម្រេចមត៌ក ដោយភ្ជាប់ជាមួយនឹងមូលហេតុណាមួយ ដូចខាងក្រោម៖

- ប្រមាថមតកជន
- ធ្វើបាបមតកជន
- ទទួលបានសេចក្តីសម្រេចពីតុលាការ ដាក់ពន្ធនាគារមួយជីវិត
- អាចមើលថែទាំមតកជនបាន នៅពេលមានជម្ងឺ ប៉ុន្តែមិនមើលថែ

[15] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥០
[16] សៀវភៅ សិក្ខាសាលាធំលើកទី២សន្តតិកម្មតាមច្បាប់ រៀបចំឡើងវិញដោយ នីតិកោសល ទំព័រ ៤ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣

- ប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ គួរឲ្យកត់សម្គាល់ ជាអាទិ៍។[17]

ប្រសិនបើម្ចាស់ទ្រព្យមិនបានផ្ដាច់មត៌កពីសន្តតិជនតាមផ្លូវតុលាការ ម្ចាស់ទ្រព្យអាចសរសេរបញ្ជាក់តាមមតកសាសន៍។ ការផ្ដាច់មត៌កពីសន្តតិជនតាមសន្តតិកម្មតាមមតកសាសន៍ គឺម្ចាស់បណ្តាំ ឬម្ចាស់ទ្រព្យបានធ្វើមតកសាសន៍ផ្ដាច់មត៌កពីសន្តតិជន អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់សុំទៅតុលាការឲ្យផ្តាច់មត៌កពីសន្តតិជននោះ នោះពេលដែលមតកសាសន៍នោះ បង្កើតអានុភាព។ ប៉ុន្តែមតកជនអាចដាក់ពាក្យសុំទៅតុលាការ ឲ្យលុបចោលនូវការផ្តាច់មត៌កពីជនដែលត្រូវបានសន្មត់ថាជាសន្តតិជន នៅពេលណាក៏បាន នៅពេលដែលខ្លួននៅមានជីវិត (មតកជន)។[18]

## ១.៧.ប្រភេទនៃសន្តតិកម្ម

សន្តតិកម្មដោយយោងទៅតាមក្រមរដ្ឋប្បវេណី មាត្រា ១១៤៥-២ បានបញ្ជាក់ពីប្រភេទនៃសន្តតិកម្មមានពីរប្រភេទគឺ សន្តតិកម្មមានបណ្តាំ ឬសន្តតិកម្មតាមមតកសាសន៍ និងសន្តតិកម្មតាមច្បាប់ ។ យើងនឹងធ្វើការបកស្រាយយ៉ាងលម្អិតនៅក្នុងជំពូកបន្តបន្ទាប់ សន្តតិកម្មតាមមតកសាសន៍(ជំពូកទី២) និងសន្តតិកម្មតាមច្បាប់(ជំពូកទី៣) ។

## ១.៨.ការបោះបង់សន្តតិកម្ម និងការយល់ព្រមដោយមានកម្រិត

### ១.៨.១.ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះទៅតុលាការ។[19] បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។[20]

**ឧទាហរណ៍ ៖** ករណី មតកជន មានកាតព្វកិច្ចច្រើន នៅពេលទទួលសន្តតិកម្ម សន្តតិជននឹងទទួលការខូចខាត ។ ហេតុនេះ សន្តតិជនអាចបោះបង់សន្តតិកម្មនោះបាន ។

គោលគំនិតខាងលើ គឺ៖

- ការពារផលប្រយោជន៍សន្តតិជន
- គោរពឆន្ទៈរបស់សន្តតិជន ។

[17] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥១
[18] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៣ កថាខណ្ឌទី១
[19] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦០
[20] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦១

### ១.៨.២.ការយល់ព្រមដោយមានកម្រិត

សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ ។[21] ករណីនេះហៅថាការយល់ព្រមដោយមានកម្រិត ។

ប្រសិនបើ មត៌កដែលបានប្រើប្រាស់ក្រោយពីសងបំណុល មានមត៌កនៅសល់ សន្តតិជនប្រាកដជាចង់ធ្វើសន្តតិកម្ម ។ ទោះបីជាបំណុលច្រើនជាងមត៌ក ក៏ដោយ ក៏សន្តតិជន មិនចង់សងបំណុលដោយប្រើប្រាស់ប្រាក់របស់ខ្លួនទេ ។

នៅក្នុងករណីបែបនេះ គឺអាចយល់ព្រមដោយមានកម្រិតបាន ។ នៅពេលដែលធ្វើការយល់ព្រមដោយមានកម្រិត ជាដំបូងត្រូវប្រើប្រាស់មត៌ករបស់មតកជន មកសងកាតព្វកិច្ចសិន ។ បន្ទាប់មកប្រសិនបើ មានមត៌កនៅសល់ សន្តតិជន អាចធ្វើការបែងចែកមត៌កទាំងនោះហើយអាចធ្វើលទ្ធកម្មបាន ។

[21] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៦

# ជំពូកទី២

# សន្តិកម្មតាមមតកសាសន៍

# ជំពូកទី២
# សន្តតិកម្មតាមមតកសាសន៍

ជាទូទៅម្ចាស់កម្មសិទ្ធិករ មានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិ ទៅតាមឆន្ទៈ និងតម្រូវការរបស់ខ្លួន ជានិច្ច មិនថាមុនពេលស្លាប់ និងក្រោយពេលស្លាប់ ។ ដើម្បីអនុវត្តនូវសិទ្ធិចាត់ចែងក្រោយពេលដែលខ្លួនទទួលមរណភាព មុនពេលម្ចាស់កម្មសិទ្ធិករទទួលមរណភាព ត្រូវបង្កើតឲ្យមាននូវបណ្តាំ ឬ មតកសាសន៍ ដើម្បីអនុវត្តការចាត់ចែងទ្រព្យសម្បត្តិ ទៅតាមបំណង របស់ខ្លួនក្រោយពេលស្លាប់ទៅ ។

រូបវន្តបុគ្គលដែលទទួលមរណភាព នឹងបាត់បង់នូវសមត្ថភាពទទួលសិទ្ធិ ។ សិទ្ធិនេះរួមទាំងសិទ្ធិក្លាយជាម្ចាស់កម្មសិទ្ធិករនៃទ្រព្យផងដែរ ។ ទោះបីជាបុគ្គលនោះទទួលមរណភាពក៏ពិតមែន ក៏ប៉ុន្តែច្បាប់នៅតែគោរពតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ។ មានន័យថា គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និងបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ។ ការគោរពនូវសេរីភាពឆន្ទៈរបស់បុគ្គលដែលបានទទួលមរណភាព ក្នុងន័យនេះ បុគ្គលនោះអាចបង្ហាញឆន្ទៈ ដោយយោងតាមសន្តតិកម្មតាមមតកសាសន៍ដោយត្រឹមត្រូវតាមលក្ខខណ្ឌ ដែលអាចបង្ហាញថាការបង្ហាញឆន្ទៈមុនពេលស្លាប់របស់កម្មសិទ្ធិករ នោះ មិនមានវិការៈ ។

តទៅនេះ ប្រសិនបើទ្រព្យសម្បត្តិ ដែលម្ចាស់កម្មសិទ្ធិកបានទទួលមរណភាព នឹងប្រើពាក្យថាជាមត៌ក ។ ម្ចាស់កម្មសិទ្ធិករទទួលមរណភាព នឹងក្លាយទៅជាមតកជន ។

តើការបង្កើត និងអនុវត្ត នូវមតកសាសន៍ ត្រូវធ្វើឡើងយ៉ាងដូចម្តេច?

ដើម្បីជាការឆ្លើយតបទៅកាន់សំណួរខាងលើ យើងនឹងធ្វើការបកស្រាយ ទៅតាមចំណុចដែលមានខាងក្រោម ដូចតទៅ ៖

## ២.១.សញ្ញាណទូទៅ

### ២.១.១.និយមន័យ

សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា **សន្តតិកម្មមានបណ្តាំ ឬ តាមមតកសាសន៍** ។ មុនពេលដែលមតកជនទទួលមរណភាពបានបន្សល់ទុកនូវមតកសាសន៍ដែលជា បណ្តាំចុងក្រោយដើម្បីឲ្យសន្តតិជនអនុវត្តន៍តាមឆន្ទៈរបស់ខ្លួនមុនពេលទទួលអនិច្ចកម្ម ។

### ២.១.២.លក្ខណៈនៃមតកសាសន៍

មតកសាសន៍មានលក្ខណៈជាទម្រង់ ហើយចាំបាច់ត្រូវតែជាលាយលក្ខណ៍អក្សរ ដោយឲ្យមតកជនធ្វើឡើងដោយឆន្ទៈរបស់ខ្លួន និងដោយស្របទៅតាមលក្ខខណ្ឌ ឬនីតិវិធីត្រឹមត្រូវទៅតាមច្បាប់ដែលបានកំណត់ ។ មតកសាសន៍មានលក្ខណៈដូចតទៅ ៖

- មតកសាសន៍ ធ្វើឡើងដោយឯកតោភាគី (ដោយមតកជន)
- មតកសាសន៍ ត្រូវធ្វើឡើងតាមទម្រង់
- ចំណុចនៃមតកសាសន៍ ត្រូវបានកំណត់ដោយច្បាប់

## ២.២.លក្ខខណ្ឌក្នុងការបង្កើតនូវមតកសាសន៍

### ២.២.១.សមត្ថភាពក្នុងការធ្វើមតកសាសន៍ (មតកជន)

សមត្ថភាពក្នុងការធ្វើមតកសាសន៍ យើងសម្តៅទៅលើបុគ្គលដែលមានសិទ្ធិក្នុងការបង្កើតនូវមតកសាសន៍នេះឡើង ។ អ្នកមានសិទ្ធិបង្កើត គឺមានតែមតកជន ដែលជាម្ចាស់កម្មសិទ្ធិករនៃទ្រព្យប៉ុណ្ណោះ ។

#### ២.២.១.១.នីតិជន

រូបវន្តបុគ្គលដែលជានីតិជន ច្បាប់បានកំណត់ថាបុគ្គលនោះ គឺមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ គឺមានសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងៗ ដូចជាការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលមានសិទ្ធិក្នុងការប្រើប្រាស់អាស្រ័យផល និងក៏ដូចជាសិទ្ធិចាត់ចែង។ ក្នុងន័យនេះ នីតិជនមានសមត្ថភាពពេញលេញក្នុងការធ្វើនូវមតកសាសន៍ ។

#### ២.២.១.២.អត្តាធីនភាព

រូបវន្តបុគ្គលដែលជាអនីតិជន ដែលបានទទួលអត្តាធីនភាពក្លាយទៅជានីតិជន ដែលមានសិទ្ធិគ្រប់យ៉ាងដូចទៅនឹងនីតិជនធម្មតាដែរ ។ រូបវន្តបុគ្គលដែលមានសិទ្ធិទទួលបានអត្តាធីនភាពត្រូវបានកំណត់លក្ខខណ្ឌដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។[22]

#### ២.២.១.៣.ជននៅក្រោមអាណាព្យាបាលទូទៅ

ទោះបីជាបុគ្គលនេះ ត្រូវបានកម្រិតសមត្ថភាពក៏ដោយច្បាប់នៅតែគិតគូរពីការចាត់ចែងទ្រព្យសម្បត្តិរបស់ជននេះ ក៏ទោះបីដឹងថាបុគ្គលនេះមានសតិមិនប្រក្រតីក៏ដោយ ក៏អាចមានសិទ្ធិក្នុងការបង្កើតនូវមតកសាសន៍បានដែរ ។ ដើម្បីធ្វើមតកសាសន៍ ជនប្រភេទនេះបានត្រូវមានសមត្ថភាពខាងឆន្ទៈ ដោយឡែកចំពោះ

[22] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២

លក្ខខ័ណ្ឌក្នុងការធ្វើមតកសាសន៍នឹងធ្វើការបកស្រាយ នៅក្នុង (២.២.២.២) ទម្រង់នៃមតកសាសន៍ពិសេស និង ចំណុច (ក) មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ។

### ២.២.២.ទម្រង់នៃមតកសាសន៍

នេះគឺជាលក្ខខណ្ឌដែលសំខាន់ ប្រសិនបើទម្រង់នៃមតកសាសន៍នេះមិនត្រឹមត្រូវ ទៅតាមច្បាប់(មានន័យថាខុសទម្រង់) ទេនោះ មតកសាសន៍ នេះមិនមានអានុភាពឡើយ ។ ដូចនេះវាតម្រូវឲ្យយើងធ្វើការសិក្សា ឲ្យស៊ីជម្រៅទៅលើវាបន្ថែមទៀត ។ ដែលទម្រង់នៃមតកសាសន៍នេះ ធ្វើការបែងចែកជាពីរ ដើម្បីងាយស្រួលយល់ គឺ (២.២.២.១) ទម្រង់នៃមតកសាសន៍ធម្មតា និង (២.២.២.២) ទម្រង់នៃមតកសាសន៍ពិសេស ។

#### ២.២.២.១.ទម្រង់នៃមតកសាសន៍ធម្មតា

**ក.មតកសាសន៍ដោយលិខិតយថាភូត** ( **មាត្រា១១៧៣** )

មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើង រវាងម្ចាស់បណ្តាំ(មតកជន) នៅចំពោះមុខសារការី ។ សារការីមានតួនាទីថែរក្សាលិខិតមតកសាសន៍នោះ ដោយតាមស្មារតីនៃមតកជន ។ ទម្រង់នៃមតកសាសន៍ ត្រូវគោរពតាមលក្ខខណ្ឌដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ទើបធ្វើឲ្យទម្រង់នេះមានសុពលភាពគតិយុត្តិ ។ ហើយទម្រង់នេះត្រូវបានកណត់ដូចខាងក្រោមៈ

- ត្រូវមានសាក្សីយ៉ាងតិច ២(ពីរ) នាក់។
- ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ ។
- បន្ទាប់ពីម្ចាស់បណ្តាំស្តាប់ និងសាក្សីបានទទួលស្គាល់ថា ការកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗត្រូវធ្វើឲ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមហេតុនោះផង ។
- សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**ខ.មតកសាសន៍ដោយលិខិតសម្ងាត់** ( **មាត្រា១១៧៥** )

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ

- ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

- ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមសំបុត្របិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសម្គាល់ ឬមធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។
- ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី ២(ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ ។
- សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ ។

**គ.មតកសាសន៍ដោយលិខិតឯកជន** (**មាត្រា១១៧៤**)

មតកសាសន៍ដោយលិខតឯកជន គឺជាលិខិតមួយដែលស្ថិតក្នុងចំណោមទម្រង់មតកសាសន៍ធម្មតាខាងលើដែរ ក៏ប៉ុន្តែលក្ខខ័ណ្ឌនៃលិខិតនេះ ខុសពីលិខិតទាំងពីរដែលបានបកស្រាយខាងលើ។ ម្ចាស់បណ្តាំ គឺជាអ្នកធ្វើលិខិតនេះដោយផ្ទាល់ខ្លួនឯង ហើយម្ចាស់បណ្តាំត្រូវសរសេរពាក្យពេចន៍ ឃ្លោងឃ្លាទាំងអស់ ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាខាងលើលិខិតនោះដោយខ្លួនឯង។ នៅក្នុងករណីដែលមតកសាសន៍ដោយលិខិតឯកជននេះ ត្រូវបានសរសេរដោយអ្នកផ្សេង ក្រៅពីសមីខ្លួន ឬ ដោយប្រើឧបករណ៍ទំនើបកម្ម ដែលមានដូចជា កុំព្យូទ័រ ទូរស័ព្ទ ជាអាទិ៍ លិខិតនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

ម្យ៉ាងវិញទៀត ក្នុងករណីមានការសង្ស័យអំពីភាពមិនពិតប្រាកដនៃលិខិតមតកសាសន៍របស់ម្ចាស់បណ្តាំដោយសន្តតិជន ឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ។ ក្នុងករណីនេះអ្នកដែលមានសិទ្ធិក្នុងការអនុវត្តន៍នៃលិខិត ព្រមទាំងបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចធ្វើការផ្ទៀងផ្ទាត់ចំពោះអក្សរដែលបានសរសេរនៅក្នុងលិខិតមតកសាសន៍ ជាមួយនឹងអក្សរដែលម្ចាស់បណ្តាំបានសរសេរនៅក្នុងអត្ថបទផ្សេងទៀត ដើម្បីបញ្ជាក់អំពីភាពពិត ឬមិនពិតប្រាកដនៃលិខិតមតកសាសន៍នោះ ។

នៅក្នុងករណីមានការបន្ថែមពាក្យពេចន៍ ការលុប ឬការកែប្រែផ្សេងៗទៀតនៅក្នុងមតកសាសន៍លិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនអាចបង្ហាញនៅកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខា ។

### ២.២.២.២.ទម្រង់នៃមតកសាសន៍ពិសេស

#### ក.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ( មាត្រា១១៧៦ )

តាមស្មារតីនៃក្រមរដ្ឋប្បវេណី យើងបានដឹងមកហើយពីជនដែលត្រូវបានកម្រិតសមត្ថភាព ដែលក្នុងនោះមានជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។ ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ[23]។ ជននេះដែលផ្អែកតាមក្រមរដ្ឋប្បវេណី គឺមានសិទ្ធិក្នុងការបង្កើតឲ្យមាននូវបណ្តាំបានដោយមានលក្ខខ័ណ្ឌ ដូចខាងក្រោម ៖

- ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២(ពីរ) នាក់។
- វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

#### ខ.មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (មាត្រា ១១៧៧)

ចំពោះជនដែលជាមតកជន ដែលជួបប្រទះនូវគ្រោះថ្នាក់បន្ទាន់ ដោយសារតែជម្ងឺ ឬដោយហេតុផ្សេងទៀត ដែលអាចនឹងប៉ះពាល់ដល់អាយុជីវិត ។ ក្នុងករណីនេះសាមីជន ក៏អាចជ្រើសរើសដោយធ្វើតាមលិខិតយថាភូត ដោយធ្វើចំពោះមុខសារការីបាន ប្រសិនបើមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើ។ ដោយឡែកប្រសិនបើបុគ្គលនោះគ្មានសមត្ថភាព ឬគ្មានពេលវេលាសម្រាប់ធ្វើដោយសារតែជម្ងឺ ធ្ងន់ធ្ងរ ឬដោយប្រធានសក្តិក្តី បុគ្គលនោះអាចធ្វើមតកសាសន៍តាមដោយប្រាប់ដោយផ្ទាល់មាត់បាន នៅចំពោះមុខបុគ្គលដែលមានវត្តមាននៅទីនោះ ហើយចំណែកលក្ខខ័ណ្ឌលម្អិតនឹងមានការបញ្ជាក់ដូចខាងក្រោម ៖

- ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត ដោយសារជម្ងឺ ឬហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឲ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវ

[23] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ២៥

សរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឲ្យសាក្សីស្តាប់ ឬ ឲ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ ។

- មតកសាសន៍ដែលបានធ្វើឡើងតាមចំណុចខាងលើ នឹងមិនមានអានុភាពឡើយ ប្រសិនបើសាក្សីណាម្នាក់ ឬបុគ្គលណាម្នាក់ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១(មួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយពុំបានទទួលបញ្ជាក់ទេនោះ។
- តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**គ.មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ ( មាត្រា ១៧៧៨ )**

បុគ្គលម្នាក់ដែលត្រូវបានជាប់ឃុំឃាំង ប្រាកដណាស់ថាអាចនឹងមានសេរីភាព ឬក៏មិនអាចមានសេរីភាពទៅតាមកម្រិតនៃការជាប់ឃុំឃាំង។ ពាក្យថាជាប់ឃុំឃាំង ក្នុងនេះគឺសម្តៅទៅដល់ការជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬសាលដីកា ឬដោយសារការចាត់ចែងផ្នែករដ្ឋបាល និងសម្តៅទៅដល់បុគ្គលដែលនៅក្នុងនាវា ឬយន្តនហោះជាដើម ។ ប្រសិនបើបុគ្គលនេះមានគំនិតចង់បង្កើតឲ្យមាននូវបណ្តាំ អាចមានសិទ្ធិធ្វើទៅបាន ដោយធ្វើទៅតាមលក្ខខណ្ឌខុសពីទម្រង់មតកសាសន៍នានា ដែលបានរៀបរាប់ខាងលើដោយយើងនឹងធ្វើការសិក្សាលក្ខខ័ណ្ឌដូចតទៅ ៖

- បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬសាលដីកា ឬដោយការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បានដោយត្រូវឲ្យមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សី យ៉ាងតិច ២(ពីរ) នាក់ ។
- បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឲ្យមានមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ ម្នាក់ និងសាក្សីយ៉ាងតិច ២(ពីរ)នាក់ ។
- មតកសាសន៍ដែលបានកំណត់ក្នុងចំណុច ទាំងពីរខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បានដោយផ្ទាល់មាត់ ចំពោះបុគ្គលដែលបានរៀបរាប់ទាំងពីរចំណុចខាងលើបាន ។
- ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ ចំពោះ នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ ។
- ប៉ុន្តែ មតកសាសន៍ដែលធ្វើឡើងតាម បួនចំណុចខាងលើនេះពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ)ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែជាអាចធ្វើមតក

សាសន៍ តាមទម្រង់ណាមួយនៃ ទម្រង់នៃមតកសាសន៍ធម្មតាទាំងបី ក្រោយពេលដែលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**ឃ. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍** ( **មាត្រា ១១៧៩** )

ក្នុងករណីដែលរូបវន្តបុគ្គលម្នាក់ពុំអាចនិយាយបាន តើបុគ្គលម្នាក់នោះមានសិទ្ធិ ធ្វើមតកសាសន៍បានដែរឬទេ?

ចម្លើយនោះគឺអាចធ្វើបាន ដោយមូលហេតុច្បាប់ក៏បានចងជាប់បុគ្គលដែលពុំមានលទ្ធភាពក្នុងការនិយាយមានសិទ្ធិក្នុងការបង្កើតឲ្យមាននូវមតកសាសន៍បានដែរ តែក៏តម្រូវឲ្យមានលក្ខខ័ណ្ឌក្នុងការបង្កើតផងដែរ។ ដើម្បីឲ្យកាន់តែច្បាស់ថាតើបុគ្គលដែលពុំមានលទ្ធភាពក្នុងការនិយាយអាចធ្វើមតកសាសន៍បាន យ៉ាងដូចម្តេច យើងនឹងធ្វើការសិក្សាទៅលើលក្ខខ័ណ្ឌដូចតទៅៈ

នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងច្បាប់ មតកសាសន៍ដោយលិខិតយថាភូត លិខិតសម្ងាត់ និងមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ម្ចាស់បណ្តាំអាចជំនួសការប្រាប់បានដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃផ្ទាល់ នៅចំពោះមុខសារការី ឬសាក្សី ។

ក្នុងករណីដែលសារការី ឬបុគ្គលផ្សេងទៀតដែលបានកំណត់ ត្រូវអានឲ្យម្ចាស់បណ្តាំ ឬសាក្សីស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលដែលបានសរសេរលាយលក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និងសាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬបុគ្គលដែលបានកំណត់ អាចជំនួសការអានឲ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះតាមការបកប្រែរបស់អ្នកបកប្រែទៅម្ចាស់បណ្តាំ ឬសាក្សី ។ នៅក្នុងករណីដែលបានបកស្រាយខាងលើនេះ សារការី ឬបុគ្គលផ្សេងទៀតដែលបានកំណត់ ត្រូវសរសេរអំពីហេតុចូលទៅក្នុងលិខិតនោះ។

**ខ.មតកសាសន៍ចំពោះជនជាតិខ្មែរដែលរស់នៅបរទេស** ( **មាត្រា ១១៨១** )

ក្នុងករណីនេះប្រសិនបើជនជាតិខ្មែរណាម្នាក់ដែលបានរស់នៅឯក្រៅប្រទេស មានបំណងចង់បង្កើតនូវមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិតសម្ងាត់ បុគ្គលនោះអាចធ្វើទៅបានដោយគ្រាន់តែទៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះនឹងដើរតួនាទីជំនួសឲ្យសារការី ។

- **កំណត់សម្គាល់៖** ក្នុងករណីដែលសារការី និងសាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សីគ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និងផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។[24]

## ២.៣.ខ្លឹមសារនៃមតកសាសន៍

### ២.៣.១.សន្តតិជន

នៅក្នុងខ្លឹមសារនៃមតកសាសន៍ចាំបាច់ណាស់ត្រូវមានសន្តតិជន ពីព្រោះសន្តតិជនជាភាគីម្ខាង នៃមតកសាសន៍ទាំងមូល ។

បុគ្គលដែលសន្មត់ថាជាសន្តតិជននឹងត្រូវក្លាយទៅជា អ្នកមានសិទ្ធិទទួលបន្តនូវទ្រព្យសម្បត្តិ ពីមតកជន ។ សម្រាប់សន្តតិកម្មតាមមតកសាសន៍ ម្ចាស់បណ្តាំ អាចបង្ហាញឆន្ទៈតាមរយៈលិខិតមតកសាសន៍របស់ខ្លួន ក្នុងការកំណត់បុគ្គលដែលនឹងទទួលបានទ្រព្យ ទោះបីជាបុគ្គលនោះមិនមែនជាជនដែលត្រូវបានកំណត់ក្នុងច្បាប់ថា ជាជនដែលមានសិទ្ធិក្លាយទៅជាសន្តតិជនក៏ដោយ ។ តែទោះជាយ៉ាងនេះក្តី ការកំណត់ចំពោះបុគ្គលដែលនឹងត្រូវក្លាយជាសន្តតិជនតាមរយៈឆន្ទៈរបស់ម្ចាស់បណ្តាំ គឺមិនត្រូវឲ្យផ្ទុយពីប្បញ្ញត្តិនៃភាគបម្រុងឡើយ ។ ប្បញ្ញត្តិស្តីពីភាគបម្រុង នឹងធ្វើការសិក្សានៅក្នុងចំណុចទៅមុខទៀត ‹‹‹**ស្តីពីភាគបម្រុង**›››។

ចំពោះករណីដែលអ្នកមានសិទ្ធិ និងមិនមានសិទ្ធិ ក្លាយទៅជាសន្តតិជន យើងក្រឡេកទៅមើលចំណុច (១.៦) បុគ្គលដែលមាន និង ពុំមានសមត្ថភាពទទួលសិទ្ធិ ។

- **កំណត់ចំណាំ ៖** បើយើងបកទៅសិក្សានៅចំណុច (១.៦) វិញ ហើយយើងមើលទៅលើ (១.៦.២) ជនដែលផ្តាច់ចេញពីសន្តតិជន ក្នុងករណីនេះ មតកជន កាលនៅរស់អាចដាក់ពាក្យសុំទៅតុលាការលុបចោល នៅការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជននៅពេលណាក៏បាន ។[25]

### ២.៣.២.ការកំណត់ចំណែកមត៌ក

មតកជនអាចកំណត់ចំណែកមត៌ក របស់សហសន្តតិជនតាមមតកសាសន៍ ឬអាចបង្ហាញឆន្ទៈផ្ទុយពីប្បញ្ញត្តិ ស្តីពីចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមប្បញ្ញត្តិស្តីពីភាគបម្រុង ។[26]

[24] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨០
[25] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៤
[26] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨២ កថាខណ្ឌទី ១

បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមប្បញ្ញត្តិស្តីពីការសម្រួលមត៌ក ។[27]

### ២.៣.៣.ការកំណត់នូវវិធីបែងចែកមត៌ក

មតកជន អាចកំណត់នូវវិធីបែងចែងតាមមតកសាសន៍ ឬអាចប្រគល់អាណត្តិឲ្យតតិយជនកំណត់វិធីនេះ ។[28] មតកជន អាចបង្ហាញឆន្ទៈរបស់ខ្លួននៅក្នុងខ្លឹមសារនៃមតកសាសន៍បានដោយខ្លួនឯងដោយកំណត់ពីការប្រគល់នូវមត៌ក ដោយសន្តតិជនម្នាក់ដែលទទួលបានគ្រប់យ៉ាង ឬមានសហសន្តតិជន ទទួលបានចំណែកដែលមតកជនធ្វើការបែងចែកទៅតាមឆន្ទៈរបស់ខ្លួន ។ ម្យ៉ាងវិញទៀតប្រសិនបើមតកជនមិនអាចធ្វើការបែងចែកបានដោយខ្លួនឯងនោះទេ មតកជនអាចបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍បាន ដើម្បីប្រគល់អាណត្តិឲ្យទៅតតិយជនជាអ្នកកំណត់អំពីវិធីបែងចែក ចំពោះមត៌កដែលត្រូវប្រគល់ឲ្យទៅសន្តតិជនបាន ។ ដូច្នេះ បុគ្គលដែលត្រូវបានប្រគល់ដោយមតកជន ជាអ្នកកំណត់វិធីបែងចែក ត្រូវអនុវត្តឲ្យបានត្រឹមត្រូវទៅតាមការបង្ហាញឆន្ទៈរបស់មតកជននៅក្នុងមតកសាសន៍ ។ ក្រៅពីនេះមតកជនក៏អាចធ្វើអនុប្បទាននូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក ឬធ្វើប្រទានកម្ម ឬអច្ច័យទានតាមមតកសាសន៍ ឱ្យទៅជនដែលត្រូវបានសន្មត់ថាជាសន្តតិជន ឬតតិយជនបានផងដែរ ។ ម្យ៉ាងវិញទៀត បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើនឲ្យទៅសន្តតិជនតែម្នាក់ ឬច្រើននាក់ មតកសាសន៍នោះត្រូវបានសន្មត់ថាជាការកំណត់នូវវិធីនៃការបែងចែកមត៌ក ។ លើកលែងតែមតកសាសន៍នោះ មានអត្ថប្រយោជន៍ជាអច្ច័យទានច្បាស់លាស់ ដូចជា អច្ច័យទានភ្ជាប់បន្ទុក ជាអាទិ៍ ហើយតម្លៃនៃទ្រព្យសម្បត្តិនោះមានចំនួនលើសចំណែកមត៌ករបស់សហសន្តតិជន គឺត្រូវចាត់ទុកថាបានកំណត់នូវចំណែកមត៌កផងដែរ ។ លើសពីនេះទៅទៀត បើមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យនោះមានចំនួនតិចជាចំណែកមត៌កដែលសន្តតិជននោះត្រូវទទួលខុសត្រូវ លុះត្រាតែពុំមានការកំណត់ផ្សេងនៅក្នុងមតកសាសន៍នោះ ត្រូវសន្មត់ថាកំណត់វិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។[29]

---

27 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨២ កថាខណ្ឌទី ២

28 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨៣

29 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨៥

### ២.៣.៤.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

នៅក្នុងខ្លឹមសារនៃមតកសាសន៍ ម្ចាស់បណ្ដាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់ ឬ អាចប្រគល់អាណត្តិឲ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះតាមមតកសាសន៍បាន។[30] ក្នុងករណីដែលកូនមិន ទាន់គ្រប់អាយុជានីតិជន អាចធ្វើទៅបានចំពោះការប្រគល់អណត្តិឲ្យឪពុកមារបស់សន្តតិជនធ្វើការកំណត់បែង ចែកមត៌ក ។ ប៉ុន្តែ ការប្រគល់អាណត្តិឲ្យទៅសន្តតិជនមិនត្រូវបានអនុញ្ញាតឡើយ ។ ការកំណត់អ្នកប្រតិបត្តិ មតកសាសន៍នេះ នឹងបកស្រាយនៅចំណុច ដែលនឹងសិក្សាពី «**ការប្រតិបត្តិមតកសាសន៍**» ។

### ២.៣.៥.ករណីមតកជនហាមមិនឲ្យបែងចែកក្នុងរយៈពេលកំណត់

នៅក្នុងករណីមតកជនហាមឃាត់មិនឲ្យបែងចែកក្នុងរយៈពេលកំណត់នេះ គឺជាឆន្ទៈរបស់ម្ចាស់ទ្រព្យ ដែលហាមឃាត់ចំពោះការបែងចែកមត៌ក នៅក្នុងអំឡុងពេលដែលកំណត់មួយ ។ តាមរយៈក្រមរដ្ឋប្បវេណី មតក ជនអាចហាមឃាត់ចំពោះការបែងចែកមត៌កនៅក្នុងអំឡុងពេលដែលមិនលើស ៥(ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែល ចាប់ផ្ដើមសន្តតិកម្មនោះបាន ។[31]

## ២.៤.អានុភាពនៃមតកសាសន៍

ជាគោលការណ៍ មតកសាសន៍មួយ អាចមានអានុភាពអនុវត្តបាន លុះត្រាតែមតកសាសន៍នោះ បាន បំពេញគ្រប់លក្ខខណ្ឌដូច ដែលបានបកស្រាយខាងលើ ។

### ២.៤.១.អានុភាពនៃមតកសាសន៍ក្នុងករណីមានលក្ខខណ្ឌបង្អង់

តាមប្បញ្ញត្តិច្បាប់ មតកសាសន៍មានអានុភាពនៅពេលម្ចាស់បណ្ដាំបានទទួលមរណភាពហើយមតក សាសន៍ជាឆន្ទៈរបស់ម្ចាស់បណ្ដាំក្នុងការសម្រេចនូវកម្មសិទ្ធិទ្រព្យសម្បត្តិ ក្រោយពេលដែលខ្លួនទទួលមរណភាព ហេតុនេះ ប្រសិនបើមតកសាសន៍នោះមានលក្ខខណ្ឌបង្អង់ លុះត្រាតែលក្ខខណ្ឌនោះត្រូវបានបំពេញទើបមតក សាសន៍មានអានុភាព ។[32]

ឧទាហរណ៍ ៖ អច្ច័យលាភីបានទទួលអច្ច័យទានភ្ជាប់បន្ទុក ដែលបានកំណត់នៅក្នុងមតកសាសន៍មាន ខ្លឹមសារថា អច្ច័យទាននេះអាចប្រគល់បាន លុះត្រាតែអច្ច័យលាភីបានចម្រើនអាយុពេញវ័យ ជាមុនសិន បើមិន អនុវត្តតាមលក្ខខណ្ឌនេះទេ អច្ច័យលាភីមិនអាចទទួលមត៌ករបស់ខ្លួនបានឡើយ ។

---

[30] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨៦

[31] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨៣

[32] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៤

### ២.៤.២.អានុភាពនៃការកំណត់ចំណែកមត៌ក

បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់មួយ ឬច្រើនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមរយៈមតកសាសន៍ ទ្រព្យនោះនឹងធ្លាក់ទៅលើសន្តតិជនដែលនឹងត្រូវទទួលទ្រព្យនោះដោយស្វ័យប្រវត្តិ នៅពេលមតកសាសន៍បង្កើតអានុភាព ។ នៅក្នុងករណីនេះ មានការកំណត់វិធីបែងចែកមត៌កតាមមតកសាសន៍ ហេតុនេះមត៌កត្រូវបែងចែកតាមវិធីដែលបានកំណត់នោះ ដោយមិនចាំបាច់ឆ្លងការពិភាក្សាដោយសហសន្តតិជនឡើយ ។

#### ២.៤.២.១.មរណភាពរបស់ជនដែលត្រូវបានសន្មត់ថាជាសន្តតិជន

ក្នុងករណីជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម អានុភាពនៃការកំណត់ចំណែកមត៌ករបស់សន្តតិជន ឬការកំណត់នូវវិធីបែងចែកមត៌កតាមរយៈមតកសាសន៍ និងមានអានុភាពចំពោះសន្តតិជនជំនួស លើកលែងតែសន្តតិជនបោះបង់សន្តតិកម្ម ឬមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ឬគ្មានសន្តតិកម្មជំនួស ។ ក្នុងករណីនេះ ត្រូវបានកំណត់ដូចគ្នាចំពោះ ជនដែលត្រូវបានសន្មត់ថាជាសន្តតិជន ដែលបានបាត់បង់សិទ្ធិសន្តតិកម្ម ដូចបានកំណត់នៅក្នុងករណីជនដែលជាអភ័ព្វបុគ្គនៃសន្តតិកម្ម ឬដោយការកាត់កាលសន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។[33]

ដោយឡែកប្រសិនបើជនដែលជាសន្តតិជនដែលទទួលមរណភាព គ្មានសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបានបង្កើតអានុភាពឡើយ ។[34] យ៉ាងណាមិញប្រសិនបើមតកជនបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។[35]

#### ២.៤.២.២.ការកម្រិតនូវមតកសាសន៍ចំពោះអ្នកអាណាព្យាបាល

នៅមុនពេលបញ្ចប់ការគណនាចំណូលចំណាយក្នុងកិច្ចការឲ្យអាណាព្យាបាល បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ដែលជាប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬអ្នកដែលនៅជុំវិញខ្លួនរបស់អ្នកអាណាព្យាបាល នោះត្រូវចាត់ទុកមតកសាសន៍នោះជាមោឃៈ ។ មូលហេតុដោយសារតែ មានការបារម្ភថា អ្នកអាណាព្យាបាលអាចប្រើល្បិចបោកប្រាស់ជននៅក្រោមអាណាព្យាបាលទូទៅ ឲ្យធ្វើមតកសាសន៍ដើម្បីជាផលប្រយោជន៍សម្រាប់ខ្លួន និងអ្នកដែលនៅជុំវិញខ្លួន ។ ប៉ុន្តែ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ

[33] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៦ កថាខណ្ឌទី ១

[34] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៦ កថាខណ្ឌទី ២

[35] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៦ កថាខណ្ឌទី ៣

ជាញាតិលោហិតខ្សែផ្ទាល់ សហព័ទ្ធ ឬបងប្អូនបង្កើតរបស់ជននៅក្រោមអាណាព្យាបាលទូទៅ នោះប្បញ្ញត្តិខាងលើនឹងមិនត្រូវយកមកអនុវត្តឡើយ មានន័យថា មតកសាសន៍នោះមិនត្រូវចាត់ទុកជាមោឃៈឡើយ ដោយសារតែមតកសាសន៍នោះបង្កើតឡើងដើម្បីជាផលប្រយោជន៍សម្រាប់អ្នកទាំងនោះជាស្រេចរួចហើយ ។[36] ដូច្នេះ ការធ្វើមតកសាសន៍បែបនេះ នឹងមានសុពលភាពតាមផ្លូវច្បាប់ ។

**២.៤.២.៣.សិទ្ធិទទួលនូវទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានត្រូវបានមោឃភាព**

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ ពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ២.៥.អច្ច័យទាន

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍ ។

### ២.៥.១.អច្ច័យទានសកល និងអច្ច័យទានមានកំណត់

- អច្ច័យទានសកល ៖ គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់តាមភាគនៃទ្រព្យ (ទាំងអស់ , ពាក់កណ្តាល , មួយភាគបី... ជាអាទិ៍ )[37]

  **ឧទាហរណ៍ ៖** មត៌កសរុបមាន ផ្ទះ (តម្លៃ ៥0.000 ដុល្លារ) , ឡាន (តម្លៃ ១0.000) និងប្រាក់សុទ្ធចំនួន ២0.000 ដុល្លារ ។ នៅក្នុងមតកសាសន៍របស់ម្ចាស់បណ្តាំ បានសរសេរថា ឲ្យទ្រព្យសម្បត្តិមួយភាគបី នៃមត៌កទាំងអស់ធ្វើជាអច្ច័យទានទៅឲ្យអច្ច័យលាភី ។ ប្រភេទនេះហៅថា **អច្ច័យទានសកល** ។

- **អច្ច័យទានមានកំណត់** ៖ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ដោយមត៌កសាសន៍ ។[38]

---

[36] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៧

[37] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៩

[38] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៩

**ឧទាហរណ៍ ៖** មត៌កសរុបមាន ផ្ទះ (តម្លៃ ៥០.០០០ ដុល្លារ) , ឡាន (តម្លៃ ១០.០០០) និងប្រាក់សុទ្ធចំនួន ២០.០០០ ដុល្លារ ។ នៅក្នុងមតកសាសន៍ មានខ្លឹមសារថា ប្រគល់ផ្ទះ (តម្លៃ ៥០.០០០ ដុល្លារ) ធ្វើជាអច្ច័យទានទៅអច្ច័យលាភី ។ ប្រភេទនេះហៅថា អច្ច័យទានមានកំណត់ ។

### ២.៥.២.សកម្មភាពឯកតោភាគី

អច្ច័យទាន គឺជាសកម្មភាពឯកតោភាគីដែលធ្វើឡើងដោយម្ចាស់បណ្ដាំ សំដែងឆន្ទៈធ្វើអនុប្បទានទ្រព្យសម្បត្តិមួយផ្នែក ឬ ទាំងអស់ទៅឲ្យអច្ច័យលាភី ដែលវាខុសពីប្រទានកម្ម គឺធ្វើឡើងរវាងទាយក និង បដិគ្គាហកតាមរយៈកិច្ចសន្យា ។ បញ្ញត្តិនៃអច្ច័យទានត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព (មាត្រា៥៧៧) ។ ប៉ុន្តែបញ្ញត្តិដែលទាក់ទងនឹងសមត្ថភាព ទម្រង់ការយល់ព្រម និងការលះបង់អច្ច័យទានដែលជាបញ្ញត្តិត្រូវបានរៀបចំដោយសារលក្ខណៈជាសកម្មភាពឯកតោភាគីនៃអច្ច័យទានមិនត្រូវយកមកអនុវត្តឡើយ ។

### ២.៥.៣.អានុភាពនៃអច្ច័យទាន

អច្ច័យទាននឹងបង្កើតអានុភាព នៅពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ។ ប៉ុន្តែក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះ ត្រូវបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះត្រូវមានអានុភាពចាប់ពីពេលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ ។[39]

**ឧទាហរណ៍១ ៖** ម្ចាស់បណ្ដាំបានធ្វើអច្ច័យទានកំណត់ ផ្ទះ (តម្លៃ ៥០.០០០ដុល្លារ) ទៅឲ្យអច្ច័យលាភី ។ ក្នុងករណីនេះ មានកម្មវត្ថុជាក់លាក់មួយនៃអច្ច័យទាន អច្ច័យលាភីនឹងទទួលបានលទ្ធកម្មកម្មសិទ្ធិលើកម្មវត្ថុនោះ នៅពេលមរណភាពរបស់ម្ចាស់បណ្ដាំ ដោយមិនចាំបាច់ចុះបញ្ជីទេ ។

**ឧទាហរណ៍២ ៖** ម្ចាស់បណ្ដាំបានធ្វើអច្ច័យទានកំណត់ ផ្ទះ (តម្លៃ ៥០.០០០ដុល្លារ) ទៅឲ្យអច្ច័យលាភីនៅពេលដែលអច្ច័យលាភីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រច្បាប់នៅមហាវិទ្យាល័យ ។ ចំពោះករណីនេះអានុភាពនៃមតកសាសន៍នឹងកើតឡើងនៅពេលបានបញ្ចប់បរិញ្ញាប័ត្រច្បាប់នៅមហាវិទ្យាល័យ ក្រោយពេលម្ចាស់បណ្ដាំទទួលមរណភាព ។ ក្នុងករណីនេះ អាចសន្និដ្ឋានថា អច្ច័យលាភី បានទទួលលទ្ធកម្មកម្មសិទ្ធិដែលមានជាប់លក្ខខណ្ឌ នៅពេលមរណភាពរបស់ម្ចាស់បណ្ដាំ ។

សំណួរសួរថា តើវាមានជាប់លក្ខខ័ណ្ឌបង្អង់ទៀតទេ ប្រសិនបើអច្ច័យលាភីបានបញ្ចប់បរិញ្ញាប័ត្រច្បាប់មុនពេលម្ចាស់បណ្ដាំទទួលមរណភាព ?

[39] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៤ កថាខណ្ឌទី ២

លក្ខខ័ណ្ឌបង្អង់នោះ បានសម្រេចមុនពេលម្ចាស់បណ្តាំទទួលមរណភាព ហេតុនេះហើយបកស្រាយថា គ្មានជាប់នូវលក្ខខ័ណ្ឌ ។

**២.៥.៤.មរណភាពរបស់អច្ច័យលាភី**

អច្ច័យទានពុំទាន់មានអានុភាព បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។[40] ចំពោះចំណុចនេះ បច្ចាញាតិផ្ទាល់ ជាអាទិ៍របស់អច្ច័យលាភីមិនអាចទទួលអច្ច័យទានជំនួសបានឡើយ ដោយសារតែ ធម្មតាអច្ច័យទានត្រូវបានធ្វើឡើងដោយផ្តោតទៅលើទំនាក់ទំនងផ្ទាល់ខ្លួនរវាងម្ចាស់បណ្តាំ និងអច្ច័យលាភី ។

បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយលក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាពនៅមុនពេលដែលលក្ខខ័ណ្ឌនេះត្រូវបានបំពេញ ។

ផ្ទុយទៅវិញ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

ប៉ុន្តែកថាខណ្ឌទី៣ ជាករណីលើកលែងមួយ ដែលសន្តតិជនត្រូវបានសន្មតជាអច្ច័យលាភី ហើយសន្តតិជននោះបានទទួលមរណភាព ត្រូវចាត់ទុកថាជាការកំណត់ចំពោះជនដែលធ្វើសន្តតិកម្មជំនួសបុគ្គលនោះដោយយោងតាមមាត្រា ១១៩៦ និង មាត្រា ១២០០-៣ ។

**ឧទាហរណ៍ ៖** ក្នុងមត៌កសរុបមាន ផ្ទះ ឡាន ប្រាក់ និងបំណុល ។ ម្ចាស់បណ្តាំបានសរសេរក្នុងមតកសាសន៍ថា ធ្វើអច្ច័យទានផ្ទះឱ្យអច្ច័យលាភី (ជាតតិយជន) ។ក្រោយមកអច្ច័យលាភីនោះ បានទទួលមរណភាពមុនពេលម្ចាស់បណ្តាំ ។ ដូចនេះ អច្ច័យទានពុំបង្កើតអានុភាពឡើយ ។

ប្រសិនបើ អច្ច័យទាននេះភ្ជាប់នូវលក្ខខ័ណ្ឌបង្អង់ ដោយតម្រូវឲ្យអច្ច័យលាភីបញ្ចប់ថ្នាក់បរិញ្ញាប័ត្រច្បាប់ ដូចនេះទោះបីជាម្ចាស់បណ្តាំបានទទួលមរណភាព ហើយក្រោយមកអច្ច័យលាភីនោះទទួលមរណភាពនៅមុនពេលដែលលក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។ ដូចនេះអច្ច័យទានពុំបង្កើតអានុភាពឡើយ ។

ប្រសិនបើ សន្តតិជនដែលត្រូវបានសន្មតជាអច្ច័យលាភី នោះទទួលមរណភាពមុនពេលម្ចាស់បណ្តាំ នោះមានន័យថា អច្ច័យទានពុំបង្កើតអានុភាពឡើយ ប៉ុន្តែមិនរារាំងចំពោះសន្តតិកម្មជំនួសដែលសន្តតិជនជំនួសត្រូវទទួលបានមត៌ក (មាត្រា ១១៩៦ និងមាត្រា ១២០០-៣) ។

លើសពីនេះទៅទៀត ប្រសិនបើអច្ច័យលាភី ជាអភ័ព្វបុគ្គល (មាត្រា១១៥០) ឬ ប្រសិនបើអច្ច័យលាភីបានទទួលមរណភាព (មាត្រា១២០០) អានុភាពនៃអច្ច័យទានមិនកើតឡើងទេ ។ ហេតុផ្សេងទៀតមានដូចជា

[40] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០០

ការបោះបង់អច្ច័យទាន ដោយអច្ច័យលាភី (មាត្រា១២០១) ហើយក្នុងករណីនេះ អានុភាពនៃអច្ច័យទានក៏មិនកើតឡើងដែរ ។ ដូចនេះ ទ្រព្យសម្បត្តិដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅលើសន្តតិជន ។

**ឧទាហរណ៍ ៖** មតកជនបានធ្វើអច្ច័យទានជាសកល ឲ្យទៅ ក និង ខ ម្នាក់ ១/៣ (ក និង ខ ជាតតិយជន) នៃទ្រព្យសរុប ។ ក្រោយមក ក បានទទួលមរណភាព នៅពេលចាប់ផ្តើមសន្តតិកម្ម ដូចនេះ ករណី ក ពុំមានអច្ច័យទានជំនួស ហើយចំណែករបស់ ក ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិដោយសន្តតិជនតាមផ្លូវច្បាប់ ចំណែក ខ បានទទួល ១/៣ ដែលជាមត៌កនៃអច្ច័យទាន ។

ប្រសិនបើ ម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ថា ក្នុងករណីអច្ច័យលាភីណាមួយបានទទួលមរណភាពនៅពេលចាប់ផ្តើមសន្តតិកម្ម នោះអច្ច័យលាភីដែលនៅរស់ នឹងទទួលបានអច្ច័យទានទាំងអស់ ។ ដូចនេះករណី ក ទទួលមរណភាពនៅពេលចាប់ផ្តើមសន្តតិកម្ម ខ នឹងទទួលបានចំណែករបស់ ក និងចំណែករបស់ខ្លួន ដែលជាមត៌កនៃអច្ច័យទាន ។

តើនៅពេលណាដែលយើងដឹងថា សន្តតិជនដែលត្រូវបានសន្មតជាអច្ច័យលាភី ឬ អច្ច័យលាភីជាតតិយជន ?

ជាគោលការណ៍ អច្ច័យទានធ្វើឡើងតាមឆន្ទៈរបស់ម្ចាស់បណ្តាំ ដែលបានចែងក្នុងមតកសាសន៍ ។ ដូចនេះដើម្បីដឹងថា សន្តតិជនដែលត្រូវបានសន្មតថាជាអច្ច័យលាភី ឬ អច្ច័យលាភីជាតតិយជន លុះត្រាតែម្ចាស់បណ្តាំបានទទួលមរណភាព ហើយចាប់ផ្តើមនូវការបើកមើលនូវមតកសាសន៍នោះ នឹងនាំឲ្យយើងដឹងថាជននោះ ជាសន្តតិជនដែលត្រូវបានសន្មតជាអច្ច័យលាភី ឬ អច្ច័យលាភីជាតតិយជន ដោយមានឃ្លាបញ្ជាក់យ៉ាងច្បាស់អំពីឈ្មោះអ្នកទទួលបានអច្ច័យទាន និងអំពីប្រភេទនៃអច្ច័យទាន ។

**កំណត់ចំណាំ ៖**

- ម្ចាស់បណ្តាំទទួលមរណភាព
- បើកមតកសាសន៍
- ឃើញឈ្មោះ និងការបញ្ជាក់ ក្នុងមតកសាសន៍ ថាជាអច្ច័យទាន
- ការឃើញឈ្មោះ អាចឲ្យយើងបានកំណត់បានថាបុគ្គលនោះ ជាសន្តតិជនដែលត្រូវបានសន្មតជាអច្ច័យលាភី ឬ អច្ច័យលាភីជាតតិយជន ។

### ២.៥.៥. អច្ច័យទានភ្ជាប់បន្ទុក

មានពេលខ្លះម្ចាស់បណ្តាំចង់ឱ្យអច្ច័យលាភីទទួលខុសត្រូវកាតព្វកិច្ចមួយចំនួន ដែលជាលក្ខខ័ណ្ឌភ្ជាប់បន្ទុកជាមួយអច្ច័យទាន ហើយរំពឹងគិតថាអច្ច័យលាភី និងអនុវត្តបន្ទុកនោះ ។ ប៉ុន្តែនៅក្នុងអច្ច័យទានគ្មានប្បញ្ញត្តិច្បាប់ណាមួយចាប់បង្ខំឲ្យអច្ច័យលាភីត្រូវទទួលយកនូវអច្ច័យទាន ។

### ២.៥.៦.ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

មតកសាសន៍ ជាសកម្មភាពឯកតោភាគី មិនមែនជាកិច្ចសន្យាអញ្ញមញ្ញទេ ហេតុនេះទោះបីជាអច្ច័យលាភីមិនអនុវត្តបន្ទុកនោះក៏ដោយ ក៏មិនអាចលុបបំបាត់នូវឆន្ទៈនៃអច្ច័យទានតាមរយៈការលុបចោលនៃកិច្ចសន្យា ។ ដូចនេះ មាត្រា ១១៩៣ បានចែងថា បើអច្ច័យលាភីពុំបានអនុវត្តករណីកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឲ្យអច្ច័យលាភី នោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនអច្ច័យលាភីនោះ អនុវត្តករណីកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនអច្ច័យលាភីនោះ មិនបានអនុវត្តករណីកិច្ចនៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះ អាចទាមទារទៅតុលាការ ឬ ឲ្យលុបចោលអច្ច័យទាននោះបាន ។

### ២.៥.៧.ការទទួលខុសត្រូវរបស់អច្ច័យលាភីនៅក្នុងអច្ច័យទានជាប់បន្ទុក

ទោះបីជាយ៉ាងណាក៏ដោយជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវរងទទួលខុសត្រូវក្នុងការអនុវត្តករណីកិច្ចដែលខ្លួនទទួលបន្ទុកត្រឹមតែកម្រិត ដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះតែប៉ុណ្ណោះ។[41]

**ឧទាហរណ៍ ៖** នៅក្នុងមតកសាសន៍ ម្ចាស់បណ្តាំបានសរសេរថា ធ្វើអច្ច័យទានលើដីមួយកន្លែងឲ្យ (ក) ប៉ុន្តែ តម្រូវឲ្យ (ក) បង់ប្រាក់ ១០.០០០ ដុល្លារ ទៅធនាគារ នេះគឺជាអច្ច័យទានភ្ជាប់បន្ទុក ។

តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន គឺជាកម្រិតនៃការទទួលខុសត្រូវរបស់អច្ច័យលាភី ដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុកនោះ ។ ចំពោះករណីឧទាហរណ៍ខាងលើ ពេលធ្វើមតកសាសន៍ដែលកម្មវត្ថុនោះ មានតម្លៃ ៣០.០០០ ដុល្លារ ហើយ (ក) តម្រូវបង់ប្រាក់ ១០.០០០ ដុល្លារ ទៅធនាគារ ។

ប៉ុន្តែក្នុងករណីដល់ពេលវេលាដែល (ក) ត្រូវបង់ប្រាក់ទៅធនាគារ ហើយដែលបានធ្វើអច្ច័យទាននោះត្រូវបានគេវាយតម្លៃ ធ្លាក់សល់ត្រឹមតែ ៩.០០០ ដុល្លារតែប៉ុណ្ណោះ ។ ដូចនេះ (ក) បង់ប្រាក់ ៩.០០០ ឲ្យធនាគារ ហើយ (ក) នឹងអាចធ្វើលទ្ធកម្មលើដីនោះបាន ។ ប៉ុន្តែចំពោះករណីប្រាក់ ១.០០០ដុល្លារ ទៀត សម្រាប់បង់ធនាគារ គឺជាការទទួលខុសត្រូវរួមរបស់សន្តតិជនតាមរយៈសន្តតិកម្ម ។

កថាខណ្ឌទី២ ជាប្បញ្ញត្តិចែងអំពីការទទួលខុសត្រូវរបស់អច្ច័យលាភី ចំពោះករណីដែលតម្លៃនៃកម្មវត្ថុនៃអច្ច័យទានដែលភ្ជាប់បន្ទុកត្រូវបានថយចុះ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីកិច្ចដែលខ្លួនត្រូវទទួលបន្ទុកតាមសមាមាត្រនៃភាគដែលថយចុះនោះ ។ ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមត៌កសាសន៍ត្រូវអនុលោមតាមឆន្ទៈនោះ ។

[41] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១១ កថាខណ្ឌទី ១

**ឧទាហរណ៍ ៖** ម្ចាស់បណ្តាំបានធ្វើអច្ច័យទានមានកំណត់ (ផ្ទះ តម្លៃ ៣០.០០០ ដុល្លារ) ដោយតម្រូវឲ្យបង់ប្រាក់ ១០.០០០ ដុល្លារ ជូនធនាគារ ។ សន្តតិជនបានទាមទារកាត់បន្ថយ១០% នៃអច្ច័យទាន ដើម្បីមកបង្គ្រប់ភាគបម្រុង ដូចនេះដែលត្រូវបង់ធនាគារចំនួន ១០.០០០ដុល្លារ នឹងត្រូវកាត់១០% ដល់អច្ច័យលាភីដែរៗ[42]

## ២.៥.៨.ការយល់ព្រម និងការបោះបង់អច្ច័យទាន

### ២.៥.៨.១.ការបោះបង់អច្ច័យទាន

ជាទូទៅ អច្ច័យទានកើតចេញពីឆន្ទៈ និងសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ក្នុងការផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យអច្ច័យលាភី ហើយអានុភាពរបស់វានឹងកើតមានឡើងនៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដោយគ្មានការទាក់ទងនឹងឆន្ទៈរបស់អច្ច័យលាភីឡើយ ។ ទោះបីជាបែបនេះក៏ដោយវាមិនអាចបង្ខំឲ្យអច្ច័យលាភីត្រូវតែទទួលយកវត្ថុ ឬសិទ្ធិ (ទ្រព្យសម្បត្តិ , ប្រាក់បញ្ញើ ,សិទ្ធិលើបំណុល ...) ដែលខ្លួនពុំមានឆន្ទៈក្នុងការទទួលដែរ ព្រោះវាជាគោលការណ៍គោរពនូវសេរីភាពបុគ្គល ។ ដើម្បីការពារនូវសិទ្ធិនេះ (មាត្រា ១២០១) បានបង្ហាញថា នៅក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាននៅពេលណាក៏បាន ។ ប៉ុន្តែចំពោះការបោះបង់អច្ច័យទានជាសកល ត្រូវអនុលោមតាមប្បញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម (មាត្រា១២៤៨) គឺត្រូវដាក់ពាក្យសុំទៅតុលាការ ចំណែកអច្ច័យទានកំណត់វិញ ពុំមានប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពេលវេលាសម្រាប់ការបោះបង់អច្ច័យទាន ឬទម្រង់ឡើយ ។ បន្ទាប់ពីការបោះបង់អច្ច័យទានការបោះបង់នេះត្រូវមានអនុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំទទួលមរណភាព ហើយកម្មវត្ថុនៃទ្រព្យអច្ច័យទានត្រូវធ្លាក់លើសន្តតិជនរបស់មតកជន ចាប់ពីពេលដែលសន្តតិកម្មបានចាប់ផ្តើម (មាត្រា ១១៩៨) ។

### ២.៥.៨.២.ការទទួលស្គាល់ ឬបោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

ក្នុងករណីអច្ច័យលាភី ជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ (មាត្រា ១១៨៥, ១២០៥) ។

**ឧទាហរណ៍ ៖** នៅក្នុងមត៌ករបស់ម្ចាស់បណ្តាំ មានផ្ទះ ប្រាក់ ឡាន និងបំណុល ។ នៅក្នុងមតកសាសន៍ម្ចាស់បណ្តាំ បានបង្ហាញថា បានធ្វើអច្ច័យទានជាកំណត់ នៅផ្ទះឲ្យទៅសន្តតិជនដែលសន្មតជាអច្ច័យលាភី ហើយទ្រព្យដែលនៅសល់ទាំងអស់នោះឲ្យទៅសន្តតិជនបីនាក់ (ម្នាក់ក្នុងចំណោមបីនាកគឺជាអច្ច័យលាភី) ។ ក្នុងករណីនេះអច្ច័យលាភីជាសន្តតិជន មិនអាចបោះបង់សន្តតិកម្ម (ប្រាក់ ឡាន និងបំណុល តាមសមាមាត្រ

[42] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១១ កថាខណ្ឌទី ២

ដែលខ្លួនទទួលបាន) ដោយទទួលយកតែ អច្ច័យទាន (ផ្ទះ) ។ ព្រោះការធ្វើបែបនេះ វាអយុត្តិធម៌ចំពោះសន្តតិជនផ្សេងៗទៀតដែលត្រូវរ៉ាប់រងនៅបំណុល ។

ប៉ុន្តែបើអច្ច័យលាភី ជាសន្តិជនបានទទួលស្គាល់សន្តតិកម្មហើយក៏អច្ច័យលាភីនោះ អាចបោះបង់អច្ច័យទានមានកំណត់បានដែរ ។[43]

#### ២.៥.៨.៣.ការបោះបង់ ឬ ការទទួលស្គាល់ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាពដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។[44] ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ត្រូវអនុលោមតាមឆន្ទៈនោះ ។

#### ២.៥.៨.៤.ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

នៅក្នុងករណីខ្លះ អច្ច័យលាភីពុំបានបង្ហាញឆន្ទៈថា បោះបង់ ឬ ទទួលស្គាល់ទេ ដូចនេះវាធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ជនដទៃផ្សេងទៀត ។ ក្នុងករណីនេះ ជនពាក់ព័ន្ធផលប្រយោជន៍ (ម្ចាស់បំណុល) អាចដាស់តឿនឲ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទាន ដោយកំណត់អំឡុងពេលសមរម្យ (មាត្រា ១២០២) ។ បើសិនជាអច្ច័យលាភីមិនបានបង្ហាញឆន្ទៈចំពោះបុគ្គលដែលមានករណីកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន (សន្តតិជន , អច្ច័យលាភីសកល) នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថាអច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

#### ២.៥.៨.៥.ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

នៅក្នុងលក្ខខ័ណ្ឌនៃការបោះបង់ និងការទទួលស្គាល់ អច្ច័យទានក៏មានការហាមឃាត់ផងដែរ ក្នុងករណីអច្ច័យលាភីបានលុបចោលវិញនូវការទទួលស្គល់ ឬ ការបោះបង់ព្រោះវាអាចជះឥទ្ធិពលដល់ជនដែលពាក់ព័ន្ធ ។[45] ទោះបីជាយ៉ាងណាក៏ដោយ ករណីខ្លះ អច្ច័យលាភីនៅតែអាចលុបចោលការបោះបង់ និងការទទួលស្គាល់អច្ច័យទានដែរ ដោយមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈ ដែលកើតចេញពីការគំរាមគំហែង ឬឆបោកពីបុគ្គលពាក់ព័ន្ធ ។

### ២.៥.៩.អានុភាពនៃអច្ច័យទាន

#### ២.៥.៩.១.អច្ច័យទានមានកំណត់

អនុប្បទានទ្រព្យសម្បត្តិជាក់លាក់ជាកំណត់ណាមួយនៅពេលម្ចាស់បណ្តាំទទួលមរណភាព

[43] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៥ កថាខណ្ឌទី ២
[44] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៣
[45] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៤ កថាខណ្ឌទី ១

ការចុះបញ្ជីគឺមានភាពចាំបាច់ តាមរយៈមាត្រា១៣៤ ។ ប៉ុន្តែមាត្រា១៣៥ មិនត្រូវយកមកអនុវត្តទេពី ព្រោះការចុះបញ្ជីជាលក្ខខ័ណ្ឌអានុភាពនេះ គឺសម្រាប់តែករណីនៃការផ្ទេរកម្មសិទ្ធិ លើអចលនវត្ថុដោយការព្រមព្រៀងតែប៉ុណ្ណោះ រីឯការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយពុំមានការព្រមព្រៀង ការចុះបញ្ជីពុំមែនជាលក្ខខ័ណ្ឌដើម្បីអានុភាពទេ ។ ដូចនេះការបែងចែកមត៌កពុំមែនជាការផ្ទេរកម្មសិទ្ធិ លើអចលនវត្ថុពីមតកជនទៅអច្ច័យលាភីដោយការព្រមព្រៀងទេ ការចុះបញ្ជីពុំមែនជាលក្ខខ័ណ្ឌដើម្បីបង្កើនអានុភាពនៃការផ្ទេរកម្មសិទ្ធិទេ ។

**ក.សិទ្ធិទទួលផលរបស់អច្ច័យលាភី**

ប្រសិនបើគ្មានលក្ខខ័ណ្ឌបង្អង់ណាមួយក្នុងអច្ច័យទានទេ ហើយម្ចាស់បណ្តាំបានទទួលមរណភាពនោះ អច្ច័យលាភី អាចទាមទារឲ្យអនុវត្តអច្ច័យទាន (វត្ថុ ឬសិទ្ធិ) ដែលជាកម្មវត្ថុនៃអច្ច័យទាន ព្រមទាំងផលដែលពាក់ព័ន្ធ ។[46]

**ឧទាហរណ៍ ៖** ម្ចាស់បណ្តាំបានធ្វើអច្ច័យទានជាកំណត់មួយ (ប្រាក់បញ្ញើនៅធនាគាចំនួន ១.០០០.០០០ដុល្លារ) ទៅឱ្យអច្ច័យលាភី ។ បន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព នោះអច្ច័យទាននោះនឹងបង្កើតអានុភាព ហើយអច្ច័លាភី ទទួលបានទាំង ប្រាក់ដើម និងការប្រាក់ ដែលជាផលពីការផ្ញើនៅធនាគារ ។ តែផ្ទុយទៅវិញ បើម្ចាស់បណ្តាំបានសរសេរបន្ថែមក្នុងមតកសាសន៍ថា ផលដែលទទួលបាននេះ ត្រូវឲ្យទៅអង្គការមនុស្សធម៌ ដូចនេះ អច្ច័យលាភីនេះក៏មិនអាច ទទួលផលដែរ (មាត្រា១២០៦) ។

**ខ.អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតក្នុងមត៌ក**

ក្នុងករណីខ្លះ សិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាន ពុំស្ថិតនៅក្នុងមត៌ក នៅពេលម្ចាស់បណ្តាំបានទទួលមរណភាព នោះអច្ច័យទានពុំមានអានុភាពឡើយ ។[47]

**ឧទាហរណ៍ ៖** នៅក្នុងមតកសាសន៍ បានផ្តល់សិទ្ធិទិញរថយន្តក្នុងតម្លៃ ២០.០០០ដុល្លារ ធ្វើជាអច្ច័យទានឲ្យទៅអច្ច័យលាភី ដែលបានថែរក្សាម្ចាស់បណ្តាំកាលពីនៅរស់ ។ នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព មត៌កសរុបមានតែ ១៥.០០០ដុល្លារ ។ ដូចនេះអច្ច័យទាននេះក៏ពុំមានអានុភាពទេ ពីព្រោះ វាពុំមានលក្ខណៈចាប់បង្ខំ ឬ មិនចាំបាច់ឱ្យជនដែលមានករណីកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន (អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជន) ចេញលុយរបស់ខ្លួន ដើម្បីប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ទេ ។ ផ្ទុយទៅវិញបើក្នុងមតកសាសន៍ បានចែងថាឲ្យលក់រថយន្តនោះ ហើយយកប្រាក់ ៥.០០០ដុល្លារ ឲ្យទៅអច្ច័យលាភី ដែលបានថែរក្សាម្ចាស់បណ្តាំកាលពីនៅរស់ នោះមតកសាសន៍នឹងមានសុពលភាព ។

[46] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៦

[47] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៧

**គ.អច្ច័យទាននៃវត្ថុ ឬសិទ្ធិ ដែលត្រូវជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន**

បើវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាន ជារបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឲ្យរលត់សិទ្ធិនោះ ចំពោះជនដែលពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។[48] ក្នុងករណីនេះអច្ច័យលាភីមិនអាចទាមទារឲ្យសន្តតិជន ដែលជាជនមានករណីកិច្ចពាក់ព័ន្ធនឹងអច្ច័យទានឲ្យរលត់សិទ្ធិរបស់តតិយជនឡើយ (បញ្ចាំ ហ៊ីប៉ូតែក....) ។

**ឧទាហរណ៍ ៖** ម្ចាស់បណ្តាំបានធ្វើអច្ច័យទានផ្ទះដែលជាប់សិទ្ធិលើបំណុល (ហ៊ីប៉ូតែកនៅធនាគារ) ឲ្យទៅអច្ច័យលាភី ។ ករណីនេះ អច្ច័យាលាភីមិនអាចទាមទារឲ្យសន្តតិជនធ្វើការរលត់សិទ្ធិនេះបានឡើយ ។ ប៉ុន្តែអច្ច័យលាភីត្រូវរងចាំការដោះស្រាយរបស់សន្តតិជនពាក់ព័ន្ធនឹងសន្តតិកម្មទាំងអស់ជាមុនសិន ។

**ឃ.ឧបាទេសកម្មលើវត្ថុ**

ក្នុងករណីខ្លះម្ចាស់បណ្តាំបានធ្វើអច្ច័យទាននូវវត្ថុមួយទៅឲ្យអច្ច័យលាភី តែជាអកុសលវត្ថុនោះត្រូវបានបំផ្លាញដោយតតិយជន នោះម្ចាស់បណ្តាំអាចទាមទារការប្រាក់សំណងនៃការបំផ្លាញ សន្មតថា សិទ្ធិនោះមកជាកម្មវត្ថុនៃអច្ច័យទាន ។[49]

ចំពោះកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា និងច្របល់គ្នានឹងវត្ថុផ្សេងៗ បើម្ចាស់បណ្តាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និងអចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមរដ្ឋប្បវេណី ត្រូវសន្មតថា ម្ចាស់បណ្តាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**ង.ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល**

ក្នុងករណីម្ចាស់បណ្តាំបានធ្វើអច្ច័យទានសិទ្ធិលើបំណុលដោយការទាមទារផ្ទះ ដែលបានទិញពីអ្នកលក់ទៅឲ្យអច្ច័យលាភី តែម្ចាស់បណ្តាំមិនទាន់ស្លាប់នៅឡើយ ហើយបានទទួលការសងផ្ទះទិញ-លក់នោះ ពីអ្នកលក់ ហើយវត្ថុដែលបានលក់នោះ នៅតែមានក្នុងមត៌ក ដូចនេះ សន្មតថាយកវត្ថុនោះមកជាកម្មវត្ថុនៃអច្ច័យទាន ។[50]

[48] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៨

[49] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២០៩ កថាខណ្ឌទី ១

[50] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១០ កថាខណ្ឌទី ១

ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ត្រូវបានសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកំរិតទឹកប្រាក់ដែលមានក្នុងមត៌ក និងប្រាក់ដែលបានបញ្ចូលក្នុង ប្រាក់បញ្ញើ ក្រោយបានសង ។[51]

**ឧទាហរណ៍ ៖** ម្ចាស់បណ្តាំបានធ្វើអច្ច័យទានសិទ្ធិលើបំណុលដែលមានគោលបំណងសងប្រាក់ ចំនួន ១០.០០០ដុល្លារ ដែលកូនបំណុលជំពាក់ឲ្យអច្ច័យលាភី ។ មុនម្ចាស់បណ្តាំទទួលមរណភាព កូនបំណុលបាន យកប្រាក់ ១០.០០០ដុល្លារ មកសងឲ្យម្ចាស់បណ្តាំវិញ ហើយក្រោយមកម្ចាស់បណ្តាំបានចំណាយទឹកប្រាក់ អស់ ២.០០០ដុល្លារ ។ ដូចនេះទឹកប្រាក់ដែលមានក្នុងមត៌កចំនួន ៨.០០០ដុល្លារ នឹងក្លាយជាកម្មវត្ថុនៃអច្ច័យ ទានសម្រាប់អច្ច័យលាភី (គ្មានប្រាក់បញ្ញើនៅក្នុងធនាគារក្រោយពីបានសងទេ) ។

### ២.៥.៩.២.អច្ច័យទានសកល

- អនុប្បទានទ្រព្យសម្បត្តិនៅពេលម្ចាស់បណ្តាំទទួលមរណភាព ។
- ការចុះបញ្ជីគឺមានភាពចាំបាច់តាមរយៈមាត្រា១៣៤ ។ ប៉ុន្តែមាត្រា១៣៥ មិនត្រូវយកមកអនុវត្ត ទេ ។
- អច្ច័យលាភីសកលមានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងសន្តតិជន (ទទួលយកទាំងទ្រព្យ និង រ៉ាប់រងលើបំណុល) ។
- បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកល ឲ្យបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។ (ករណីនេះសន្តតិជនមិនចាំបាច់ទទួលបន្ទុកលើបំណុល ក្នុងករណីមានបំណុល) ។
- ពុំមានភាគបម្រុង (អាចមានការយល់ច្រឡំថាមានភាគបម្រុង ព្រោះសិទ្ធិ និងករណីកិច្ចរបស់អ ច្ច័យលាភីសកលដូចនឹងសន្តតិជន) ។
- ពុំមានសន្តតិកម្មជំនួស ។

## ២.៦. ការលុបចោលមតកសាសន៍

ការបង្កើតមតកសាសន៍ គឺជាឆន្ទៈរបស់មតកជន ដើម្បីជាគោលបំណងចុងក្រោយក្នុងការបង្ហាញឆន្ទៈ ក្នុងការចាត់ចែងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួន ចំពោះការបង្កើតមតកសាសន៍នេះទៀតសោធ គឺជាសិទ្ធិ ផ្តាច់មុខរបស់ម្ចាស់បណ្តាំ ។ យ៉ាងណាមិញ ម្ចាស់បណ្តាំមិនមែនមានតែសិទ្ធិក្នុងការបង្កើតមតកសាសន៍នោះទេ

[51] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១០ កថាខណ្ឌទី ២

ម្ចាស់បណ្តាំក៏មានសិទ្ធិលុបចោលមតកសាសន៍វិញផងដែរ ។ ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃ ការលុបចោលនូវមតកសាសន៍នេះ ។[52]

សម្រាប់ការលុបចោលមតកសាសន៍នេះ ត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ដែលទាក់ទងនឹងបញ្ញត្តិស្តីពីការលុបចោលមតកសាសន៍ ដូចខាងក្រោម ៖

**២.៦.១.ទម្រង់នៃការលុបចោលមតកសាសន៍**

ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍របស់ខ្លួនបាន នៅក្នុងអំឡុងពេលដែលមតកសាសន៍រហូតដល់មុនពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដោយអាចលុបមតកសាសន៍វិញបានតាមបីទម្រង់ គឺ៖

- ការលុបចោលដោយទម្រង់នៃមតកសាសន៍
- ការលុបចោលដោយការចាត់ចែងនាពេលនៅរស់ និង
- ការលុបចោលដោយសារការបដិសេធលិខិតមតកសាសន៍ ។

**២.៦.១.១.ការលុបចោលដោយទម្រង់នៃមតកសាសន៍**

ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍មួយភាគ ឬទាំងមូលបានតាមទម្រង់នៃមតកសាសន៍ ។ មានន័យថា បើមតកសាសន៍ដែលបានធ្វើក្រោយ មានភាពផ្ទុយគ្នានឹងមតកសាសាន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថាមតកសាសន៍ដែលបានធ្វើក្រោយនេះ អាចលុបចោលនូវមតកសាសន៍ដែលធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។[53] យ៉ាងណាមិញ ដើម្បីឲ្យមានភាពច្បាស់លាស់ចំពោះមតកសាសន៍ដែលបានធ្វើនៅពេលមុន ឬពេលក្រោយ គឺត្រូវកំណត់ទៅលើកាលបរិច្ឆេទដែលបានចុះនៅក្នុងមតកសាសន៍នោះ ។

ដើម្បីលុបចោលមតកសាសន៍ដោយទម្រង់នៃមតកសាសន៍ គឺត្រូវសរសេរក្នុងមតកសាសន៍ថ្មី ដោយបញ្ជាក់ឲ្យច្បាស់ថាអំពីការលុបចោល ។

**២.៦.១.២.ការលុបចោលដោយការចាត់ចែងនាពេលនៅរស់**

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀតចំពោះវត្ថុដែលជាកម្មវត្ថុនៃមត៌ក នាពេលនៅរស់ ត្រូវចាត់ទុកថាម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬសកម្មភាពផ្សេងនោះ ។[54]ក្នុងករណីនេះមានន័យថា តាមមតកសាសន៍ មានចលនវត្ថុ មួយបានប្រគល់ទៅឲ្យបុគ្គលដែលជាសន្តតិជន «ក» ក៏ប៉ុន្តែអំឡុងពេលដែលមតកជននៅរស់បានធ្វើប្រទានកម្ម ចលនវត្ថុនោះទៅឲ្យបុគ្គល «ខ» ដូចនេះ មតកសាសន៍បានលុបចោលអច្ច័យទាន ដែលជាផ្នែកមួយនៃមតកសាសន៍ ។

[52] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨៨
[53] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨៩
[54] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩០

### ២.៦.១.៣.ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ ករណីនេះត្រូវយកទៅអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ដោយចេតនា ។[55] និយាយឲ្យខ្លីទៅគឺមានន័យថា មតកសាសន៍ធ្វើឡើងជាតឹកតាងសម្រាប់បញ្ជាក់ពីឆន្ទៈរបស់ មតកជន ប្រសិនបើមតកជនបំផ្លាញមតកសាសន៍នោះ ជាហេតុនាំឲ្យមតកសាសន៍ត្រូវចាត់ទុកជាមោឃៈ ។

ផ្ទុយទៅវិញក្នុងករណីដែលលិខិតមតកសាសន៍ ត្រូវបានបំផ្លាញដោយទង្វើរបស់តតិយជន ឬដោយប្រធានសក្តិ អានុភាពនៃការលុបចោលមិនកើតឡើងបានឡើយ ប៉ុន្តែ ប្រសិនបើមានផ្នែកណាមួយមើលមិនយល់ ត្រូវចាត់ទុកថាផ្នែកនៃមតកសាសន៍នោះគ្មានអានុភាព ។ ក្នុងករណីដែលមតកសាសន៍ត្រូវបានលុបចោលទាំងស្រុង នោះត្រូវចាត់ទុកថា មតកសាសន៍មិនត្រូវបានបង្កើតឡើងតាំងពីដើម ។

- ❖ កំណត់សម្គាល់ ៖ ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភី ពុំបានអនុវត្តករណីកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឲ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬបើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឲ្យអច្ច័យលាភីនោះអនុវត្តករណីកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះមិនបានអនុវត្តករណីកិច្ចនៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬសន្តតិជននោះអាចទាមទារទៅតុលាការ ឲ្យលុបចោលអច្ច័យទាននោះបាន ។[56]

## ២.៧.ការប្រតិបត្តិមតកសាសន៍

បន្ទាប់ពីបង្កើតមតកសាសន៍គ្រប់ទៅតាមលក្ខខណ្ឌដូចដែលបានរៀបរាប់ខាងលើមក តមកទៀតយើងនឹងធ្វើការសិក្សាទៅលើ ការប្រតិបត្តិមតកសាសន៍វិញម្តង ក្រោយពេលដែលមតកសាសន៍មានអានុភាពបន្ទាប់ពីមរណភាពរបស់មតកជន នោះការប្រតិបត្តិមតកសាសន៍ នឹងចាប់ផ្តើមអនុវត្ត ។

### ២.៧.១.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍

តាមការបកស្រាយខាងលើរួចមកហើយ ចំពោះអ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់ ត្រូវបានជ្រើសរើសដោយ ម្ចាស់បណ្តាំ ឬអាចប្រគល់អាណត្តិឲ្យតតិយជនជាអ្នកកំណត់អ្នកប្រតិបត្តិមតកសាសន៍នោះបាន ។ អ្នកប្រតិបត្តិមតកសាសន៍ គឺជាអ្នកធ្វើសកម្មភាព គតិយុត្តពេលប្រតិបត្តិមតកសាសន៍ ហេតុនេះហើយច្បាប់បានកំណត់នូវលក្ខខណ្ឌតម្រូវខាងលើ លក្ខណៈសម្បត្តិនៃអ្នកដែលមិនអាចប្រតិបត្តិមតកសាសន៍បាន គឺ

---

[55] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩១

[56] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៩៣

មានជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និងជនក្ស័យធន ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។[57]

លើសពីនេះទៅទៀត បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឲ្យតតិយជនអនុវត្តភារកិច្ចជំនួសខ្លួនបានឡើយ លើកលែងតែមតកជន បានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ហើយតតិយជននោះ អនុវត្តភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និងសន្តតិជនប្រសិនបើមានការព្យសនកម្ម (ការខូចខាត) កើតឡើង ជាអាទិ៍ ។

គួរឲ្យកត់សម្គាល់ដែរក្នុងករណីដែលម្ចាស់បណ្តាំ ឬតតិយជនដែលទទួលអាណត្តិពីម្ចាស់បណ្តាំមិនបានជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ ឬក៏បានជ្រើសដែរតែដោយសារមកពីការមិនព្រមកាន់មុខងារ ឬបដិសេធ នោះមានន័យថាអ្នកប្រតិបត្តិមតកសាសន៍គ្មានវត្តមានតាំងពីដើមមក ។ ម៉្យាងទៀត អាចមានករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានកាន់កាប់មុខងារហើយតែក្រោយមក បានទទួលការអនុញ្ញាតពីតុលាការឱ្យលាឈប់ ឬ ក៏បានទទួលមរណភាព ឬ ក៏មានមូលហេតុនៃការខ្វះខាតលក្ខណសម្បត្តិចំពោះជនដដែលនោះកើតមានឡើង។ ចំពោះករណីនេះតុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។[58]

### ២.៧.២.សិទ្ធិ និង តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍បាន ក៏ប៉ុន្តែអ្នកដែលត្រូវបានកំណត់ឱ្យបំពេញការងារជាអ្នកប្រតិបត្តិមតកសាសន៍នោះ ទទួលកាន់មុខងារនោះ ឬ យ៉ាងណា គឺត្រូវគោរពតាមឆន្ទៈរបស់ជននោះ ។ ដូចនេះបើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវអនុវត្តភារកិច្ចនោះភ្លាមៗ ។[59]

ម៉្យាងវិញទៀត ប្រសិនបើបានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ មិនអាចដកការយល់ព្រមនោះវិញបានទេ ។ ដើម្បីឈប់ ត្រូវមានការអនុញ្ញាតពីតុលាការ ។

#### ២.៧.២.១. ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

ក្រោយពីបានកាន់មុខងារហើយ ដំបូងបំផុត អ្នកប្រតិបត្តិមតកសាសន៍ត្រូវរៀបចំបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ភ្លាម ។ បញ្ជីសារពើភណ្ឌមត៌កនេះចាំបាច់មាន ដើម្បីកំណត់ច្បាស់លាស់នូវកម្មវត្ថុនៃសិទ្ធិគ្រប់គ្រងចាត់ចែងម

57 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១៧

58 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១៨

59 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១៥

ត៌ក របស់អ្នកប្រតិបត្តិមកតសាសន៍ ព្រមទាំងដើម្បីបញ្ជាក់អំពីមូលដ្ឋាននៃករណីកិច្ចរាយការណ៍ ព្រមទាំងករណីកិច្ចសងសំណង របស់អ្នកប្រតិបត្តិមតកសាសាន៍ ។ ដូច្នេះ អ្នកប្រតិបត្តិមតកសាសន៍ ដំបូងបំផុត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក ហើយត្រូវប្រគល់បញ្ជីនោះទៅឱ្យសន្តតិជន ។[60]

### ២.៧.២.២.សិទ្ធិ និងករណីកិច្ចក្នុងការគ្រប់គ្រងមត៌ក

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និងករណីកិច្ចដែលចាំបាច់ដើម្បីធ្វើរាល់សកម្មភាពក្នុងការប្រតិបត្តិមតកសាសន៍ នៅក្នុងសិទ្ធិអំណាច និងមុខនាទីរបស់ខ្លួន ។

អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកដែលត្រូវបានជ្រើសតាំងដើម្បីប្រតិបត្តិមតកសាសន៍ ហេតុនេះ ត្រូវផ្តល់សិទ្ធិ និងករណីកិច្ច ដើម្បីគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។[61] អ្នកប្រតិបត្តិមតកសាសន៍នៃមត៌កទាំងអស់អាចសងនូវកាតព្វកិច្ចដែលជាមត៌ក រីឯម្ចាស់បំណុលរបស់មតកជនវិញ ក៏អាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍នេះសងបំណុលបានដែរ ។ ម្យ៉ាងវិញទៀត ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍មិនអនុវត្តអច្ច័យទានតាមការបែងចែកក្នុងមតកសាសន៍ទេ អច្ច័យលាភីអាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍នោះអនុវត្តបាន ។

អ្នកប្រតិបត្តិមតកសាសន៍ មានតែសិទ្ធិគ្រប់គ្រងចាត់ចែងមត៌កប៉ុណ្ណោះ មិនមែនជាប្រធាននៃសិទ្ធិ និងករណីកិច្ចទេ ។ សន្តតិជនទៅវិញទេដែលជាប្រធាននៃសិទ្ធិ និងករណីកិច្ច ក៏ប៉ុន្តែ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ប្រសិនបើសន្តតិជនមានសិទ្ធិចាត់ចែងផងដែរ នោះអាចមានករណីដែលការចាត់ចែងរបស់អ្នកប្រតិបត្តិមតកសាសន៍ និងរបស់សន្តតិជន មិនស៊ីគ្នា ហើយធ្វើឱ្យអ្នកប្រតិបត្តិមតកសាសន៍មិនអាចបំពេញមុខនាទីបានពេញលេញ (ឧទាហរណ៍ ដូចជាការអនុវត្តករណីកិច្ចចុះបញ្ជីស្តីពីការផ្ទេរកម្មសិទ្ធិ ដែលត្រូវជាបន្ទុករបស់សន្តតិជន ក្នុងករណីអច្ច័យទានមានកំណត់ជាដើម) ។ ដូច្នេះហើយបានជាមាត្រានេះបានដកហូតសិទ្ធិចាត់ចែងពីសន្តតិជន ។ ដូចនេះប្រសិនបើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍ឡើយ ។[62]

ម្យ៉ាងវិញទៀត អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើសកម្មភាព នៅក្នុងនាម ជាអ្នកប្រតិបត្តិមតកសាសន៍ចំពោះមត៌ក ។[63] ឧទាហរណ៍ ជាក់ស្តែង គឺអ្នកប្រតិបត្តិមតកសាសន៍ A ត្រូវធ្វើសកម្មភាពគតិយុត្តក្នុងនាមសាមីខ្លួនជា A នោះ ដោយបញ្ជាក់សរសេរថា «« អ្នកប្រតិបត្តិមតកសាសន៍របស់មតកជនឈ្មោះ00 »» ។

---

[60] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២១៩

[61] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២០

[62] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២១

[63] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៣ កថាខណ្ឌទី ១

សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍ក្នុងនាមមុខនាទីរបស់ខ្លួន ត្រូវមានអានុភាព ចំពោះសន្តតិជនដែលជាប្រធាននៃមត៌ក ដូចជាករណីដែលសកម្មភាពអ្នកតំណាង មានអានុភាពផ្ទាល់ចំពោះម្ចាស់សិទ្ធិដែរ ។ ហេតុដូច្នេះ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ អនុវត្តអច្ច័យទាន គេវាយតម្លៃថា សន្តតិជនដែលជាអ្នកមានករណីកិច្ចធ្វើអច្ច័យទាន បានអនុវត្តអច្ច័យទាននោះដែរ ។[64]

## ២.៧.២.៣.សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍មិនអាចឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលមានមូលហេតុដែលពុំអាចជៀសវាងបានទេ ព្រមទាំងក្នុងករណីដែលមានការចែងអនុញ្ញាតជាមុនក្នុងលិខិតមតកសាសន៍ អាចឱ្យតតិយជនអនុវត្តកិច្ចការនោះបាន ។[65] ការមិនអនុញ្ញាតឱ្យតតិយជនអនុវត្តកិច្ចការនេះ ជាគោលការណ៍ គឺដោយសារតែមតកជនជឿទុកចិត្តទៅលើចំណេះដឹង និងសមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ហើយបានជ្រើសតាំងអ្នកនោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍នោះ ហើយបានជ្រើសតាំងអ្នកនោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ដោយប្រគល់សិទ្ធិដែលមានលក្ខណៈផ្តាច់មុខ ដូច្នេះ គឺមានន័យដូចគ្នានឹងអ្នកតំណាងដែលបានធ្វើកិច្ចសន្យាជាមួយម្ចាស់សិទ្ធិដែរ (មាត្រា ៣៧៦) ។

អ្នកប្រតិបត្តិមតកសាសន៍ ក្នុងករណីដែលបានឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួន ។ ជាបឋម ក្នុងករណីដែលអាចឱ្យតតិយជនអនុវត្តកិច្ចការនោះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និង សន្តតិជន ក្នុងការជ្រើសតាំង និងត្រួតពិនិត្យតតិយជននោះ ។ ការទទួលខុសត្រូវនេះ ដូចគ្នានឹងករណីដែលអ្នកតំណាងជ្រើសតាំងអនុតំណាង (មាត្រា ៣៧៧ កថាខណ្ឌទី ១) ។ បន្ទាប់មក ក្នុងករណីដែលបានជ្រើសតាំងឱ្យតតិយជនអនុវត្តកិច្ចការ ដោយខុសនឹងគោលការណ៍នោះនឹងត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។[66]

## ២.៧.២.៤.សិទ្ធិលាឈប់ពីអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវបានជ្រើសតាំង ដោយមតកជនផ្ទាល់ ឬដោយតតិយជនដោយអាណត្តិ ឬដោយតុលាការ ។ អ្នកប្រតិបត្តិមតកសាសន៍ អាចមានសិទ្ធិបដិសេធភ្លាមៗ ពេលដែលត្រូវបានជ្រើសតាំងដោយបុគ្គលខាងលើ ប៉ុន្តែប្រសិនបើយល់ព្រម ក្នុងករណីដែលចង់លាឈប់ពីភារកិច្ចវិញ អ្នកប្រតិបត្តិមតកសាសន៍ អាចឈប់បាន ប្រសិនបើ មានមូលហេតុត្រឹមត្រូវ ដោយទទួលការអនុញ្ញាតពីតុលាការ ។[67]

---

[64] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៣ កថាខណ្ឌទី ២

[65] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៤ កថាខណ្ឌទី ១

[66] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៤ កថាខណ្ឌទី ២

[67] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៧ កថាខណ្ឌទី ១

ផ្ទុយទៅវិញ ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍មិនបានចង់លាឈប់ ក៏ប៉ុន្តែត្រូវបានបញ្ឈប់ដោយបានធ្វេសប្រហែសក្នុងភារកិច្ច ឬបើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការបាន ។[68]

### ២.៧.៣.សហអ្នកប្រតិបត្តិមតកសាសន៍

ក្នុងករណី ដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្ដាល ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវសម្រេចតាមឆន្ទៈនោះ ។[69] ឧទាហរណ៍ A មានសិទ្ធិសម្រេចអ្វីៗស្ដីពីអចលនទ្រព្យ ហើយ B មានសិទ្ធិសម្រេចអ្វីៗស្ដីពីសិទ្ធិលើបំណុល ជាអាទិ៍ ។

### ២.៧.៤.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

ការប្រតិបត្តិមតកសាសន៍ ក៏ដូចជាការងារអណត្តិដែរ មានពីរយ៉ាង គឺការប្រតិបត្តិដោយយកកម្រៃ និងការប្រតិបត្តិដោយមិនយកកម្រៃ ។ ក៏ប៉ុន្តែ អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីកិច្ចក្នុងការគ្រប់គ្រងមត៌រាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ ម្យ៉ាងទៀត ពេលប្រតិបត្តិកិច្ចការនោះ ត្រូវចាត់ចែងកិច្ចការដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ហើយបន្ទុកមុខងារនេះធ្ងន់ធ្ងរណាស់ ថែមទាំងមានការទទួលខុសត្រូវខ្ពស់ ដូចនេះហើយគួរតែទទួលកម្រៃ ។ ជាពិសេស ក្នុងករណីដែលបានជ្រើសតាំងតតិយជនដែលមិនមែនជាសន្តតិជន ឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ គួរតែមានកម្រៃ ។

រីឯចំនួនទឹកប្រាក់នៃកម្រៃនោះវិញ យោងតាមករណីខាងលើនៅក្នុងលិខិតមតកសាសន៍ ត្រូវអនុវត្តតាមមតកសាសន៍នោះ ។ ប្រសិនបើក្នុងមតកសាសន៍កំណត់ថា ពុំមានកម្រៃទេ នោះមិនមានសិទ្ធិទាមទារកម្រៃទេ ដូច្នេះ បើមិនពេញចិត្ត អាចបដិសេធមិនកាន់មុខងារនេះបាន ។

ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះតាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ ។ ករណីដែលអ្នកប្រតិបត្តិមតកសាសន៍ ជាសន្តតិជន ការប្រតិបត្តិនោះមានភាពងាយស្រួល ដូច្នេះ មិនចាំបាច់ឱ្យកម្រៃក៏បានដែរ ។ ក្នុងករណីដែលតតិយជនជាអ្នកប្រតិបត្តិមតកសាសន៍ ទោះតិចក៏ដោយ ក៏តុលាការគួរតែកំណត់ចំនួនទឹកប្រាក់នៃកម្រៃនេះដែរ ។ ពេលកំណត់ចំនួនទឹកប្រាក់នៃកម្រៃនេះ ត្រូវពិចារណាទៅលើស្ថានភាពនៃមត៌ក ទំនាក់ទំនងរវាងម្ចាស់បណ្ដាំ និងអ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងស្ថានភាពផ្សេងទៀត ។ ឧទាហរណ៍ ប្រសិនបើតុលាការបានជ្រើសតាំងមេធាវី ជាអាទិ៍ ដែលជាអ្នកមាន

[68] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៧ កថាខណ្ឌទី ២

[69] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២២៥ កថាខណ្ឌទី ១

ជំនាញខាងច្បាប់ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ជាពិសេស ក្នុងករណីដែលបានធ្វើបណ្តឹង ដើម្បីប្រតិបត្តិមតកសាសន៍នោះ ត្រូវផ្តល់កម្រៃឱ្យបានសមរម្យតាមនោះដែរ ។

### ២.៧.៥.សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ជាបន្ទុកមួយនៃមត៌ក ហេតុនេះហើយអាចកាត់ពីមត៌កនោះបាន។

សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍មានដូចជា សោហ៊ុយចាំបាច់សម្រាប់នីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោយហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក សោហ៊ុយគ្រប់គ្រងមត៌ក កម្រៃអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ ។ អ្នកប្រតិបត្តិមតកសាសន៍ អាចកាត់សោហ៊ុយទាំងនេះពីមត៌កបាន ។ ការកាត់សោហ៊ុយនៃមតកសាសន៍នេះមិនអាចបន្ថយភាគបម្រុងបានទេ ។ ដូច្នេះ ភាគនៃសោហ៊ុយដែលអាចបន្ថយភាគបម្រុងនោះ ជាបន្ទុករបស់អច្ច័យលាភី ។ **ឧទាហរណ៍៖** មត៌កមាន ១.០០០ ដុល្លារ ហើយសន្តតិជន A និង B ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា ។ មតកជនបានធ្វើមតកសាសន៍ ដោយគិតដល់ភាគបម្រុងរបស់ B ២៥០ ដុល្លារ ហើយបានកំណត់ឱ្យ A ៧៣០ ដុល្លារ ។ រីឯសោហ៊ុយប្រតិបត្តិមតកសាសន៍វិញត្រូវចំណាយអស់ ៥០ ដុល្លារ ។ ក្នុងករណីនេះ សោហ៊ុយ ៥០ដុល្លារ ត្រូវយកពីមត៌ក ២៧០ដុល្លារដែលនៅសល់ បន្ទាប់ពីផ្តល់ឱ្យ A ចំនួន ៧៣០ ដុល្លាររួចក៏ប៉ុន្តែ អាចកាត់យកត្រឹមតែ ២០ដុល្លារវិញ ដែលនៅសល់ពីភាគបម្រុងតែប៉ុណ្ណោះ នៅសល់ ៣០ ដុល្លារទៀត ជាបន្ទុករបស់ A ដែលទទួលលទ្ធកម្ម ៧៣០ ដុល្លារ តាមមតកសាសន៍ ។ ប្រសិនបើ B មិនទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងទេ ត្រូវកាត់សោហ៊ុយពី ២៧០ ដុល្លារ ដែលជាមត៌កសល់នោះ ។

## ២.៨.ភាគបម្រុង

របបភាគបម្រុង គឺជារបបធានាមួយភាគនៃចំណែកមត៌កកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់ ។ មតកជនមានសេរីភាពក្នុងការធ្វើមតកសាសន៍ ក៏ប៉ុន្តែ របបនេះទទួលស្គាល់ឱ្យសន្តតិជនដែលកំណត់ដោយច្បាប់មួយចំនួន ធ្វើការបដិសេធនូវសេរីភាពនេះមួយភាគ ។ របបបម្រុងនេះ មានតួនាទីសម្រួលសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ ហេតុនេះហើយបានជាយើងនឹងត្រូវសិក្សាលម្អិតពីរបបនៃភាគបម្រុងនេះ ។

ក្នុងរបបភាគបម្រុងនេះ មានវិធីធានានូវភាគបម្រុងដោយការបដិសេធមតកសាសន៍ ជាអាទិ៍ ដោយសន្តតិជនដែលត្រូវគេបំពានសិទ្ធិលើភាគបម្រុងរបស់ខ្លួន និង វិធីហាមមិឱ្យមតកជនយកមត៌កមួយចំនួនទៅធ្វើជាកម្មវត្ថុនៃមតកសាសន៍ ជាអាទិ៍ ។ តទៅនេះយើងនឹងសិក្សាឱ្យកាន់តែស៊ីជម្រៅទៅលើភាគបម្រុងនេះ ដោយយើងនឹងសិក្សាទៅលើ (២.៨.១) អ្នកមានសិទ្ធិលើភាគបម្រុង ។

### ២.៨.១.អ្នកមានសិទ្ធិលើភាគបម្រុង

ក្នុងចំណោមសន្តតិជនដែលកំណត់ដោយច្បាប់ មានតែបច្ឆាញាតិផ្ទាល់ ឬឪពុកម្ដាយ ឬជីដូនជីតា និង សហព័ទ្ធរបស់មតកជនទេ ដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ។ មានន័យថា សន្តតិជន ក្រៅពីបងប្អូនបង្កើត របស់មតកជន និង ជនទទួលសន្តតិកម្មជំនួសបងប្អូនបង្កើតនោះ ជាអ្នកមានសិទ្ធិលើភាគបម្រុង ។ ម្យ៉ាងវិញ ទៀតក្នុងករណីដែលបច្ឆាញាតិផ្ទាល់របស់មតកជន បានទទួលមរណភាព មុនពេលមតកជនទទួលមរណភាព ជនដែលទទួល សន្តតិកម្មជំនួស ក៏ត្រូវមានភាគបម្រុងដែរ ។ ជាគោលការណ៍ភាគបម្រុង គឺ ១ ភាគ ២ នៃមត៌ក របស់មតកជន ។[70] ចំពោះករណីដែលមានតែឪពុកម្ដាយ ឬ មានតែជីដូនជីតាជាសន្តតិជន ភាគបម្រុង គឺ ១ ភាគ ៣ នៃមត៌ករបស់មតកជន ។[71] ឧទាហរណ៍ ក្នុងករណីដែលមានតែកូនម្នាក់ និង សហព័ទ្ធរបស់មតកជន ជា សន្តតិជន ភាគបម្រុងសម្រាប់អ្នកទាំងនោះគឺ ១ ភាគ ២ នៃមត៌ករបស់មតកជន ។

ក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងមានច្រើនាក់ ត្រូវធ្វើការបែងចែកទ្រព្យដែលត្រូវបានចាត់ ទុកជាភាគបម្រុងនោះ ទៅតាមសមាមាត្រនៃចំណែកមត៌ក ។ ចំពោះឧទាហរណ៍ ខាងលើនេះ ចំណែកមតត៌ក មានស្មើភាគគ្នា ហេតុនេះហើយ ភាគបម្រុងរបស់កូន ព្រមទាំងសហព័ទ្ធនោះ គឺ ១ ភាគ ៤ នៃមត៌កសម្រាប់ ម្នាក់ៗ ។

**កំណត់សម្គាល់៖**

- សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច
- បើមានសន្តតិជនលំដាប់ទី១ ជាអ្នកមានសិទ្ធិលើភាគបម្រុង នោះសន្តតិជនលំដាប់ទី២ មិនមាន សិទ្ធិនេះឡើយ ។

**ឧទាហរណ៍ ៖** មតកជន មិនមានកូន និង សហព័ទ្ធ មានតែឪពុក និងម្ដាយ ដូចនេះឪពុកម្ដាយជាសន្តតិ ជនតាមច្បាប់ ករណីខាងលើ ភាគបម្រុង គឺ ១/៣ នៃមត៌ករបស់មតកជន ដោយសន្តតិជនមានពីរនាក់ នាំឲ្យ ចំណែកនៃសិទ្ធិលើភាគបម្រុង ១/៣ ចែកនឹង២ = ១/៦ ។ ជាក់ស្ដែងតាមឧទាហរណ៍ខាងលើ ប្រសិនបើ មតក ជន មានទ្រព្យដែលជាមូលដ្ឋានលើភាគបម្រុង មានចំនួន ៣០.០០០ ដុល្លារ ។

ដូចនេះតាមសម្មតិកម្មខាងលើយើងបាន ៖

នាំឲ្យភាគបម្រុង = ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង x (១/៦)

នាំឲ្យភាគបម្រុង = ៣០.០០០ x (១/៦) = ៥.០០០ ដុល្លារ

[70] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០ កថាខណ្ឌទី ១-ខ

[71] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០ កថាខណ្ឌទី ១-ក

ដូច្នេះ ចំណែកនៃមត៌ក ដែលអាចទាមទារបានពីភាគបម្រុង គឺ ឪពុក និង ម្តាយ ទទួលបាន ៥.០០០ ដុល្លារ ស្មើគ្នា ។

ក្នុងករណីសន្តតិកម្មជំនួស ភាគបម្រុងក៏ត្រូវចែកស្មើភាគគ្នារវាងជនដែលទទួលសន្តតិកម្មជំនួសដែរ ។

**២.៨.២.ការគណនាភាគបម្រុង**

**២.៨.២.១.ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុង**

ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស (មាត្រា ១១៦៣) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម (មាត្រា ១២២៣ ) ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

ដូចនេះយើងអាចទាញចេញជារូបមន្តដូចខាងក្រោម៖

| |
|---|
| ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុង = មត៌កនាពេលចាប់ផ្តើមសន្តតិកម្ម + តម្លៃនៃជប្រយោជន៍ពិសេស + ប្រទានកម្ម - កាតព្វកិច្ច |

ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

ដោយលើកលែងតែផលប្រយោជន៍ពិសេស ប្រទានកម្មដែលកំណត់ខាងក្រោមនេះ នឹងក្លាយទៅជាប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង៖

- ✓ ប្រទានកម្មដែលបានធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។[72] ជាគោលការណ៍ ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេលមួយឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។
- ✓ ប្រទានកម្មដែលត្រូវធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឲ្យមានការខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។[73] ចំពោះប្រទានកម្មបែបនេះ គឺជាចេតនារបស់ភាគីទាំងសងខាងដែលបានដឹងថាការធ្វើប្រទានកម្មបែប នេះជាការបំពានលើអ្នកដែលមានសិទ្ធិលើភាគបម្រុង ។ ហើយការធ្វើប្រទានកម្មបែបនេះមិនបានគិតពីអំឡុងពេលនោះទេ ព្រោះជាការរំលោភបំពានអ្នកមានសិទ្ធិលើភាគបម្រុង ហើយដើម្បីដឹងថាជាការបំពាន ឬមិនបំពាននោះ ត្រូវធ្វើការប្រៀបធៀបទ្រព្យសម្បត្តិសរុបដែលមតកជនមានពេលធ្វើប្រទានកម្ម និងតម្លៃដែលបានធ្វើប្រទានកម្ម ។

[72] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣២ កថាខណ្ឌទី ១-ក

[73] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣២ កថាខណ្ឌទី ១-ខ

**ឧទាហរណ៍ ៖** មតកជនមានប្រាក់ចំនួន ២០.០០០ ដុល្លារ ដោយនៅមុនពេលមតកជនទទួលមរណភាព បានធ្វើប្រទានកម្ម ចំនួន ៥.០០០ ដុល្លារ ឲ្យទៅ (ក) ជាកូន ដើម្បីជាទុនក្នុងបង្កើនការរកស៊ី បើប្រៀបធៀបទំហំ ទឹកប្រាក់សរុបរបស់មតកជន រវាងទឹកប្រាក់ដែលបានធ្វើប្រទានកម្ម មិនមែនជាការបំពានភាគបម្រុងឡើយ បើទោះបីក្រោយមក ប្រាក់របស់មតកជនបានថយចុះ កម្រិតណាក៏ដោយ ។ ដោយឡែកក្នុងករណីដែលមតកជនបានធ្វើប្រទានកម្ម ទៅឲ្យ (ក) ចំនួន ១៥.០០០ ដុល្លារវិញ នោះសបញ្ជាក់ឲ្យឃើញថាមានការរំលោភបំពានទៅដល់អ្នកមានសិទ្ធិលើភាគបម្រុង ដោយជាក់ស្តែងទំហំលុយនៃការធ្វើប្រទានកម្មច្រើនហួសហេតុពេក ។

- ✓ ចំពោះកាតព្វកិច្ចដែលមិនយកតម្លៃតប ឬការលើលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ និងកិច្ចសន្យាដែលបានធ្វើដោយយកថ្នូរមិនត្រឹមត្រូវ ក៏ត្រូវចាត់ទុកថាប្រទានកម្មដែរ ។[74]

**ឧទាហរណ៍ ៖** (ក) ជាមតកជន មាន កូន (ខ) និង (គ) និងមានបងធម៌ (ឃ) ដោយបានបន្សល់ទុកនូវមត៌ក ចំនួន ៣០.០០០ ដុល្លារ ព្រមទាំងបំណុល ៦.០០០ ដុល្លារ និងមានមតកសាសន៍ដែលត្រឹមត្រូវតាមទម្រង់ ដែលក្នុងនោះបានសរសេរថា ទ្រព្យសម្បត្តិពាក់កណ្ដាល់របស់ខ្ញុំឲ្យទៅមិត្តភក្តិ (ឃ) ហើយក្នុងនោះ (ខ) និង (គ) ទទួលបាន ៧.៥០០ ដុល្លារស្មើគ្នា។ ប៉ុន្តែមុនពេលមតកជនទទួលមរណភាព (ខ) បានទទួលផលប្រយោជន៍ពិសេស ១២.០០០ ដុល្លារ ។

ដោយយោងតាមរូបមន្តខាងលើ ៖

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុងគឺ = ៣០.០០០ + ១២.០០០ - ៦.០០០ = **៣៦០០០** ដុល្លារ

ភាគបម្រុងដែលសន្តតិជនទាំងអស់ គឺ ៖ ៣៦.០០០ / ២ = ១៨.០០០ ដុល្លារ

ភាគបម្រុងរបស់សន្តតតិជន១នាក់ ៖ ១៨.០០០ / ២ = ៩.០០០ដុល្លារ

- ❖ **កំណត់សម្គាល់ ៖** ដោយសារតែ (ឃ) ជាមិត្តភក្តិ មិនមែនជាសន្តតិជនដែលកំណត់ដោយច្បាប់ដូចនេះមិនមានសិទ្ធិលើភាគបម្រុងទេ ដូចនេះអ្វីដែលទទួលបានគឺជាចំណែកក្រៅពីភាគបម្រុងប៉ុណ្ណោះ គឺ ១៨.០០០ ដុល្លារ ។

### ២.៨.២.២.វិធីគណនានៃចំនួនដែលបំពានភាគបម្រុង

ចំនួនដែលបំពានភាគបម្រុង គឺត្រូវគណនាដោយយកភាគបម្រុងរបស់បុគ្គលនោះ ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលបុគ្គលនោះទទួលបានដោយសន្តតិកម្ម និងផលប្រយោជន៍ពិសេស ហើយ បូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះទទួលបន្ទុកដោយសន្តតិកម្ម ។[75]

[74] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣២ កថាខណ្ឌទី ២

[75] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៤

យើងអាចទាញបាននូវរូបមន្តដូចខាងក្រោម

| |
|---|
| ចំនួនដែលបំពានភាគបម្រុង = ភាគបម្រុងរបស់បុគ្គលនោះ - ចំនួនទ្រព្យសម្បត្តិដែលទទួលបានពីមតកសាសន៍ - ផលប្រយោជន៍ពិសេស + កាតព្វកិច្ចដែលលើបំណុលដោយសន្តតិកម្ម |

យោងតាមឧទាហរណ៍ ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុង ខាងលើ យើងយកមកសិក្សាបន្តដោយបានសម្មតិកម្មដូចតទៅ ៖

| | កូន(ខ) | កូន (គ) |
|---|---|---|
| ចំនួនទទួលបាន | ៧.៥០០ ដុល្លារ | ៧.៥០០ ដុល្លារ |
| កាតព្វកិច្ចលើបំណុល | ៣.០០០ ដុល្លារ | ៣.០០០ ដុល្លារ |
| ផលប្រយោជន៍ពិសេស | ១២.០០០ ដុល្លារ | 0 ដុល្លារ |
| ភាគបម្រុង | ៩.០០០ ដុល្លារ | ៩.០០០ ដុល្លារ |

ចំនួនដែលបំពានលើភាគបម្រុង របស់ (ខ) មិនមានទេ គឺ 0ដុល្លារ ចំណែក (ខ) បានបំពានភាគបម្រុងចំនួន ៤.៥០០ដុល្លារ ដោយយោងតាមរូបមន្តខាងលើ ។

### ២.៨.២.៣.ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ទោះបីជាអ្នកមានសិទ្ធិលើភាគបម្រុងក៏ដោយ ក៏មិនមែនមានន័យថាទ្រព្យសម្បត្តិនឹងត្រូវបានចែកទៅឲ្យបុគ្គលនោះដោយស្វ័យប្រវត្តិនោះដែរ ។ ក្នុងករណី មតកសាសន៍ដែលធ្វើឲ្យបំពានភាគបម្រុងរបស់បុគ្គលណាម្នាក់ត្រូវបានកើតឡើងអ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែអនុវត្តការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងថា ភាគបម្រុងរបស់ខ្លួនត្រូវបានបំពានដោយអច្ច័យទានជាដើម ។ ម្យ៉ាងវិញទៀតសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ក៏ត្រូវរលត់អាជ្ញាយុកាល បើអំឡុងពេល ៥ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។[76]

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទានជាអាទិ៍ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

[76] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៥

### ២.៨.២.៤.ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរួមមានៈ[77]

→ អច្ច័យទាន

→ ចំណែកមត៌កតាមមតកសាសន៍

→ ផលប្រយោជន៍ពិសេស និង

→ ប្រទានកម្ម

ក្នុងករណីដែលអច្ច័យទានរបស់សន្តតិជន ការកំណត់ចំណែកមត៌ក និងការទទួលផលប្រយោជន៍ពិសេសត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនេះ មានត្រឹមតែផ្នែកដែលលើសចំនួនពីទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនប៉ុណ្ណោះ ។[78] មានន័យថា ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងប្រសិនបើសន្តតិជនដែលត្រូវបានគេទាមទារឱ្យកាត់បន្ថយនោះ ត្រូវបានគេបំពានភាគបម្រុងរបស់ខ្លួនវិញ ដោយសារតែការកាត់បន្ថយនោះ សន្តតិជននោះអាចបដិសេធនូវការទាមទារនោះបាន។

### ២.៨.២.៥.លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមតកសាសន៍ជាមុនទេ ។

ចំពោះកថាខណ្ឌខាងលើមានន័យថា តើត្រូវយកទ្រព្យណាមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយមុន ក្នុងចំណោមទ្រព្យដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយយោងតាមមាត្រា ១២៣៣ ។

តាមកថាខណ្ឌដែល បានកំណត់ថា ត្រូវយកអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ មកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយ មុនប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ។ ប៉ុន្តែប្រសិនបើធ្វើការកម្រិតនូវកម្មវត្ថុនៃការកាត់បន្ថយ ត្រឹមតែមត៌ក អាចទៅជាបំពានទៅលើភាគបម្រុងទៅវិញ ដោយសារការធ្វើប្រទានកម្មពេលនៅរស់ ។ ហេតុដូច្នេះ ប្រទានកម្ម ជាអាទិ៍ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយ ក្នុងទំហំដែលបានចែងក្នុងមាត្រា ១២៣២ ដែរ ។ ផលប្រយោជន៍ពិសេសក៏ជាប្រទានកម្មពេលនៅរស់មួយប្រភេទដែរ ។ ក៏ប៉ុន្តែ ការយកផលប្រយោជន៍ពិសេសទាំងអស់ មកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយ នាំឱ្យមានសមភាពមួយរវាងសហសន្តតិជន ហេតុនេះហើយបានជា មាត្រា ១២៣៣ បានចែងដូចនេះ ។ ក៏ប៉ុន្តែ ប្រសិនបើ

[77] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៣ វាក្យខណ្ឌទី ១

[78] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៣ វាក្យខណ្ឌទី ២

មត៌កដែលមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម មានគ្រប់គ្រាន់ដើម្បីបង្គ្រប់ភាគបម្រុង នោះមិនចាំបាច់លើកការចាត់ចែងពេលមតកជននៅរស់មកបង្គ្រប់ភាគបម្រុងទេ ។

ករណី ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងមាន ច្រើនលំដាប់ ជាអាទិភាពនៃការកាត់បន្ថយ មានដូចខាងក្រោម[79] ៖

លំដាប់ទី១ អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន ។

លំដាប់ទី២ អច្ច័យទានដែលត្រូវបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

លំដាប់ទី៣ ប្រទានកម្ម ឬផលប្រយោជន៍ពិសេស ។ ចំពោះប្រទានកម្ម ឬផលប្រយោជន៍ពិសេស គឺជាកម្មវត្ថុថ្មី មានន័យថា ជាវត្ថុដែលត្រូវបានកើតឡើងតាមក្រោយដូច្នេះវានឹងមានអាទិភាពជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

**ឧទាហរណ៍៖** មតកជន បានទទួលមរណភាព នៅថ្ងៃទី ១ ខែសីហា ឆ្នាំ២០១៦ ដោយមានកូន ២នាក់ (ក) និង (ខ) ដោយបន្សល់ទុកនូវ ទ្រព្យសម្បត្តិ ១៨.០០០ ដុល្លារ និងមានមតកសាសន៍ត្រឹមត្រូវតាមទម្រង់ ដែលមានខ្លឹមសារថា ប្រាក់ចំនួន ៣.០០០ ដុល្លារ ប្រគល់ឲ្យទៅមិត្តភក្តិ (ឃ) ហើយប្រាក់ចំនួន ១៤.០០០ដុល្លារឲ្យទៅ (ក) រីឯប្រាក់ចំនួន ១.០០០ដុល្លារ ឲ្យទៅកូន (ខ) ។ ប៉ុន្តែ មុនពេលមតកជនទទួលមរណភាព នៅឆ្នាំ ២០១៤ បានធ្វើប្រទានកម្មទៅឲ្យ (ក) ចំនួន ១៥.០០០ដុល្លារ បន្ទាប់មក នៅឆ្នាំបន្ទាប់បានប្រគល់នូវប្រទានកម្ម ចំនួន៧.០០០ ដុល្លារ បន្ថែមទៀត ទៅ (ក) ដដែល ។

[79] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៦-១២៣៨

ដូចនេះតាមសម្មតិកម្មខាងលើនាំឲ្យ

- ភាគបម្រុងរួមគឺ = ១៨.០០០+១៥.០០០+៧.០០០ = ៤០.០០០ដុល្លារ
- ភាគបម្រុងសម្រាប់សន្តតិជនម្នាក់ៗ = ៤០.០០០/២/២/ = ១០.០០០ដុល្លារ

សន្តតិជនដែលត្រូវបានបំពានភាគបម្រុង គឺ កូន (ខ) ចំនួន ១០.០០០-១.០០០ = ៩.០០០ដុល្លារ

- លំដាប់នៃការកាត់បន្ថយភាគបម្រុង៖

ទី១៖ អច្ច័យទានទៅកូនត្រឹមផ្នែកដែលលើសភាគបម្រុងរបស់កូន (ក)៖

១៤.០០០ - ១០.០០០ = ៤.០០០ ដុល្លារ

ទី២៖ អច្ច័យទានទៅឲ្យមិត្តភក្តិ (ឃ) ចំនួន ៣.០០០ដុល្លារ = ៣.០០០ដុល្លារ

ទី៣៖ ប្រទានកម្មនៃវត្ថុថ្មីក្នុងអំឡុងពេលនៅរស់ឲ្យកូន (ក) ចំនួន ៧.០០០ដុល្លារ = ២.០០០ ដុល្លារ ។ដូចនេះដោយរួមបញ្ចូលលំដាប់នៃការកាត់បន្ថយភាគបម្រុងទាំងបីចូលគ្នាគ្រប់ចំនួនដែលបំពានភាគបម្រុងរបស់ (ខ) ចំនួន ៩.០០០ដុល្លារ ។

**២.៨.២.៦.អានុភាពនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង**

នៅពេលដែលមានការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ជាដើម និងបាត់បង់អានុភាពត្រឹមកម្រិតបំពានភាគបម្រុងហើយសិទ្ធិនៃផ្នែកទាំងនោះ គឺជារបស់អ្នកដែលបានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

# ជំពូកទី៣

# សន្តិកម្មតាមច្បាប់

# ជំពូកទី ៣
# សន្តតិកម្មតាមច្បាប់

បើសិនក្នុងករណីដែលមតកជនមិនបានធ្វើមតកសាសន៍ ឬលិខិតបណ្តាំទេនោះ ជាគោលការណ៍គេត្រូវធ្វើការបែងចែកទៅតាមច្បាប់ ពិព្រោះថាច្បាប់ក៏បានចែងបម្រុងទុកផងដែរ ដែលនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សម្រាប់យកមកអនុវត្តវាមិនខុសគ្នាពីសន្តតិកម្មតាមមតកសាសន៍នោះទេ។ ហេតុនេះហើយយើងនឹងមកសិក្សាឲ្យកាន់តែច្បាស់ និងស៊ីជម្រៅនៅក្នុងជំពូកទី៣ សន្តតិកម្មតាម ច្បាប់។

សន្តតិកម្មតាមច្បាប់នេះ គឺជាការផ្ទេរមត៌ករបស់មតកជន ទៅឲ្យសន្តតិជន ឬជនដែលមានសិទ្ធិដូចជាសន្តតិកម្មតាមមតកសាសន៍ដែរ ប៉ុន្តែមានលក្ខណៈមិនដូចគ្នាត្រង់ថាសន្តតិកម្មតាមមតកសាសន៍បែងចែកទ្រព្យសម្បត្តិទៅតាមឆន្ទៈរបស់មតកជន ផ្ទុយទៅវិញសន្តតិកម្មតាមច្បាប់ គឺជាការបែងចែកមត៌កដែលជាកម្មវត្ថុនៃទ្រព្យសម្បត្តិ ទាំងអស់របស់ម្ចាស់ទ្រព្យទៅឲ្យសន្តតិជន ឬអ្នកដែលមានសិទ្ធិទាំងអស់តាមការកំណត់របស់ច្បាប់ ដោយសារតែមិនមានបណ្តាំ។

សន្តតិកម្មតាមច្បាប់ ជាការបែងចែកមត៌កដែលជាកម្មវត្ថុនៃទ្រព្យសម្បត្តិទាំងអស់របស់ម្ចាស់ទ្រព្យ ឬមតកជន ទៅឲ្យសន្តតិជន ឬអ្នកដែលមានសិទ្ធិទាំងអស់តាមការកំណត់របស់ច្បាប់ ដោយសារតែមតកជនមិនបានបន្សល់ទុកនូវលិខិតបណ្តាំ។

ក្នុងជំពូកទី ៣ សន្តតិកម្មតាមច្បាប់ នេះត្រូវបែងចែកជាបីផ្នែក ដែលក្នុងនោះមានដូចជា ចំណុច ៣.១ បកស្រាយអំពី សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់ ចំណុច ៣.២ បកស្រាយអំពី ការអនុវត្តនៃសន្តតិកម្មតាមច្បាប់ និងចំណុច ៣.៣ បកស្រាយអំពី ការបែងចែកមត៌ក ។

## ៣.១. សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

### ៣.១.១. និយមន័យ

សន្តតិកម្មតាមច្បាប់ ជាទម្រង់មួយនៃសន្តតិកម្មដែលត្រូវអនុវត្តទៅតាមការកំណត់របស់បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធនឹងសន្តតិជន នៅក្នុងករណីដែលមតកជនមិនបានធ្វើបណ្តាំមត៌ក (មតកសាសន៍) ហើយសហសន្តតិជនមិនអាចព្រមព្រៀងគ្នាតាមការពិភាក្សា។ សន្តតិកម្មតាមច្បាប់ត្រូវតាក់តែងឡើងដោយគិតទៅដល់យុត្តិធម៌រវាងញាត្តិដែលត្រូវបានកំណត់ថាជា សន្តតិជន។

សន្តតិកម្ម ចាប់ផ្តើមដោយសារមរណភាពរបស់មតកជនហើយសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជន។[80]

[80] មាត្រា ១១៨៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ចំពោះមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម ទីកន្លែងដែលត្រូវចាប់ផ្តើមសន្តតិកម្ម អានុភាពនៃសន្តតិកម្ម និងភាពគ្រប់លក្ខណៈសម្បត្តិជាសន្តតកម្ម មិនថាជាសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍នោះ ពោលគឺវាមានលក្ខណៈដូចគ្នា ដែលចំណុចនេះយើងបានធ្វើការសិក្សាយ៉ាងលម្អិតនៅជំពូកទី១ រួចមកហើយ។

នៅក្នុងករណីនេះដែរប្រសិនបើ សន្តតិកម្មតាមច្បាប់មានសន្តតិជនតែម្នាក់ គឺមិនចាំបាច់ធ្វើការបែងចែកមត៌កទេ។ ផ្ទុយទៅវិញ បើសន្តតិជនមានច្រើននាក់គឺចាំបាច់ធ្វើការបែងចែកមត៌ក។ ដូច្នេះ ចាប់ពីមាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីវិធានស្តីពី សន្តតិជន និងចំណែកមត៌កដែលច្បាប់បានកំណត់។ ចំណុចបន្ទាប់ យើងនឹងធ្វើការសិក្សាទៅលើសន្តតិជន។

### ៣.១.២. លំដាប់សន្តតិជន

សន្តតិជន គឺជាជនទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។[81] ដូចយើងដឹងហើយថាសន្តតិជន គឺជាអ្នកដែលទទួលបន្ត ឬស្នង (ទាយាទ) នូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមច្បាប់ ឬតាមឆន្ទៈដោយបុគ្គលអាចក្លាយជាសន្តតិជន (ជនដែលត្រូវសន្មត់ថាជាសន្តតិជន)។ មតកជនអាចធ្វើការផ្ទេរទ្រព្យរបស់ខ្លួនតាមឆន្ទៈរបស់ខ្លួន ដោយបង្កើតនូវមតកសាសន៍ ឬប្រសិនបើមិនបានកំណត់ទេ ទ្រព្យនោះនឹងត្រូវធ្វើការផ្ទេរទៅតាមការកំណត់របស់ច្បាប់។

ក្នុងករណីដែលគ្មានបណ្តាំ ឬមតកសាសន៍ ច្បាប់បានបញ្ញត្តិថា ការបែងចែកទ្រព្យសម្បត្តិ គេធ្វើការបែងចែកមត៌កទៅតាមលំដាប់នៃសន្តតិជន។ ផ្អែកតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ សន្តតិជនត្រូវបានបែងចែកជា០៣ លំដាប់គឺ សន្តតិជនលំដាប់ទី១ ៖ បច្ឆាញ្ញាតិ សន្តតិជនលំដាប់ទី២ ៖ បុព្វញ្ញាតិ និង សន្តតិជនលំដាប់ទី៣ ៖ បងប្អូនបង្កើត។

ជនដែលជាជនក្នុងក្របខណ្ឌនៃសន្តតិកម្មតាមច្បាប់ គឺជាសាច់ញាតិរបស់មតកជន ដែលអាចជាបច្ឆាញាតិ បុព្វញាតិ សាខាញាតិ។ ក្នុងករណីនេះសន្តតិជន ដែលមាន សន្តតិជនលំដាប់ទី១ ចំណុច **ក** សន្តតិជនលំដាប់ទី២ ចំណុច **ខ** សន្តតិជនដាប់ទី៣ ចំណុច **គ** សន្តតិជនជំនួស ចំណុច **ឃ** សន្តតិជនជានិច្ច ចំណុច **ង**។

#### ៣.១.២.១. សន្តតិជនលំដាប់ទី១ ៖ បច្ឆាញ្ញាតិ

សន្តតិជនលំដាប់ទីមួយ សំដៅទៅលើកូនរបស់មតកជន បើទោះបីជាកូនរបស់មតកជននោះ ជាកូនបង្កើត ឬកូនសុំក្តី ត្រូវតែមានចំណែកមត៌កស្មើៗគ្នា។[82] ត្រង់ចំណុចនេះចង់មានន័យថា មត៌កនឹងត្រូវធ្លាក់ទៅលើទាយាទផ្ទាល់ទាំងឡាយដែលជាបច្ឆាញ្ញាតិ ពោលគឺ កូនដែលមានចំណងបុត្តភាពតាមន័យគតិយុត្តជាមួយ

[81] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧,សន្ទានុក្រមផ្នែករដ្ឋប្បវេណី,ទំព័រ ២១

[82] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៦

មតកជន ដោយរាប់ទាំងកូនក្នុងចំណងអាពាហ៍ពិពាហ៍ កូនឥតខាន់ស្លាដែលត្រូវបានទទួលស្គាល់ដោយមតកជន (កូនស៊ុំពេញលេញ ឬមិនពេញលេញ) របស់មតកជន ហើយចំណែករបស់កូនទាំងនោះត្រូវបានទទួលស្គាល់ស្មើៗគ្នា។ ចំពោះកូនដែលគ្មានចំណងបុត្តភាពគតិយុត្តជាមួយមតកជនជាពិសេសកូនឥតខាន់ស្លាដែលមិនត្រូវបានទទួលស្គាល់ មិនអាចក្លាយជាសន្តតិជនបានទេ។

កូនរបស់មតកជន មានន័យថាជាកូនដែលមានបុត្តភាពត្រូវបានទទួលស្គាល់តាមច្បាប់។ ដូច្នេះចំពោះកូនក្រៅអាពាហ៍ពិពាហ៍ ទោះបីមានទំនាក់ទំនងបិតុភាពក៍ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុត្តភាពតាមច្បាប់ ក៏មិនអាចទទួលស្គាល់បានដែរ ដូច្នេះកូននោះមិនអាចក្លាយជាសន្តតិជនបានទេ។[83]

បច្ឆាញាតិ សំដៅលើញាតិលោហិតជំនាន់ក្រោយ ដូចជាកូនរបស់ខ្លួន និងបុគ្គលជំនាន់ក្រោយដោយរាប់បញ្ចូលទាំងជំនាន់ដូចគ្នានឹងកូនៗទាំងនោះ។ ឧទាហរណ៍ៈ ទំនាក់ទំនងរវាងខ្លួនយើង និងកូន ចៅ ឬកូនក្មួយ ចៅក្មួយ ។ល។ ដែលជាជនដែលស្ថិតនៅក្រោមខ្លួន។

### ៣.១.២.២. សន្តតិជនលំដាប់ទី២ (បុព្វញាតិថ្នាក់ទី១ ឬ ថ្នាក់ទី២)

សន្តតិជនលំដាប់ទី២ គឺជាបុព្វញាតិរបស់មតកជនដែលជិតជាងគេមុន មានន័យថាផ្តល់អាទិភាពទៅឲ្យឪពុកម្តាយរបស់មតកជន មុនជីដូនជីតារបស់មតកជន។ ជាបឋមក្នុងករណីពុំមានបុព្វញាតិលំដាប់ទី១ ប៉ុន្តែមានបុព្វញាតិថ្នាក់ទី២ ជាជីដូនជីតានឹងក្លាយជាសន្តតិជនលំដាប់ទី២។ ក្នុងករណីដែលឪពុកម្តាយរបស់មតកជននៅមានជីវិតរស់នៅទាំងពីរ មត៌កត្រូវបានបែងចែកជាពីរចំណែកស្មើៗគ្នា។ តែបើឪពុក ឬម្តាយរបស់មតកជននៅរស់តែម្ខាង ហើយគ្មានបុព្វញាតិផ្សេងទៀតរស់ នៅមត៌កទាំងអស់ត្រូវធ្លាក់ទៅលើភាគីម្ខាងនោះទាំងអស់ដោយមិនបែងចែកឲ្យអ្នកណាផ្សេងទៀតឡើយ។ ប៉ុន្តែបើគ្មានឪពុក និងម្តាយ នោះមត៌កត្រូវផ្ទេរទៅឲ្យជីដូនជីតាទាំងសងខាងរបស់ ឪពុក និងម្តាយ នូវចំណែកស្មើគ្នា ប្រសិនបើមានបួននាក់ត្រូវបែងចែកជាបួនចំណែក ឬចែកតាមសមាមាត្រនៃចំនួនសន្តតិជននោះ។[84]

### ៣.១.២.៣. សន្តតិជនលំដាប់ទី៣ ( បងប្អូនបង្កើត)

បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់នោះទេ ជនដែលនឹងត្រូវទទួលបានមត៌ក គឺជាបងប្អូនបង្កើតរបស់មតកជននោះ។ ក្នុងករណីបងប្អូនមានចំនួនច្រើន នោះបងប្អូនបង្កើតម្នាក់ៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា ឬមត៌កត្រូវបែងចែកតាមសមាមាត្រនៃចំនួនសមាជិក។ តែបើចំណែករបស់បងប្អូនបង្កើត

[83] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៧-១

[84] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៩

ដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នា នោះចំណែកដែលត្រូវទទួលបានស្មើ ១ភាគ២នៃចំណែករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយទាំងសងខាងដូចគ្នា។[85]

ចំពោះញាតិលោហិតផ្សេងទៀតដូចជា ពូ មីង ឬបងប្អូនជីដូនមួយរបស់មតកជនគ្មានសិទ្ធិទទួលសន្តតិកម្មទេ លើកលែងតែជនដែលមាននិស្ស័យពិសេសជាមួយនឹងមតកជន។[86] ជនដែលមាននិស្ស័យពិសេសមានសិទ្ធិទទួលមត៌កនៅពេលដែលគ្មានសន្តតិជនមកស្នងមត៌ក ហេតុដូចនេះជនដែលមាននិស្ស័យពិសេសអាចដាក់ពាក្យស្នើសុំទៅតុលាការ ដើម្បីសុំធ្វើការបែងចែកមត៌ក។

### ៣.១.២.៤. សន្តតិជនជំនួស

ក្នុងករណីដែលមានបច្ឆាញាតិផ្ទាល់របស់មតកជនបានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបាត់បង់សិទ្ធិសន្តតិកម្មដោយមូលហេតុអភ័ព្វបុគ្គល ឬការកាត់ផ្តាច់មត៌ក នោះកូនរបស់បុគ្គលដែលបានស្លាប់មុនការទទួលមត៌កនោះ អាចឡើងទទួលមត៌កជំនួសឪពុកម្តាយតាមរយៈសន្តតិកម្មជំនួស ក្នុងឋានៈជាសន្តតិជនជំនួស។[87] ប៉ុន្តែប្រសិនបើសន្តតិជនបានទទួលមរណភាពក្រោយពេលចាប់ផ្តើមសន្តតិកម្ម មានន័យថាជននោះបានទទួលសន្តតិកម្មរួចហើយ នោះកូនរបស់សន្តតិជននោះមានសិទ្ធិទទួលសន្តតិកម្មបន្តពីសន្តតិជននោះវិញ ដោយពុំហៅថាសន្តតិជនជំនួសទេ។

ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ពោលគឺបង្ហាញទៅលើកូនស្មុំរបស់មតកជនដែលបានកើតមុនពេលស្មុំ ករណីមតកជនសុំជនដែលមានកូនតាមស្មុំកូនធម្មតា កូនរបស់កូនស្មុំធម្មតានោះមិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ តែបើកូនរបស់កូនស្មុំធម្មតានោះបានកើតក្រោយការស្មុំកូនវិញ កូនដែលកើតនោះត្រូវជាញាតិផ្ទាល់របស់មតកជន ហេតុនេះគេអាចទទួលសន្តតិកម្មជំនួសបាន។[88] ប្រសិនបើកូនរបស់សន្តតិជនជំនួសបានកើតមូលហេតុដូចសន្តតិជន នោះកូនរបស់សន្តតិជនជំនួសត្រូវធ្វើលទ្ធកម្មនូវចំណែកមត៌ករបស់សន្តតិជនជំនួសនោះជាបន្តបន្ទាប់បាន។ ប៉ុន្តែចំពោះសន្តតិជនជំនួសរបស់សន្តតិជនដែលជាបងប្អូនបង្កើតរបស់មតកជនវិញ អាចធ្វើបានត្រឹមតែមួយតំណប៉ុណ្ណោះ ដោយសារតែគិតទៅលើសាច់ឈាមមានលក្ខណៈឆ្ងាយ ហើយពិបាកនឹងការស្វែងរកទៀត។[89]

[85] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦០

[86] សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, ភាគ៩ ទំព័រ ១៩-២០

[87] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៧, មាត្រា ១១៥៨

[88] សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, ភាគ៩ ទំព័រ ១៦

[89] សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, ភាគ៩ ទំព័រ ១៩

ចំពោះចំណែកមត៌កដែលសន្តតិជនជំនួសត្រូវបានទទួល ត្រូវស្មើនឹងចំណែកដែលសន្តតិជនមុនដំបូងត្រូវបានទទួលដែរ។ ប៉ុន្តែក្នុងករណីដែលសន្តតិជនជំនួស មានចំនួនច្រើននាក់ នោះចំណែកដែលត្រូវទទួលបានគឺត្រូវទទួលបានស្មើៗគ្នា ឬបែងចែកតាមសមាមាត្រនៃចំនួនបុគ្គលចំនួសទាំងនោះ។[90]

### ៣.១.២.៥. សន្តតិជនជានិច្ច

សហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ ក៏ប៉ុន្តែ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ ក្នុងករណីដែលជននោះជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬជាបុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ។ ពាក្យថា «ជានិច្ច» នៅក្នុងនេះមានន័យថា គ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេង ព្រមទាំងលំដាប់សន្តតិកម្មទេ។ ម្យ៉ាងទៀត នៅក្នុងមាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ទទួលស្គាល់សហព័ទ្ធជាសន្តតិជន តែក្នុងករណីដែលមតកជនគ្មានបុព្វញាតិផ្ទាល់ បងប្អូនបង្កើត និងបច្ឆាញាតិផ្ទាល់របស់បងប្អូននោះតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ដោយទៅតាមទស្សនៈសមភាពរវាង បុរស និងស្ត្រី ជាអាទិ៍ មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីនេះទទួលស្គាល់ថា សហព័ទ្ធជាសន្តតិជនជានិច្ច។[91] ជាធម្មតា សហព័ទ្ធ មិនជាប់ទំនាក់ទំនងញាតិលោហិតជាមួយមតកជនក៏ពិតមែន ប៉ុន្តែទើបក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបញ្ញត្តថា សហព័ទ្ធរបស់មតកជនជាញាតិ ដោយយោងតាមមាត្រា៩៣៨នៃក្រមរដ្ឋប្បវេណី ២០០៧ ត្រូវបានក្លាយជាសន្តតិជនជានិច្ច។[92]

ប្រសិនបើមានសន្តតិជនផ្សេងទៀតក្នុងលំដាប់ទី ៣ សហព័ទ្ធត្រូវទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននេះ។ ឧទាហរណ៍៖ ក្នុងករណីដែលមតកជនមានកូន ឬមានសន្តតិជនជំនួសនោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយបុគ្គលនោះ ដែលជាសន្តតិជនលំដាប់ទី ២ ទទួលសន្តតិកម្ម ក៏សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយបុគ្គលនោះដែរ។ប្រសិនបើមតកជនណាម្នាក់ គ្មានសន្តតិជនពីលំដាប់ទី ១ ដល់លំដាប់ទី ៣ ទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៦១ កថាខណ្ឌទី១។[93]

## ៣.២. ការអនុវត្តនៃសន្តតិកម្មតាមច្បាប់

ក្រោយពីយើងសិក្សាអំពីសន្តតិជន រួចអស់ហើយ យើងនឹងមកធ្វើការសិក្សាទៅលើ ការយល់ព្រម និងការបោះបង់ចោលសន្តតិកម្ម ក្នុងចំណុច ៣.២.១ និង របបនៃការគ្រប់គ្រងសន្តតិកម្មតាមច្បាប់ ៣.២.២។

[90] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៧, មាត្រា ១១៥៨

[91] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦១-១

[92] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦១

[93] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦១-២

### ៣.២.១.ការយល់ព្រម និងការបោះបង់ចោលសន្តតិកម្ម

បន្ទាប់ពីបានសិក្សានូវជំពូកទី១ រួចមកដែលបានបកស្រាយអំពីការយល់ព្រម និងការបោះបង់សន្តតិកម្ម ប៉ុន្តែដោយហេតុថាចំណុចខាងលើមិនបានរៀបរាប់ ឬបកស្រាយឲ្យបានក្បោះក្បាយ យើងនឹងមកធ្វើការសិក្សានៅចំណុចនេះឲ្យបាន ក្បោះក្បាយ និងលម្អិតនៅចំណុចនេះផងដែរ។

សន្តតិកម្ម គឺជាការទទួលបន្តនូវទំនាក់ទំនងដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិទាំងមូលរបស់មតកជន (ការទទួលបន្តទាំងស្រុង)។ ក្នុងការករណីដែលមតកជនបានជាប់បំណុលមុនពេលទទួលមរណភាព បំណុលនោះក៏ត្រូវគិតបញ្ចូលទៅក្នុងមត៌កដែរ។ អាស្រ័យលើកាលៈទេសៈនីមួយៗមានពេលខ្លះបំណុលអាចច្រើនជាងទ្រព្យសម្បត្តិទៅទៀត។ ក្នុងករណីនេះទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ទទួលស្គាល់នូវជម្រើសបីដល់សន្តតិជនៈ

- បដិសេធន៍ទាំងស្រុង នូវការទទួលបន្តទ្រព្យសម្បត្តិ (ការបោះបង់សន្តតិកម្ម)
- ទទួលយកទាំងស្រុងនូវការទទួលបន្តទ្រព្យសម្បត្តិ (ការយល់ព្រមទាំងស្រុង)
- ទទួលខុសត្រូវលើសំណងកាតព្វកិច្ចជាអវិជ្ជមានផ្សេងៗ ត្រឹមកម្រិតនៃទ្រព្យសម្បត្តិជាវិជ្ជមាន ដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ (ការយល់ព្រមដោយមានកម្រិត) ជាការពិតប្រាកដណាស់ វាមិនអាចមានជម្រើសទទួលតែទ្រព្យសម្បត្តិជាវិជ្ជមានដោយមិនទទួលខុសត្រូវលើបំណុលបានទេ។

សន្តតិជនត្រូវធ្វើការជ្រើសរើសមួយក្នុងចំណោមជម្រើសទាំងបីខាងលើនេះ ក្នុងអំឡុងពេលបីខែ អំឡុងពេលសម្រាប់ពិចារណា គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។[94]

#### ៣.២.១.១. ការយល់ព្រមមានកម្រិតៈ

ការយល់ព្រមដោយមានកម្រិតមានខ្លឹមសារថា ធ្វើសកម្មភាពនៃសន្តតិកម្មដែលបម្រុងសម្រាប់កាតព្វកិច្ចនឹងទទួលដោយសន្តតិកម្ម ត្រឹមកម្រិតទទួលដោយសន្តតិកម្ម មានន័យថា សន្តតិជនក្លាយជាកូនបំណុល ដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបាន ត្រឹមកម្រិតនៃមត៌ក លើកលែងតែសន្តតិជនសងកាតព្វកិច្ចដោយស្ម័គ្រចិត្ត (ចំណែកនៃកាតព្វកិច្ចដែលលើសពីមត៌កសកម្ម គេហៅថាជាកាតព្វកិច្ចធម្មជាតិ)។ មួយវិញទៀត ក្នុងករណីមានសហសន្តតិជន ការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងរួមគ្នា និងយល់ព្រមដោយមានកម្រិតចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជីដើម្បីឲ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ហើយសហសន្តតិជនត្រូវឯកភាពគ្នាក្នុងការសងនោះពីព្រោះ ប្រសិនបើមានសន្តតិជនមួយចំនួនយល់ព្រម ហើយបានអះអាងនូវចំណែកមត៌ក ការជម្រះបញ្ជីនូវមត៌កទាំងអស់នឹងមិនអាចធ្វើទៅបាន។ ផ្ទុយទៅវិញ ប្រសិនបើសន្តតិជនមួយចំនួនបានបោះបង់សន្តតិ

[94] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៩១៥

កម្ម នោះគ្មានបញ្ហានោះទេ ពីព្រោះជនដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង ហេតុនេះ សន្តតិជនដែលនៅសល់អាចយល់ព្រមដោយកម្រិតរួមគ្នាបាន លើកលែងតែសន្តតិជនមួយចំនួនក្នុងចំណោមសន្តតិជនដែលយល់ព្រមដោយមានកម្រិត ដោយមានមូលហេតុដែលមានកំណត់នៅក្នុងមាត្រា ១២៥៩ (ការយល់ព្រមដោយមានកម្រិត កើតឡើងមុនការយល់ព្រមដោយតាមច្បាប់) ជាហេតុនាំឲ្យត្រូវទទួលខុសត្រូវដូចគ្នានឹងការយល់ព្រមទាំងស្រុង និងប្រសិនបើមានស្ថានភាពបែបនេះមែន មត៌កទាំងអស់ត្រូវឆ្លងកាត់តាមនីតិវិធីជម្រះបញ្ជី ដូច្នេះសន្តតិជនដែលនឹងត្រូវទទួលខុសត្រូវតាមមាត្រា ១២៥៩ មិនអាចអះអាងថាខ្លួនមានចំណែកមត៌កសកម្ម ខណៈពេលដែលមិនទាន់បញ្ចប់នីតិវិធីនៃការជម្រះបញ្ជីឡើយ។[95] លើសពីនេះទៅទៀត ដើម្បីធ្វើតាមរបៀបដែលមានកំណត់ដូចតទៅ៖

ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវដាក់ពាក្យសុំតុលាការក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃដែលដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន ប៉ុន្តែអំឡុងពេលនេះអាចពន្យាបានដោយមានការអនុញ្ញាតពីតុលាការតាមរយៈពាក្យសុំរបស់សាមីខ្លួន។ មួយវិញទៀត ក្នុងករណីសហសន្តតិកម្ម សហសន្តតិជនទាំងអស់ត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការយល់ព្រមដោយមានកម្រិត ដែលការគណនាអំឡុងពេលត្រូវគិតចាប់ពីថ្ងៃសន្តតិជនដែលដឹងអំពីការចាប់ផ្តើមសន្តតិកម្មក្រោយគេ។ នៅពេលដែលដាក់ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមត៌ក ដោយបញ្ជាក់អំពីមត៌កសកម្ម និងមត៌កអកម្មដែលសន្តតិជនបានទទួល នៅពេលចាប់ផ្តើមសន្តតិកម្ម ក្នុងកម្រិតលទ្ធភាពដែលខ្លួនបានដឹង និងប្រសិនបើមិនបានបញ្ជាក់ឲ្យច្បាស់លាស់ដោយចេតនា ត្រូវចាត់ទុកថាយល់ព្រមទាំងស្រុង។[96]

អានុភាពនៃការយល់ព្រមដោយមានកម្រិត ដែលមានខ្លឹមសារថាម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឲ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ។ ទោះបីជាដូច្នេះក៏ដោយ តាមគោលការណ៍មត៌កត្រូវធ្លាក់ទៅសន្តតិជន ប៉ុន្តែជាលក្ខណៈសារជាតុទ្រព្យសម្បត្តិជាមត៌កត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជនមិនអាចរលត់ដោយព្យាកុលនោះទេ។[97]

ការយល់ព្រមមានកម្រិត កើតឡើងមុនការយល់ព្រមតាមច្បាប់៖ ចំពោះសន្តតិជនដែលត្រូវបានយល់ព្រមដោយមានកម្រិត ប្រសិនបើមានមូលហេតុដែលជាការទទួលខុសត្រូវទាំងស្រុងតាមផ្លូវច្បាប់ ផលប្រយោជន៍នៃការយល់ព្រមដោយមានកម្រិតត្រូវបាត់បង់ ហើយសន្តតិជនត្រូវទទួលខុសត្រូវដូចគ្នានឹងអ្នកយល់

[95] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៦
[96] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៧
[97] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៨

ព្រមទាំងស្រុង។ ក្នុងករណីជាសហសន្តតិជន ហើយសន្តតិជនម្នាក់ ឬច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងនោះ មានមូលហេតុនៃការយល់ព្រមទាំងស្រុង នាំឲ្យធ្វើការជម្រះបញ្ជីមត៌កជាមុនសិន បន្ទាប់មកប្រសិនបើខ្វះខាត អាចយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់មកសងបន្ថែម។ ចំពោះកម្រិតនៃការទទួលខុសត្រូវនេះ ទោះបីជាមានការយល់ព្រមដោយកម្រិតក៏ដោយសហសន្តតិជនត្រូវទទួលបន្តនូវកាតព្វកិច្ចរបស់មតកជនទៅតាមចំណែកមត៌ក ប៉ុន្តែការទទួលខុសត្រូវមានកម្រិតត្រឹមកម្រិតមត៌កប៉ុណ្ណោះ ហេតុនេះម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនណាម្នាក់ ឬច្រើននាក់ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលតាមចំណែកមត៌កនីមួយៗនោះបាន។[98]

**៣.២.១.២. ការយល់ព្រមទាំងស្រុង**

ក្នុងករណីដែលសន្តតិជនទទួលយល់ព្រមទាំងស្រុងនូវសន្តតិកម្ម មានន័យថា សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយតម្រូវឲ្យបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ មានសេចក្តីថា មិនចាំបាច់ដាក់ពាក្យសុំទៅតុលាការ ដូចករណីយល់ព្រមដោយមានកម្រិត ឬបោះបង់សន្តតិកម្មនោះឡើយ។[99] មួយវិញទៀតប្រសិនបើសន្តតិជន បានធ្វើសកម្មភាពណាមួយក្នុងសកម្មភាពខាងក្រោមនេះ ត្រូវចាត់ទុកថាយល់ព្រមទាំងស្រុង (ការយល់ព្រមទាំងស្រុងតាមផ្លូវច្បាប់)៖

- សន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ លើកលែងតែសកម្មភាពរក្សា ឬគ្រប់គ្រង។
- សន្តតិជនមិនបានបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ នៅក្នុងអំឡុងពេល ០៣ (បី)ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម លើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការ។
- ទោះបីជាសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ក៏ដោយ ប៉ុន្តែសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន លើកលែងតែនៅក្រោយពេលដែលជនដែលត្រូវបានសន្មតជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ដោយហេតុថា ក្នុងករណីសន្តតិជននៃលំដាប់បន្ទាប់បានយល់ព្រម សន្តតិកម្មនេះបានឲ្យទៅសន្តតិជនលំដាប់បន្ទាប់នោះ ដើម្បីមានសន្ទនាភាព និងសង្គតិភាពតាមផ្លូវច្បាប់ ហេតុនេះប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពបែបនេះ

[98] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៩

[99] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៤

សន្តតិជនលំដាប់បន្ទាប់អាចធ្វើការទាមទារឲ្យសន្តតិជនលំដាប់មុនប្រគល់មត៌កវិញ ឬទាមទារឲ្យសងសំណងនៃការខូចខាត។[100]

#### ៣.២.១.៣.ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវធ្វើសេចក្តីថ្លែងការណ៍ពីការបោះបង់សន្តតិកម្ម ដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេល ដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម លើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការ។[101] បុគ្គលដែលបានបោះបង់សន្តតិកម្មត្រូវចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក។[102]

### ៣.២.២.របបនៃការគ្រប់គ្រងសន្តតិកម្មតាមច្បាប់

បន្ទាប់ពីបានសិក្សាលើចំណុចការយល់ព្រម និងការបោះបង់សន្តតិកម្មរួចមក យើងនឹងមកធ្វើការសិក្សាទៅលើ ការសម្រួលមត៌ករវាងម្ចាស់បំណុល ចំណុច ៣.២.២.១ ការគ្រប់គ្រងមត៌ក ចំណុច ៣.២.២.២ និង ស្ថានភាពពិសេសនៃសន្តតិកម្ម ចំណុច ៣.២.២.៣ ។

#### ៣.២.២.១.ការសម្រួលរវាងម្ចាស់បំណុល

ក្នុងករណីមតកជនមានសិទ្ធិលើបំណុល ឬកាតព្វកិច្ច តើត្រូវធ្វើសន្តតិកម្មទាំងអស់នោះ យ៉ាងដូចម្តេច? សិទ្ធិលើបំណុល និងកាតព្វកិច្ច មានប្រភេទដូចតទៅៈ

- សិទ្ធិលើបំណុលដែលអាចបែងចែកបាន
- កាតព្វកិច្ចដែលអាចបែងចែកបាន
- សិទ្ធិលើបំណុលអវិភាគីយ៍
- កាតព្វកិច្ចអវិភាគីយ៍

សហសន្តតិជនត្រូវទទួលបន្តសិទ្ធិលើបំណុលដែលអាចបែងចែកបានរបស់មតកជនតាមសមាមាត្រនៃចំណែកមត៌កនោះ។[103]

ចំពោះសិទ្ធិលើបំណុលដែលអាចបែងចែកបាន គឺសន្តតិជនអាចយកមកធ្វើជាកម្មវត្ថុនៃការបែងចែកមត៌ក។ មានន័យថា នៅក្នុងការពិភាក្សាបែងចែកមត៌ក សន្តតិជន អាចធ្វើការបែងចែកសិទ្ធិលើបំណុលដែលអាចបែងចែកបាន ដោយភាគខុសគ្នានឹងចំណែកមត៌កដែលច្បាប់បានកំណត់។ សហសន្តតិជន ត្រូវទទួលបន្តកាតព្វកិច្ចដែលអាចបែងចែកបានរបស់មតកជន តាមសមាមាត្រនៃចំណែកមត៌កនោះ។ ចំពោះកាតព្វកិច្ចដែល

[100] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៥
[101] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦០
[102] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦១
[103] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៨

អាចបែងចែកបាន គឺសន្តតិជនមិនអាចយកមកធ្វើជាកម្មវត្ថុនៃការបែងចែកមត៌កបានទេ។ មានន័យថា សន្តតិជនមិនអាចធ្វើការបែងចែកកាតព្វកិច្ចដែលអាចបែងចែកបានដោយភាគខុសគ្នាជាមួយនឹងចំណែកមត៌កដែលច្បាប់បានកំណត់ទេ។[104]

សិទ្ធិលើបំណុលអវិភាគីយ៍ គឺជាសិទ្ធិលើបំណុលដែលមិនអាចបែងចែកបានតាមលក្ខណៈនៃសិទ្ធិ។ សហសន្តតិជន ត្រូវទទួលបន្តសិទ្ធិលើបំណុលអវិភាគីយ៍ ដោយអវិភាគីយ៍។ កាតព្វកិច្ចអវិភាគីយ៍ គឺជាកាតព្វកិច្ចដែលមិនអាចបែងចែកបានតាមលក្ខណៈនៃសិទ្ធិ។ សហសន្តតិជន ត្រូវទទួលបន្តកាតព្វកិច្ចអវិភាគីយ៍ ដោយអវិភាគីយ៍។

ទោះបីជាមតកជនបានទទួលមរណភាពហើយក៏ដោយ ក៏កាតព្វកិច្ចរបស់មតកជន នៅតែបន្តមានដដែល ហើយបានបន្តទៅឲ្យសន្តតិជនទាំងអស់ ទៅតាមសមាមាត្រនៃចំណែកមត៌កដែលសន្តតិជននីមួយៗបានទទួលនោះ ដែលគោលការណ៍មួយនេះហៅថា គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះម្ចាស់បំណុលនៃមតកជនមានសិទ្ធិអនុវត្តលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្ម តាមរយៈការហាមឃាត់មិនឲ្យសន្តតិជនផ្ទេរកម្មសិទ្ធបាន ដោយម្ចាស់បំណុលអាចទាមទារឲ្យជ្រើសតាំងអ្នកគ្រប់គ្រងបណ្ដោះអាសន្នក្នុងការរក្សាគ្រប់គ្រងមត៌កទាំងអស់នោះ លុះត្រាតែគ្មានអ្នកប្រតិបត្តិមតកសាសន៍ ក៏បញ្ជាក់ឲ្យឃើញបានដែលថា ម្ចាស់បំណុលគ្មានសិទ្ធិក្នុងការគ្រប់គ្រងផ្ទាល់ទៅលើមត៌ករបស់មតកជននោះទេ។

វិធានសម្របសម្រួលនេះ សំដៅការពារផលប្រយោជន៍របស់ម្ចាស់បំណុល ប៉ុន្តែប្រសិនបើសន្តតិជនបានបោះបង់សន្តតិកម្ម ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ដូចដែលបានរៀបរាប់ខាងលើនោះទេ ហើយសន្តតិជនក៏មិនអាចទទួលចំណែកមត៌កបាននោះដែរ។ មួយវិញទៀត ក្នុងករណីសន្តតិជនបានយល់ព្រមដោយកម្រិតសន្តតិជនត្រូវជូនដំណឹងជាសាធារណៈ អំពីការយល់ព្រមដោយកម្រិតនេះទៅម្ចាស់បំណុលក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយកំណត់ផងដែរនូវអំឡុងពេលជាក់លាក់មួយសម្រាប់ម្ចាស់បំណុលដាក់ពាក្យស្នើសុំ និងចាប់ផ្ដើមឲ្យមាននីតិវិធីជម្រះបញ្ជី។[105] ដែលតម្រូវឲ្យសន្តតិជននោះ នឹងមានកាតព្វកិច្ចគ្រប់គ្រងមត៌កឲ្យបានល្អ ព្រមទាំងនឹងទទួលចំណែកមត៌កសកម្មដែលបាននៅសល់ក្រោយការជម្រះបញ្ជី។[106] ផ្ទុយទៅវិញ ក្នុងករណីមិនបានស្នើសុំនោះ ក្នុងអំឡុងពេលដែលបានកំណត់នោះទេ ម្ចាស់បំណុលនោះនឹងត្រូវបាត់បង់ផលប្រយោជន៍អំពីបំណុលរបស់ខ្លួន ព្រោះសន្តតិជនអាចមិនសងលើបំណុលនោះ ព្រោះខ្លួនមិនមានឈ្មោះក្នុងការជម្រះបញ្ជីនោះទេ។[107]គួរ

[104] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៨

[105] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨១-១

[106] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨០

[107] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១៣០៤-២

បញ្ជាក់ផងដែរថា ករណីខាងលើមិនមានប្រសិទ្ធភាព ទៅលើម្ចាស់បំណុលដែលបានភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្សដូចជា ហ៊ីប៉ូតែក ជាអាទ៍ ។ ក្រោយពីអំឡុងពេលដែលបានដាក់នោះផុតកំណត់ហើយ សន្តតិជនដែលយល់ព្រមដោយកម្រិតនោះ មានកាតព្វកិច្ចសងឲ្យម្ចាស់បំណុលទាំងអស់ដែលខ្លួនបានដឹងឮ តាមសមាមាត្រនៃចំណែកមត៌កដែលខ្លួនបានទទួលធៀបនឹងបំណុលនោះ។[108] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញត្តិអំពីម្ចាស់បំណុលដែលមានសិទ្ធអាទិភាពមានលំដាប់ដូចខាងក្រោមនេះ ៖

ទី១ ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាព ។ ទី២ ម្ចាស់បំណុលដែលបានដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ។ ទី៣ អច្ច័យលាភីដែលបានដាក់ពាក្យស្នើសុំនៅអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ ។ ទី៤ ម្ចាស់បំណុល និងអច្ច័យលាភី ដែលមិនបានស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ ។[109]

ក្នុងករណីដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មដោយកម្រិតហើយ វាបង្កើតឲ្យម្ចាស់បំណុលបង្កើតនូវសិទ្ធិទទួលបានសំណងដែលជម្រះបញ្ជីនោះ ទោះបីជាមិនទាន់ដល់ពេលកំណត់សងក៏ដោយ។[110] ការសងបំណុលត្រូវធ្វើការសងទៅឲ្យម្ចាស់បំណុលមុននឹងសងទៅឲ្យអច្ច័យលាភី។[111] ក្នុងករណីដែលតម្រូវឲ្យសងតាមរយៈការលក់មត៌កដោយបង្ខំ ឬលក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែលត្រូវបានជ្រើសតាំងដោយតុលាការ ម្ចាស់បំណុលនិងអច្ច័យលាភីមានសិទ្ធិក្នុងការទិញមត៌កនោះ។[112] បើក្នុងករណី សន្តតិជនជាច្រើនបានយល់ព្រមដោយមានកម្រិតចំពោះសន្តតិកម្មនោះ វាជាតួនាទីរបស់តុលាការ ក្នុងការជ្រើសតាំងសន្តតិជនម្នាក់ក្នុងចំណោមអ្នកទាំងនោះជាអ្នកគ្រប់គ្រងចំណែកមត៌ក ដោយរួមទាំងការសងបំណុលក្នុងជាផលប្រយោជន៍របស់ខ្លួនឯង និងសន្តតិជនទាំងអស់ផងដែរ។[113]

### ៣.២.២.២.ការគ្រប់គ្រងមត៌ក

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្មមិនអាចមិនមានការគ្រប់គ្រងនោះទេ នៅមុនពេលដែលសន្តតិជនសម្រេចចិត្តក្នុងការទទួលយក ឬធ្វើការបោះបង់ចោលនូវសិទ្ធិក្នុងការទទួលបានចំណែកមត៌ករបស់ខ្លួន។ ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិអំពីអ្នកទទួលបន្ទុកគ្រប់គ្រងចំណែកមត៌កនោះដូចខាងក្រោមនេះ ៖

[108] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨៣

[109] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨៣-២ និង១២៨៥

[110] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨៤

[111] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨៥

[112] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨៦

[113] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៨៩

ទី១៖ ការរក្សាទុក និងគ្រប់គ្រងដោយសន្តតិជនមានន័យថា ក្រោយពេលមតកជនបានទទួលមរណភាពទៅសន្តតិជនរូបណាដែលបានធ្វើការកាន់កាប់ទ្រព្យសម្បត្តិរបស់មតកជននោះនឹងធ្វើការរក្សាទុក និងគ្រប់គ្រងមត៌ករហូតបានធ្វើការបែងចែករួចហើយ ក្នុងឋានៈជាអ្នកគ្រប់គ្រងសុចរិត។[114] មួយវិញទៀត ទោះបីជាសន្តតិជនរូបនោះបានបោះបង់ចំណែកមត៌ករបស់ខ្លួនក៏ដោយក៏កាតព្វកិច្ចនេះមិនអាចទម្លាក់ចោលបានដែរ។[115] ក្នុងករណី ចំណែកមត៌កដែលជាចំណែកសហសន្តតិជននោះ ត្រូវមានការរក្សា និងគ្រប់គ្រងចំណែកមត៌កជាមួយគ្នា មិនមែនជាកាតព្វកិច្ចរបស់សន្តតិជនតែម្នាក់នោះទេ។[116]

ទី២៖ ក្នុងករណី មានអ្នកប្រតិបត្តិមតកសាសន៍ ដែលជាអ្នករក្សាគ្រប់គ្រងលិខិតមតកសាសន៍ដោយអនុលោមតាមមាត្រា១២១៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ អ្នកប្រតិបត្តិមតកសាសន៍នោះជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់មតកជននោះ ។ ក្នុងចំណុចនេះ ដោយវាផ្តោតទៅលើចំពោះតែករណីដែលមានមតកសាសន៍ ហើយបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ប៉ុណ្ណោះ ដូច្នេះ អ្នកគ្រប់គ្រងនោះ គឺត្រូវតែជាអ្នកប្រតិបត្តិមតកសាសន៍នោះតែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើមតកសាសន៍បានបញ្ញត្តិផ្សេង ឬមានលក្ខណៈច្បាស់លាស់ទៅលើទ្រព្យសម្បត្តិណាមួយដែលបានកំណត់ឲ្យអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិក្នុងការរក្សាត្រឹមកម្រិតណា។[117]

ទី៣៖ ការគ្រប់គ្រងមត៌ក ដែលចាត់តាំងដោយតុលាការ ប្រសិនបើ គ្មានករណីទាំងពីរខាងលើនោះទេពោលគឺគ្មានអ្នកគ្រប់គ្រងមត៌ក និងគ្មានអ្នកប្រតិបត្តិមតកសាសន៍ តុលាការមានឆន្ទានុសិទ្ធិក្នុងការកំណត់អ្នកគ្រប់គ្រង លុះត្រាតែបានបែងចែកចំណែកមត៌ករួចរាល់ហើយ ឬក៏មានការព្រមព្រៀងចំពោះមត៌ក តាមរយៈពាក្យស្នើសុំពីសន្តតិជន ឬអច្ច័យលាភី ឬម្ចាស់បំណុលរបស់មតកជន ប៉ុន្តែការគ្រប់គ្រងរបៀបនេះ ជាការគ្រប់គ្រងបណ្តោះអាសន្ន។[118] រាល់សោហ៊ុយក្នុងការគ្រប់គ្រងនេះ ត្រូវកាត់ពីទ្រព្យសម្បត្តិរបស់មតកជននោះ ប៉ុន្តែបើជាកំហុសរបស់សន្តតិជន សន្តតិជននោះត្រូវទទួលខុសត្រូវដោយខ្លួនឯង។[119]

ការងារសំខាន់របស់អ្នកគ្រប់គ្រងមត៌ក គឺត្រូវក្តាប់ឲ្យដឹងអំពីមត៌កទាំងអស់ និងការសងបំណុលរបស់មតកជន ហើយនឹងការបែងចែកមត៌កដែលនៅសល់ទៅឲ្យអ្នកដែលមាននិស្ស័យពិសេស ឬបង្វិលមត៌កនោះទៅ

[114] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦២-១
[115] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦២-២
[116] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦២
[117] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦៣
[118] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦៤
[119] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦៥

ឲ្យរដ្ឋ។ អ្នកគ្រប់គ្រងមត៌កធ្វើសកម្មភាពគ្រប់គ្រងក្នុងនាមជាអ្នកតំណាងនីតិបុគ្គលមត៌ក ដែលអ្នកគ្រប់គ្រងនេះត្រូវមានសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដូចតទៅ៖

- ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ
- គ្រប់គ្រង ថែរក្សាមត៌ក ហើយបើមានការចាំបាច់អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬអាចចាត់ចែងមត៌កនោះ ដោយទទួលការអនុញ្ញាតពីតុលាការ។
- ករណីយកិច្ចធ្វើការរាយការណ៍ជូនម្ចាស់បំណុលរបស់មតកជន ឬអច្ច័យលាភី បើមានការទាមទារ
- ករណីយកិច្ចដាស់តឿន ក្រើនរំលឹក ចំពោះម្ចាស់បំណុលជាអាទិ៍

អ្នកគ្រប់គ្រងមត៌កអាចទទួលបានកម្រៃ តាមរយៈតុលាការដោយគិតពិចារណាទៅលើស្ថានភាពនៃមត៌ក និងស្ថានភាពផ្សេងទៀត ក្នុងករណីគ្មានសន្តតិជន។[120]

### ៣.២.២.៣.ស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់

ស្ថានភាពពិសេសនៃសន្តតិកម្ម គឺជាករណីដែលសន្តតិកម្មចាប់ផ្តើមដោយគ្មានសន្តតិជនដែលជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចរបស់មត៌ក ដោយតម្រូវឲ្យមានការស្វែងរកសន្តតិជន ដើម្បីមកស្នងមត៌កទាំងនោះ ហើយប្រសិនបើក្នុងករណីគ្មានសន្តតិជនទេនោះ មត៌កទាំងអស់នោះបានទៅជនដែលមាននិស្ស័យពិសេស។

ម្យ៉ាងវិញទៀតស្ថានភាពពិសេសនៃសន្តតិកម្មអាចកើតឡើងបាន ក្នុងករណីជនមកពីខាងក្រៅហាក់ដូចជាសន្តតិជន បានស្នងមត៌ក និងកាន់កាប់មត៌កនោះ ដោយគ្មានមូលហេតុគតិយុត្តត្រឹមត្រូវ ដែលជាហេតុនាំឲ្យធ្វើបដិទានសន្តតិកម្មបានផងដែរ។

ក្នុងករណីមួយចំនួន ចំពោះសន្តតិកម្មខ្លះគ្មានសន្តតិជននោះទេ ដែលជាហេតុនាំឲ្យត្រូវការស្វែងរកសន្តតិជនមកស្នងមត៌កទាំងអស់នោះ និងក្នុងករណីផ្សេងទៀតនោះ គឺគ្មានសន្តតិជនតែម្តង ដែលធ្វើឲ្យមត៌កទាំងអស់ត្រូវធ្លាក់ទៅលើជនមាននិស្ស័យពិសេស (នត្ថិភាពសន្តតិជន) ដែលសិក្សាក្នុងចំណុច ក។ មួយវិញទៀត ប្រសិនជាមានជនដទៃដែលហាក់ដូចជាសន្តតិជន ហើយបានទទួលមត៌ករួចហើយ តែគ្មានមូលហេតុគតិយុត្តណាមួយក្នុងការទទួលសន្តតិកម្មនោះទេ ដែលនាំឲ្យសន្តតិជនទាមទារឲ្យមានការធ្វើបដិទានសន្តតិកម្មមកវិញ ដែលសិក្សាក្នុងចំណុច ខ។

#### ក. នត្ថិភាពនៃសន្តតិជន

##### ក.១. នីតិបុគ្គលមត៌ក

[120] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១

ប្រសិនបើករណីពុំច្បាស់ថាមានសន្តតិជនទេ មត៌កនឹងត្រូវក្លាយជានីតិបុគ្គល មានន័យថា បើគ្មានសន្តតិជនទេ ប្រធាននៃសិទ្ធិ និងកាតព្វកិច្ចលើមត៌កក៏មិនមានដែរ ហើយចំពោះអចលនវត្ថុត្រូវធ្លាក់ទៅជាកម្មសិទ្ធិរដ្ឋ[121] រីឯចលនវត្ថុវិញ អ្នកដែលបានកាន់កាប់មុនអាចក្លាយទៅជាកម្មសិទ្ធិករនៃចលនវត្ថុនោះ។[122] ហេតុនេះម្ចាស់បំណុលរបស់មតកជននឹងមានការលំបាកក្នុងការទទួលការសង ហើយធ្វើឲ្យមានភាពច្របូកច្របល់នៅក្នុងទំនាក់ទំនងគតិយុត្តរបស់សង្គម ដែលជាមូលហេតុត្រូវចាត់ទុកមត៌កជានីតិបុគ្គល ហើយធ្វើឲ្យនីតិបុគ្គលនោះ ក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចនៃមត៌ក បន្ទាប់មកអាចធ្វើការជម្រះបញ្ជីដើម្បីសងបំណុលជាអាទិ៍។

ក្នុងករណីពុំបានដឹងច្បាស់ថាមានសន្តតិជនទេ មត៌កត្រូវចាត់ទុកថាជានីតិបុគ្គលតាមផ្លូវច្បាប់ដោយស្វ័យប្រវត្តិ ក៏ប៉ុន្តែគ្មានអ្នកគ្រប់គ្រង ហេតុនេះតម្រូវឲ្យតុលាការត្រូវជ្រើសរើសតាំងអ្នកគ្រប់គ្រងមត៌កនោះ តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬមេឃុំ/ចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ។ អ្នកគ្រប់គ្រងមត៌ក គឺមានតួនាទីសងបំណុលទៅឲ្យម្ចាស់បំណុល ហើយការបែងចែកមត៌កឲ្យទៅជនដែលមាននិស្ស័យពិសេស ឬបង្វិលមត៌កនោះទៅឲ្យរដ្ឋ និងដើម្បីអាចបំពេញការងារនេះបានក្នុងករណីចាំបាច់ត្រូវចាត់ចែងប្តូរជាប្រាក់ ដោយទទួលការអនុញ្ញាតពីតុលាការ។ ក្រោយពីជ្រើសតាំងអ្នកគ្រប់គ្រងហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នេះ ដោយគ្មានការយឺតយ៉ាវឡើយ។[123]

ម្យ៉ាងវិញទៀត គោលបំណងនៃការបង្កើតរបបគតិយុត្តិស្តីពីនីតិបុគ្គលមត៌ក គឺការជម្រះបញ្ជីមត៌ក ហេតុនេះជាបឋម មត៌កត្រូវយកទៅសងម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភី ដោយត្រូវជូនដំណឹងជាសាធារណៈទៅឲ្យម្ចាស់បំណុល ឬអច្ច័យលាភីជាអាទិ៍ ហើយតាមរយៈការជូនដំណឹងនេះ គេអាចដឹងថាមតកជនបានជ្រើសតាំង ប្រសិនបើមានសន្តតិជន សន្តតិជនអាចដឹងថាសន្តតិកម្មបានចាប់ផ្តើមតាមរយៈការជូនដំណឹងនេះ។ ផ្ទុយទៅវិញករណីដែលគ្មានសន្តតិជនចេញមកបង្ហាញខ្លួន តាមរយៈការប្រកាសជាសាធារណៈដើម្បីស្វែងរកសន្តតិជន នឹងនាំឲ្យមានភាពចាំបាច់នៃការដកហូតសិទ្ធិរបស់សន្តតិជន ដើម្បីអាចបើកផ្លូវទៅរកការបែងចែកមត៌កទៅឲ្យសន្តតិជនដែលមាននិស្ស័យពិសេស មានន័យថាសន្តតិជននឹងត្រូវដកហូតសិទ្ធិ បន្ទាប់ពីមតកជនបានទទួលមរណភាព ដោយលក្ខខណ្ឌនៃការប្រកាសជាសាធារណៈត្រូវបានគោរព គឺរយៈពេល ០៨ ខែយ៉ាងតិច (០២ខែបន្ទាប់ពីបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កតាមរយៈការប្រកាសជាសាធារណៈ និងត្រូវប្រកាសជាសាធារណៈស្វែងរកសន្តតិជនមិនឲ្យតិចជាង ០៦ ខែ)។ ដោយឡែកក្នុងករណីបានដឹងច្បាស់អំពីសន្តតិជន នោះនីតិ

[121] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១៦១

[122] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១៨៤

[123] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៩១

បុគ្គលមត៌ក ត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង។ ដូច្នេះសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងត្រូវរលត់នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម អ្នកគ្រប់គ្រងត្រូវបង្ហាញឲ្យបានច្បាស់លាស់នូវស្ថានភាពដែលខ្លួនបានគ្រប់គ្រងមត៌ក។[124]

### ក.២. ចំណែកជនដែលមាននិស្ស័យពិសេស

ជនដែលមានជីវភាពរស់នៅជាមួយមតកជន ជនដែលបានខិតខំមើលថែ ព្យាបាលមតកជន ត្រូចចាត់ទុកថាជាជនមាននិស្ស័យពិសេស ទោះបីជាគ្មានទំនាក់ទំនងញាតិជាមួយមតកជនក៏ដោយ។ ក្នុងករណីអ្នកដែលជាជនមាននិស្ស័យពិសេសចង់បែងចែកចំណែកមត៌ក ជននោះត្រូវធ្វើការស្នើសុំទៅតុលាការ ទាមទារចំណែកមត៌កដែលមិនលើសពីពាក់កណ្តាលនៃចំណែកមត៌កទាំងអស់ក្រោយពីជម្រះបញ្ជីនោះទេ។[125] ថេរវេលានៃការស្នើសុំរបស់ជនដែលមាននិស្ស័យពិសេស គឺ ៣ (បី) ខែគិតចាប់ពីពេលស្វែងរកសន្តតិជនបានផុតទៅ។[126]

### ក.៣. មត៌កដែលក្លាយជារបស់រដ្ឋ

ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃសន្តតិកម្ម ហើយពុំមានសន្តតិជនស្នងលើអចលនវត្ថុនោះទេ វានឹងក្លាយជាសម្បត្តិរបស់រដ្ឋ ចំណែកមត៌កសល់ពីការបែងចែកទៅឲ្យជនដែលមាននិស្ស័យពិសេស នឹងក្លាយជារបស់រដ្ឋជថដែរ។[127]

### ខ. បដិទានសន្តតិកម្ម

ការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម មានលក្ខណៈខុសគ្នានឹងករណីសន្តតិជនធ្វើការទាមទារដើម្បីយកមត៌កមកវិញ ដោយសារតែតតិយជនដែលមិនពាក់ព័ន្ធបានកាន់កាប់មត៌កនោះដោយគ្មានសិទ្ធិដែលនាំឲ្យមូលហេតុគតិយុត្តនៃការកាន់កាប់ ហើយការទាមទារដើម្បីយកមត៌កមកវិញ គឺជាការទាមទារតាមបញ្ញត្តិស្តីពីសិទ្ធិប្រត្យក្ស ជាអាទិ៍ ដែលមិនមែនជាខ្លឹមសារនៃការទាមទារក្នុងការធ្វើបដិទានសន្តតិកម្មឡើយ ព្រោះការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម ជាស្ថានភាពអ្នកមានសិទ្ធិអាចទាមទារចំពោះជនដែលបានទទយលមត៌កតាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឲ្យប្រគល់មកវិញនូវទ្រព្យដែលបានទទួលនោះ ដោយហេតុថា ជនដែលគេយល់ឃើញថាសន្តតិជនតាមសភាពខាងក្រៅ កំពុងកាន់កាប់មត៌កដោយមូលហេតុទទួលសន្តតិកម្មដោយទុកសិទ្ធិឲ្យសន្តតិជនពិតប្រាកដធ្វើការទាមទារយកមត៌កនោះមកវិញ។

ការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម ជាការទាមទាររបស់សន្តតិជនឲ្យប្រគល់ត្រលប់មកវិញនូវសន្តតិកម្មដែលខ្លួនត្រូវដកហូតសិទ្ធិសន្តតិកម្ម។ សន្តតិជនអាចទាមទារចំពោះទ្រព្យដែលបានទទួលនោះ។

---

[124] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៩៥

[125] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៩៩-១

[126] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៩៥-២

[127] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១៣០០

ការធ្វើបដិទាននឹងមានអានុភាពលុះត្រាតែសន្តតិជនដែលមានសិទ្ធិទាមទារ ហើយអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេលកំណត់មួយ។ ក្នុងការទាមទារនេះភាគីម្ខាងទៀតនៃការទាមទារត្រូវប្រគល់នូវមត៌កមកឲ្យសន្តតិជនដែលបានទាមទារវិញ។ ប៉ុន្តែបើសន្តតិជនដែលមានសិទ្ធិនោះមិនអនុវត្តសិទ្ធិរបស់ខ្លួនក្នុងរយៈពេលដែលច្បាប់កំណត់ទេ ជននោះនឹងត្រូវបាត់បង់សិទ្ធិដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិ។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម គឺរយៈពេល ០៥ ឆ្នាំ គិតចាប់ពីថ្ងៃដែលភាគីម្ខាងទៀតនៃការទាមទារនោះបានទទួលមត៌កតាមមតកសាសន៍ ឬក្រោយការបែងចែក មត៌កចំពោះករណីសហសន្តតិជន។ ចំពោះសន្តតិជនតែម្នាក់ មានរយៈពេល ០៥ ឆ្នាំ គិតពីថ្ងៃដែលមតកជនបានទទួលមរណភាព។

## ៣.៣. ការបែងចែកមត៌ក

ក្រោយពីបានសិក្សាទៅលើលក្ខណៈរបស់សន្តតិជន និងទ្រព្យសម្បត្តិហើយ ឥឡូវយើងនឹងធ្វើការសិក្សាទៅលើការបែងចែកមត៌កម្តង ដែលអាចមានជាការបែងចែកមត៌ក ចំណុច ៣.៣.១ រូបមន្តនៃការបែងចែកមត៌កចំណុច ៣.៣.២ និងក្នុងករណីការសម្រួលមត៌ក ចំណុច ៣.៣.៣ ។

### ៣.៣.១. ការបែងចែកមត៌ក

ការបែងចែកមត៌ក អាចធ្វើឡើងតាមរយៈការពិភាក្សា ឬប្រសិនបើការពិភាក្សាមិនអាចធ្វើទៅបាន គឺការបែងចែកអាចធ្វើឡើងតាមរយៈតុលាការ ដោយការបែងចែកមត៌កនាំអោយមានអានុភាពមួយជាក់លាក់ តាមការកំណត់របស់ច្បាប់ និងមានស្ថានភាពមួយចំនួនទៀតជាករណីពិសេស ដូចជា ការទទួលស្គាល់សន្តិជន ក្រោយការបែងចែកមត៌ក ជាអាទិ៍។

#### ៣.៣.១.១. ការពិភាក្សាបែងចែកមត៌ក

ដូចដែលបានលើកឡើងខាងលើ នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីវិធានស្តីពីចំណែកមត៌កដែលច្បាប់បានកំណត់។ ប៉ុន្តែ ជាក់ស្តែង ទ្រព្យសម្បត្តិមិនត្រូវបានបែងចែកដោយស្វ័យប្រវត្តិឲ្យស្របទៅតាមវិធាននៅក្នុងក្រមរដ្ឋប្បវេណីបែបនេះទេ គឺទ្រព្យសម្បត្តិត្រូវបានបែងចែកទៅតាមការពិភាក្សារវាងសហសន្តតិជន។ នៅពេលមតកជនទទួលមរណភាព សហសន្តតិជនជួបជុំគ្នា ហើយពិភាក្សាគ្នាដើម្បីបែងចែកមត៌ក។ ការពិភាក្សាបែបនេះ ហៅថា ការពិភាក្សាបែងចែកមត៌ក។[128] អ្នកដែលអាចចូលរួមការពិភាក្សាបែងចែកមត៌កបាន គឺមានតែសន្តតិជនប៉ុណ្ណោះ។

ជាគោលការណ៍ការបែងចែកមត៌កត្រូវធ្វើឡើងតាមការពិភាក្សាគ្នានៃសហសន្តិជន ដោយសហសន្តិជនអាចពិភាក្សាគ្នាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ០១ ( មួយ) ខែ បានកន្លងផុតទៅ ក្រោយពី

[128] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៦

ការចាប់ផ្តើមសន្តិកម្ម[129] ប៉ុន្តែការផ្លាស់ប្តូរម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផល នៃការបែងចែកមិនអាចធ្វើបានឡើយ បើអំឡុងពេលដែលច្បាប់កំណត់មិនទាន់កន្លងហួស ( អំឡុងពេល ០៣ ខែ នៃការបង្ហាញឆន្ទៈបោះបង់ ឬទទួលយកសន្តិកម្ម) លើកលែងតែមានភាពចាំបាច់ដើម្បីសងកាតព្វកិច្ចមតកជន ឬមតកជនអាចបង្ហាញឆន្ទៈ នៅក្នុងមតកសាសន៍អំពីអំឡុងពេលនៃការបែងចែក ជាអាទិ៍។[130] ការពិភាក្សាបែងចែកមត៌ក មិនមែនមានន័យថាត្រូវតែធ្វើការបែងចែកមត៌កដោយភាគខុសគ្នាជាមួយនិងចំណែកមត៌កដែលច្បាប់បានកំណត់បានផងដែរ។

ក្នុងករណី សហសន្តតិជនមិនអាចព្រមព្រៀងគ្នាក្នុងការពិភាក្សាបែងចែកមត៌កបាន ពួកគេអាចដាក់ពាក្យស្នើសុំទៅតុលាការឲ្យធ្វើការបែងចែកមត៌កតាមមាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណី។ ក្នុងករណីនេះជាមូលដ្ឋាន តុលាការត្រូវបែងចែកមត៌កឲ្យស្របទៅតាមចំណែកមត៌កដែលច្បាប់បានកំណត់ ដែលចំណុចនេះយើងនឹងធ្វើការសិក្សាឲ្យលម្អិតនៅចំណុចបន្ទាប់។

### ៣.៣.១.២. ការបែងចែកដោយតុលាការ

ជាគោលការណ៍តុលាការធ្វើការបែងចែកមត៌ក ជំនួសអោយសន្តតិជន នៅក្នុងករណីដែលការពិភាក្សារបស់សហសន្តតិជននៅក្នុងការបែងចែកមត៌កពុំបានសម្រេច ឬសហសន្តតិជនពុំអាចពិភាក្សាបាន តាមរយៈការដាក់ពាក្យសុំនៅតុលាការអោយធ្វើការបែងចែកមត៌ក ដោយតុលាការធ្វើការបែងចែក ដោយពិចារណាលើលក្ខខ័ណ្ឌមួយចំនួន ដូចជា មូលដ្ឋាននៃការបែងចែក ( ប្រភេទ និងលក្ខណៈនៃវត្ថុ សិទ្ធិដែលមានក្នុងមត៌ក....ជាអាទិ៍ ) សំណាងនៃកាតព្វកិច្ចរបស់មតកជន ទម្លាក់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន។ បន្ទាប់ពីមូលដ្ឋានក្នុងការបែងចែកដោយតុលាការ ចំពោះទ្រព្យដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬអំពើរបស់បុគ្គលដែលទទួលសន្តតិកម្មនៃសហសន្តតិជននោះ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលទទួលបានពីការលក់នោះដែលជារបៀបនៃការលក់មត៌កនិងការបែងចែកប្រាក់ដែលទទួលបានក្រោយការលក់។ លើសពីនេះទៅទៀត ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដែលជាសិទ្ធិស្ថិតនៅក្នុងមត៌កនោះ ( រាប់បញ្ចូលទាំងផលធម្មជាតិ និងផលស៊ីវិលដែលកើតឡើងពីមត៌ក ) ត្រូវក្លាយជាកម្មវត្ថុនៃមត៌ក ហេតុនេះ ក៏ក្លាយជាកម្មវត្ថុនៃការបែងចែកមត៌ក ផងដែរ។[131]

[129] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦២
[130] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៦៦
[131] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៧០

#### ៣.៣.១.៣. អានុភាពនៃការបែងចែក

ការបែងចែកមត៌កមានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម ប៉ុន្តែមិនអាចបំពានសិទ្ធិ របស់តតិយជនដែលបានចុះបញ្ជី ឬមានលក្ខខ័ណ្ឌតតាំងនោះឡើយ ហើយសហសន្តតិជននីមួយៗត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងនឹងទ្រព្យដែលខ្លួនបានធ្វើលទ្ធកម្ម។[132]

**ករណីពិសេស៖** ក្នុងករណីដែលជនបានក្លាយជាសន្តតិជន ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារការបែងចែកមត៌ក ប៉ុន្តែសហសន្តតិជនដទៃទៀតបានបែងចែកមត៌ក ឬចាត់ចែងមត៌ក ជននោះមានសិទ្ធិទាមទារអោយសងតម្លៃ ប៉ុណ្ណោះ។ លក្ខខ័ណ្ឌតតាំងជាអាទិ៍ នៃការបែងចែកសិទ្ធិ លើបំណុល គឺជាស្ថានភាពនៃការបែងចែកមត៌ក ដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ដែលកំណត់ដោយច្បាប់ ហើយសហសន្តតិជនទាំងអស់ ត្រូវមានកាតព្វកិច្ចជូនដំណឹងអំពីការបែងចែកនេះ ឬការបែងចែកធ្វើឡើងដោយលិខិតយថាភូត ត្រូវបង្ហាញលិខិតនោះទៅកូនបំណុល ដើម្បីទទួលបានលក្ខខ័ណ្ឌតតាំង ហើយកូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកដែលបានកំណត់ដោយច្បាប់ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង អាចតតាំងចំពោះសហសន្តតិជន ដែលបានធ្វើលទ្ធកម្មលើបំណុលនោះបាន។ ម្យ៉ាងវិញទៀត សហសន្តតិជនម្នាក់ៗ ត្រូវទទួលខុសត្រូវទៅតាមសមាមាត្រនៃចំណែកមត៌ក ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត។

### ៣.៣.២. រូបមន្តនៃការបែងចែកមត៌ក

យោងតាមមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញាតិអំពីរូបមន្តនៃការបែងចែកមត៌កដូចតទៅ៖

មត៌កសរុប = តម្លៃមត៌កនៅពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស - វិភាគទាន

- តម្លៃផលប្រយោជន៍ពិសេស
  - ផលប្រយោជន៍ពិសេសកើនឡើង នាំឲ្យ យកតម្លៃថ្ងៃធ្វើប្រទានកម្ម
  - ផលប្រយោជន៍ពិសេសធ្លាក់ចុះ នាំឲ្យយកតម្លៃថ្ងៃបើកសន្តតិកម្ម
- ចំណែកសន្តតិជននីមួយៗ = មត៌កសរុប ÷ ចំនួនសន្តតិជនដែលមាន
  - បើផលប្រយោជន៍ពិសេស ≥ ចំណែកសិទ្ធិ នាំឲ្យ សន្តតិជន = 0
  - បើផលប្រយោជន៍ពិសេស < ចំណែកសិទ្ធិ នាំឲ្យ ចំណែករបស់សន្តតិជនដែលនៅខ្វះ
- ចំណែកខ្វះសន្តតិជននីមួយៗ = មត៌កនៅពេលចាប់ផ្ដើមសន្តតិកម្ម × ចំណែកសិទ្ធិខ្វះ ÷ ចំណែកសិទ្ធិខ្វះសរុបរបស់សន្តតិជនដែលខ្វះ

[132] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៧៣

### ៣.៣.២.១. សហព័ទ្ធ និងបច្ឆាញាតិផ្ទាល់

បច្ឆាញាតិផ្ទាល់ សំដៅទៅលើកូនរបស់មតកជន ទោះបីជាកូននោះមានខាន់ស្លា ឬឥតខាន់ស្លាក់ដោយ ឬជាកូនបង្កើត កូនចិញ្ចឹមក្តីសុទ្ធតែអាចទទួលមត៌ក។ ចំពោះមត៌ករវាងសហព័ទ្ធ និងកូននីមួយៗនោះគឺ នឹងត្រូវទទួលបាននូវចំណែកស្មើៗគ្នា។[133]

ឧទាហរណ៍១៖ ក្នុងករណី មតកជន A និងសហព័ទ្ធមានកូន បី នាក់។ ពេលដែល A ស្លាប់បានបន្សល់ទុកនូវមត៌ក ៤.០០០ ដុល្លារ។ ដូច្នេះ បើយោងតាមមាត្រា ១.១៥៦ នាំឲ្យ មត៌កត្រូវបានបែងចែកជា មួយ ភាគ បួន (១/៤) ដូចនេះ សហព័ទ្ធទទួលបាន ១.០០០ ដុល្លារ រីឯ X Y និង Z ទទួលបានម្នាក់ ១.០០០ ដុល្លារ។

តារាងញាតិរបស់មតកជន A




### ៣.៣.២.២. សហព័ទ្ធ និងបុព្វញាតិផ្ទាល់

ប្រសិនបើមតកជនគ្មានបច្ឆាញាតិផ្ទាល់នោះមត៌កនឹងត្រូវធ្លាក់ទៅលើឪពុកម្តាយ របស់មតកជននោះ។ បុព្វញាតិផ្ទាល់មានដូចជា ឪពុកម្តាយ ជីដូន ជីតាជាដើម។ បុព្វញាតិផ្ទាល់អាចក្លាយជាសន្តតិជនបាន ក្នុងករណីដែល មតកជនពុំមានបច្ឆាញាតិផ្ទាល់ដូចជា កូន ឬ ចៅជាដើមតែប៉ុណ្ណោះ។[134] ប្រសិនបើ បុព្វញាតិផ្ទាល់មានច្រើននាក់ ត្រូវផ្តល់អាទិភាពចំពោះបុព្វញាតិផ្ទាល់ដែលជិតជិតជាមួយមតកជនជាមុន។

ចំពោះមត៌ករវាងសហព័ទ្ធ និងឪពុកម្តាយរបស់មតកជនចំណែកមត៌ករបស់សហព័ទ្ធ ត្រូវបាននូវចំណែក ១ ភាគ ៣ ចំណែកឯរបស់ឪពុកម្តាយត្រូវបាន ២ ភាគ ៣។

ប៉ុន្តែប្រសិនបើក្នុងករណី ឪពុក ឬម្តាយ របស់មតកជនមានតែម្នាក់នៅរស់ ឪពុក ឬម្តាយនោះ និងសហព័ទ្ធត្រូវទទួលបាននូវចំណែកស្មើៗគ្នា។[135]

ឧទាហរណ៍២៖ ក្នុងករណីនេះមតកជន A មានសហព័ទ្ធ B ហើយអ្នកទាំងពីរពុំមានកូននោះទេ។ ប៉ុន្តែ A មានឪពុក X និងម្តាយ Y នៅពេលដែល A ទទួលមរណភាពបានបន្សល់នូវប្រាក់ ៦.០០០ ដុល្លារ។ ដូចន្នេះ

[133] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦២-ក

[134] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៩

[135] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦២-ខ

យោងតាមមាត្រា ១១៦២ នាំឲ្យមត៌កត្រូវបានបែងចែកជា ១ ភាគ ៣ ដូចនេះ សហព័ទ្ធ ទទួលបាន ២.០០០ ដុល្លារ រីឯ ឪពុក ទទួលបាន ២.០០០ ដុល្លារ និងម្តាយ ទទួលបាន ២.០០០ ដុល្លារ។

តារាងញាតិរបស់ មតកជន A

ឪពុក X ម្តាយ Y

មតកជន A សហព័ទ្ធ

### ៣.៣.២.៣. សហព័ទ្ធ និងបងប្អូនបង្កើត ឬសន្តតិជនជំនួស

បងប្អូនបង្កើតរបស់មតកជន ត្រូវក្លាយជាសន្តតិជនរបស់មតកជន ក្នុងករណីដែលមតកជននោះពុំមានទាំងបច្ឆាញាតិផ្ទាល់ និងទាំងបុព្វញាតិផ្ទាល់តែប៉ុណ្ណោះ។[136] ចំណែកមត៌ករបស់បងប្អូនបង្កើត គឺត្រូវបែងចែកស្មើៗគ្នា។

ប្រសិនបើសហព័ទ្ធ និងបុព្វញាតិក្រៅពីឪពុកម្តាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលនូវសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវបាន ១ភាគ២ រីឯចំណែកមត៌ករបស់បុព្វញាតិក្រៅពីឪពុកម្តាយ មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសនោះត្រូវបាន ១ ភាគ ២។[137]

**ឧទាហរណ៍ទី១៖** ក្នុងករណីមតកជន **ក** គ្មានកូនទេ ហើយឪពុកម្តាយឈ្មោះ **ច** និង **ឆ** បានទទួលមរណភាពហើយ។ ឪពុកម្តាយនេះមានកូនឈ្មោះ **ខ** និង **គ** ពីរនាក់ទៀតក្រៅពី **ក**។ លើសពីនេះទៀត **ច** មានកូនមួយផ្សេងទៀតឈ្មោះ **ង** មុននឹងរៀបការជាមួយ **ឆ**។ ដូច្នេះសន្តតិជនរបស់ **ក** គឺ **ខ គ** និង **ង** គឺស្មើនឹងពាក់កណ្តាលនៃចំណែករបស់ **ខ** និង **គ** ហេតុនេះហើយ **ខ** និង **គ** បានទទួលមត៌កម្នាក់ ២ភាគ៥ រីឯ **ង** វិញបានទទួល ១ ភាគ ៥។ ប្រសិនបើ **ង** ជាកូនស្មុំធម្មតារបស់ **ច** វិញ (ស្មុំកូនដែលជាកូនរបស់សហព័ទ្ធ) នោះ **ឆ** ក្លាយជា ម្តាយរបស់ **ង** តាមផ្លូវច្បាប់ដែរ។ ដូច្នេះ **ង** មានឪពុកម្តាយរួមជាមួយ **ខ** និង **គ** ហេតុនេះហើយ នាំឲ្យ **ខ គ** និង **ង** ត្រូវទទួលនូវចំណែកមត៌កស្មើៗគ្នា។

### ៣.៣.៣. ការសម្រួលចំណែកមត៌ក

ការសម្រួលមត៌កជាការចាំបាច់នៃការពិភាក្សា ព្រោះថាជាគោលការណ៍ សន្តតិជនត្រូវទទួលបាននូវចំណែកស្មើៗគ្នា ប៉ុន្តែប្រសិនបើមានសន្តតិជនណាក្នុងចំណោមសន្តតិជនទាំងអស់បានទទួលផលប្រយោជន៍មុនពេល

[136] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦០

[137] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦២-គ

ចាប់ផ្ដើមសន្តតិកម្ម វាធ្វើឲ្យខូចប្រយោជន៍ដល់សន្តតិជនដែលពុំទាន់បានទទួលផលប្រយោជន៍ពិសេសផ្សេងៗ ដើម្បីការពារប្រយោជន៍ដល់សន្តតិជនដែលពុំទាន់បានទទួលផលប្រយោជន៍នោះ នាំឲ្យមានច្បាប់បញ្ញត្តិស្ដីពីការសម្រួលចំណែកមត៌ក ហេតុនេះដើម្បីឲ្យមានសភាពត្រឹមត្រូវរវាងសហសន្តតិជន។ ផលប្រយោជន៍ពិសេស គឺជាផលប្រយោជន៍ដែលបុគ្គលណាបានទទួលជាប្រទានកម្ម នៅពេលរៀបអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងៗទៀត ពីមតកជនពេលនៅរស់រានមានជីវិត។ លើសពីនេះទៅទៀត អច្ច័យទានដែលសន្តតិជនទទួលបានក៏ចាត់ទុកជាផលប្រយោជន៍ពិសេសផងដែរ ប៉ុន្តែអច្ច័យទានពុំត្រូវបានរាប់បញ្ចូលដើម្បីគណនាទេ ព្រោះថាអច្ច័យទានពុំទាន់ត្រូវបានបែងចែកឲ្យទៅសន្តតិជនឡើយនៅពេលចាប់ផ្ដើមសន្តតិកម្ម ម៉្យាងវិញទៀតប្រទានកម្មដែលជាផលប្រយោជន៍ពិសេសរបស់តតិយជន អាចជាកម្មវត្ថុនៃការគណនាភាគបម្រុងបានកាលដែលប្រទានកម្មនោះធ្វើឡើងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ មុនពេលចាប់ផ្ដើមសន្តតិកម្ម ឬក៏ប្រទានកម្មដែលធ្វើឡើងដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្ដាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ហើយការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរត្រូវចាត់ទុកថាជាប្រទានកម្មផងដែរ។[138]

វិធីសម្រួលចំណែកមត៌ក វាជាការចាំបាច់ត្រូវដឹងថាផលប្រយោជន៍ពិសេសជាអ្វី? ព្រោះថាក្នុងគោលបំណងនៃការសម្រួលនូវចំណែកមត៌កគឺសម្រាប់អ្នកទទួលបានផលប្រយោជន៍ពិសេសក្នុងចំណោមសន្តតិជនទាំងអស់។ ប្រសិនបើ សន្តតិជនណាម្នាក់ ឬច្រើននាក់ ពេលដែលសន្តតិជនណាម្នាក់រៀបអាពាហ៍ពិពាហ៍ មតកជនពេលនៅរស់បានចងដៃសន្តតិជននោះជាប្រាក់ ឬជាវត្ថុមានតម្លៃផ្សេងៗទៀត ទ្រព្យនេះជាកម្មវត្ថុនៃការសម្រួលចំណែកមត៌ក ឬអាចហៅថាជាផលប្រយោជន៍ពិសេស។ តម្លៃសរុបនៃមត៌ក គឺត្រូវយកទ្រព្យរបស់មត៌កជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម បូកបញ្ចូលតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកជាមត៌ក បន្ថែមពីចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទានចេញពីចំណែកមត៌ក គឺជាចំណែកមតករបស់បុគ្គលនោះ។[139] មត៌កសរុបស្មើនឹង ការបូករវាងមត៌ក និងប្រទានកម្ម ឬអច្ច័យទាន។

### ៣.៣.៣.១. ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

ក្នុងករណីដែលមានសន្តតិជនតែម្នាក់ បានទទួលប្រទានកម្មពីមតកជនហើយក្រោយមកមតកជនបានទទួលមរណភាព ការបែងចែកទ្រព្យសម្បត្តិដែលនៅសល់ទៅឲ្យចំណោមសន្តតិជនដោយស្មើគ្នានោះ នឹងធ្វើឲ្យសន្តតិជនតែម្នាក់នោះទទួលបានទ្រព្យសម្បត្តិច្រើនជាងគេ ហើយធ្វើឲ្យមានភាពអយុត្តិធម៌។ ដូច្នេះ នៅក្នុងករណីនេះ ប្រព័ន្ធដែលអាចធ្វើឲ្យមានភាពស្មើគ្នារវាងសន្តតិជន គឺប្រព័ន្ធនៃការទទួលផលប្រយោជន៍ពិសេស។ ត្រូវចាត់ទុកជាអច្ច័យទាន គឺជាផលប្រយោជន៍ពីសេសរៀងរាល់ពេល។ ផលប្រយោជន៍ពិសេស គឺជាប្រទានកម្ម

---

[138] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៣២

[139] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៣

ពិសេស ដែលមតកជនបានផ្តល់នូវទ្រព្យណាមួយទៅឲ្យសន្តតិជន។ មិនមែនឲ្យអ្វីបន្តិចបន្តួច សម្រាប់ចាយវាយប្រចាំថ្ងៃ ជាផលប្រយោជន៍ពិសេសនោះទេ។ បើការឲ្យនោះលើសពីទំហំធម្មតា នោះជាផលប្រយោជន៍ពិសេស។[140]

ប្រសិនបើសន្តតិជនតាមច្បាប់ច្រើននាក់ ហើយមានសន្តតិជនខ្លះក្នុងចំណោមសហសន្តតិជនទាំងអស់នោះ បានទទួលពីមតកជននូវប្រទានកម្មពិសេសនៅពេលដែលមតកជននៅរស់ ឬបានទទួលអច្ច័យទានតាមបណ្តាំមតកសាសន៍ ក្នុងករណីខ្លះ ការគណនាចំណែកមត៌កត្រូវចាត់ទុកប្រទានកម្មនិងអច្ច័យទានទាំងនេះថាជាចំណែកមត៌កដែលប្រគល់ឲ្យមុន។ ច្បាប់កំណត់ថា របស់ទាំងអស់នេះត្រូវបានរៀបបញ្ចូលជាមត៌ក ហើយត្រូវបានគណនាទៅក្នុងចំណែកមត៌កភាគ (ចំពោះភាគណាដែលបានទទួលផលប្រយោជន៍រួចស្រេចហើយនោះ គឺត្រូវដកចេញពីចំណែកមត៌កដែលត្រូវទទួលបាន)។ នេះជាប្រព័ន្ធនៃការប្រមូលមកវិញនូវផលប្រយោជន៍ពិសេសដែលបុគ្គលទទួលបាន។[141] ការទទួលផលប្រយោជន៍ពិសេស គឺមានដូចជាការទទួលនូវការឧបត្ថម្ភសម្រាប់ថ្លៃសាលា ខ្ពស់ជាងការទទួលបានរបស់សន្តតិជនផ្សេងទៀត ឬប្រទានកម្មជាអចលនវត្ថុសម្រាប់ថ្ងៃអាពាហ៍ពិពាហ៍ជាដើម។

ក្នុងករណីដែលមានការទទួលផលប្រយោជន៍ពិសេស វិធីគណនាចំណែកមត៌កមានដូចតទៅ៖

ដំបូង ត្រូវបូកទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេស ចំពោះមត៌ករបស់មតកជន។ នេះហៅថា ទ្រព្យដែលត្រូវចាត់ទុកជាមត៌ក។ ហើយ ត្រូវគណនាទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក ឲ្យស្របតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ រួចគណនាចំណែកសន្តតិកម្មរបស់សន្តតិជននីមួយៗ ។ នេះហៅថា ចំណែកដែលត្រូវចាត់ទុកថាជាមត៌ក។ បន្ទាប់មក ត្រូវដកទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេស ពីចំណែកត្រូវចាត់ទុកថាជាមត៌ករបស់សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស។[142]

**ឧទាហរណ៍ទី១៖** មតកជនបានបន្សល់ទុកមត៌កចំនួន ៤.០០០ ដុល្លារ ហើយមតកជនមានកូនចំនួនបួន នាក់ គឺ A, B, C, D ប៉ុន្តែ A បានទទួលប្រាក់ពីមតកជន ១.០០០ ដុល្លារ ពីមតកជនពេលនៅរស់ និង B បានទទួលប្រាក់ពីមតកជន ៥០០ ដុល្លារ ពីមតកជនពេលនៅរស់។ នោះមត៌កសរុបគឺ ចំនួន ៤.០០០ $ និងតម្លៃប្រទានកម្ម ១.៥០០ $ នោះមត៌កសរុបគឺ ៤.០០០ + ១.៥០០ = ៥.៥០០ $ ។ នាំឲ្យចែកចំណែកមត៌កស្មើៗគ្នារបស់ A, B, C, D គឺ ៥.៥០០ ដុល្លារចែកឲ្យ ៤ (បួន)គឺ ១.៣៧៥ ដុល្លារ តែ A ទទួលបានប្រទានកម្មចំនួន ១.០០០ ដុល្លារ រួចហើយដូច្នេះ A អាចទទួលបានតែ ៣៧៥ ដុល្លារថែមទៀតប៉ុណ្ណោះ ចំណែកឯ B ទទួលបានប្រទានកម្ម

---

[140] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៣

[141] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៩០៣

[142] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៣

ចំនួន ៥០០ ដុល្លារ រួចហើយដូច្នេះ B បានតែ ៨៧៥ ដុល្លារ ទៀតប៉ុណ្ណោះ រីឯ C, D មិនធ្លាប់បានទទួលប្រទានកម្មទេ ដូច្នេះ C, D ទទួលបាន ១.៣៧៥ ដុល្លារ។

ប្រសិនបើតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ស្មើនឹងតម្លៃនៃចំណែកមត៌ក ឬលើសនឹងចំណែកមត៌កសហសន្តតិជននោះមិនអាចទទួលបានចំណែកមត៌កនោះបានឡើយ។[143] ទោះបីជាតម្លៃនៃប្រទានកម្ម ឬអច្ច័យទានដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសងសហសន្តតិជនផ្សេងទៀតឡើយលើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។[144] ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណីចាស់បានយកគោលការណ៍ខុសពីការបែងចែកខាងលើដោយចែងថា ប្រសិនបើចំណែកមត៌កតិចជាងតម្លៃទ្រព្យដែលត្រូវបង្វិលទៅវិញ ត្រូវសងវិញនូវចំនួនដែលខ្វះ។[145] គេផ្តល់អាទិភាពដល់ឆន្ទៈរបស់មតកជនកាលពេលនៅរស់ ឬឆន្ទៈរបស់សហសន្តតិជន ក្នុងការសងទៅវិញនូវចំណែកលើស ទៅឲ្យរបបកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

ក្នុងករណីខាងលើនេះ មិនចាំបាច់ឲ្យបង្វិលនូវភាគលើសវិញនោះទេ តម្លៃនៃចំណែកមត៌កជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀតនៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវគណនាដោយបែងចែកមត៌ក ដែលមតកជនមានពេលចាប់ផ្តើមសន្តតិកម្ម នោះតាមសមាមាត្រនៃចំណែកមត៌ក របស់សន្តតិជនម្នាក់ៗ។[146]

ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសដែលសហសន្តតិជនបានទទួល លើសចំណែកមត៌កក៏ដោយ ក៏មិនចាំបាច់បង្វិលទ្រព្យទាក់ទងនឹងប្រទានកម្មនោះវិញដែរ ព្រមទាំងចែងច្បាស់លាស់នូវចំណែកមត៌កជាក់ស្តែងរបស់សហសន្តតិជនផ្សេងៗទៀត ក្នុងករណីនេះផងដែរ។ ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសដែលសហសន្តតិជនបានទទួលលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ ក៏មិនចាំបាច់បង្វិលទ្រព្យដែលទាក់ទងនឹងប្រទានកម្មនោះវិញដែរ។

**ឧទាហរណ៍ទី២៖** មតកជន A មានសន្តតិជន B C D មុនពេលស្លាប់បានឲ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ដែលមានតម្លៃ ៧.០០០ ដុល្លារ និងឲ្យលុយនៅធនាគារទៅ D ដែលមានចំនួន ៩.០០០ ដុល្លារ ។ មត៌កដែលបន្សល់ទុកគឺ ៨.០០០ ដុល្លារ។

ផ្អែកតាមអង្គហេតុនេះ៖

**មត៌កសរុប = មត៌កពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស**

---

143 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៣,២

144 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៥

145 ក្រមរដ្ឋប្បវេណី, ឆ្នាំ ១៩៦០,មាត្រា ៦០០

146 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៥

នាំឲ្យ មត៌កសរុប = ៨.០០០ + ៧.០០០ + ៩.០០០ = ២៤.០០០ ដុល្លារ

ចំណែកមត៌ករបស់សន្តតិជននីមួយៗ = មត៌កសរុប ÷ ចំនួនសន្តតិជនដែលមាន

B = C = D = ២៤.០០០ ÷ ៣ = ៨.០០០ ដុល្លារ

ប៉ុន្តែ D មិនចាំបាច់បង្វិលសងវិញនោះទេ។ មត៌កជាក់ស្តែងមាន ៨.០០០ និង C ចំនួន ១.០០០ នោះទេ នាំឲ្យវិធានសមាមាត្រត្រូវយកមកអនុវត្តដែលមានខ្លឹមសារថា៖

ប្រៀបធៀបផលប្រយោជន៍ពិសេស និងចំណែកសិទ្ធិ

C = ៧.០០០ < ៨.០០០ នាំឲ្យ ខ្វះ ១.០០០ ដុល្លារ

D = ៩.០០០ ≥ ៨.០០០ នាំឲ្យ ខ្វះ 0

B = 0 < ៨.០០០ នាំឲ្យ ខ្វះ ៨.០០០ ដុល្លារ

ចំណែកខ្វះសន្តតិជននីមួយៗ = មត៌កពេលចាប់ផ្តើមសន្តតិកម្ម × ចំណែកសិទ្ធិខ្វះ ÷ ចំណែកសិទ្ធិខ្វះសរុប

C = ៨.០០០×១.០០០ ÷ ៩.០០០ = ៨៨៨,៨៩

B = ៨.០០០×៨.០០០ ÷ ៩.០០០ = ៧.១១១,១១

**ដូចនេះ** B ទទួលបាន ៧.១១១,១១ ដុល្លារ

C ទទួលបាន ៨៨៨,៨៩ ដុល្លារ

D ទទួលបាន 0 ដុល្លារ

#### ៣.៣.៣.២. វិភាគទាន

ភាគនៃវិភាគទាន គឺជាករណីដែលផ្ទុយពីការទទួលផលប្រយោជន៍ពិសេស។ មានន័យថា ជាប្រព័ន្ធដែលធ្វើការពិចារណាដើម្បីឲ្យមានភាពស្មើគ្នាចំណោមសន្តតិជនករណីមានបុគ្គលដែលជាក់លាក់ណាម្នាក់ក្នុងចំណោមសន្តតិជនច្រើននាក់ បានសហការធ្វើឲ្យមានការកើនឡើងនូវទ្រព្យសម្បត្តិរបស់មតកជន។

ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាម្នាក់បានធ្វើវិភាគទាន ពិសេសដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ឬបានថែរក្សាមតកជន និងបានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន នោះតម្រូវឲ្យមានការគណនាឲ្យបានសមរម្យលើចំណែកមត៌កដោយឆ្លុះបញ្ចាំងពីវិភាគទានដែលបុគ្គលនោះបានធ្វើ។ ដូច្នេះក្នុងករណីដែលមានវិភាគទានដូចបានរៀបរាប់ខាងលើនេះ ច្បាប់ទទួលស្គាល់ចំនួនទឹកប្រាក់សរុបនៃចំណែកមត៌ក ដែលមានបូកបញ្ចូលនូវភាគនៃវិភាគទានតែប៉ុណ្ណោះហើយតម្លៃនៃវិភាគទាននេះតម្រូវឲ្យមានការវាយតម្លៃជាទឹកប្រាក់ដោយយោងលើសាលក្រមរបស់តុលាការគ្រួសារ ឬដោយផ្អែកលើការពិគ្រោះគ្នារវាងសហសន្តតិជន។

វិធីសាស្ត្រនៃការគណនាចំណែកមត៌ក ក្នុងករណីដែលមានភាគនៃវិភាគទានមានដូចតទៅៈ

ដំបូង ត្រូវដកចំនួនទឹកប្រាក់ភាគនៃវិភាគទាន ពីមត៌ករបស់មតកជន នេះហៅថាទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក ហើយត្រូវគណនាទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក ឲ្យស្របតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ រួចគណនាចំណែកសន្តតិកម្មរបស់សន្តតិជននីមួយៗ ។ នេះហៅថា ចំណែកដែលត្រូវចាត់ទុកជាមត៌ក ។ បន្ទាប់មកត្រូវបូកចំនួនទឹកប្រាក់ភាគនៃវិភាគទាន។

ក្នុងករណីដែលក្នុងចំណោមសហសន្តតិជនទាំងអស់ មានអ្នកធ្វើវិភាគទានពិសេស។ ក្នុងករណីនេះ តម្លៃនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្មដោយដកនឹងភាគនៃវិភាគទាន ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃចំណែកមត៌កដែលបានគណនាតាមបញ្ញត្តិដែលបានលើកឡើងខាងលើ បូកនឹងវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជនដែលបានធ្វើវិភាគទានពិសេសនោះ។

**ឧទាហរណ៍៖** មតកជន ក មានសន្តតិជន ៥ នាក់ A B C D E មត៌កពេលចាប់ផ្ដើមសន្តតិកម្ម ២៥.០០០ ដុល្លារ និងបំណុលចំនួន ៦.០០០ ដុល្លារ ។ A ទទួលបានផ្ទះពីមតកជនដែលមានតម្លៃ ២០.០០០ ដុល្លារ នៅឆ្នាំ ២០១៥ ផ្ទះមានតម្លៃ ១០.០០០ដុល្លារ ។ B បានទទួលឡានពីមតកជន ដែលមានតម្លៃ ៣.០០០០ ដុល្លារ នៅឆ្នាំ ២០១៥ ឡានមានតម្លៃ ៨០.០០០ ដុល្លារ។ A B C D E បានធ្វើវិភាគទាន ៥.០០០ ដុល្លារ។

ផ្អែកតាមអង្គហេតុនេះ៖

**មត៌កសរុប = មត៌កពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស - វិភាគទាន**

**តម្លៃផលប្រយោជន៍ពិសេស**

- ផលប្រយោជន៍ពិសេសកើនឡើង នាំឲ្យ យកតម្លៃថ្ងៃធ្វើប្រទានកម្ម
- ផលប្រយោជន៍ពិសេសធ្លាក់ចុះ នាំឲ្យយកតម្លៃថ្ងៃបើកសន្តតិកម្ម

ហេតុនេះនាំឲ្យ៖ A : ២០.០០០ ធ្លាក់ចុះ ១០.០០០ នាំឲ្យយកតម្លៃ ១០.០០០ ដុល្លារ

B: ៣០.០០០ កើនឡើង ៨០.០០០ នាំឲ្យយកតម្លៃ ៣០.០០០ ដុល្លារ

នាំឲ្យ មត៌កសរុប = ២៥.០០០ + ១០.០០០ + ៣០.០០០ – ៥.០០០ = ៦០.០០០ ដុល្លារ

**ចំណែកសិទ្ធិរបស់សន្តតិជននីមួយៗ = មត៌កសរុប ÷ ចំនួនសន្តតិជន**

ហេតុនេះនាំឲ្យ A = B = C = D = E = ៦០.០០០ ÷ ៥ =១២.០០០ ដុល្លារ

ប្រៀបធៀបផលប្រយោជន៍ពិសេស និងចំណែកសិទ្ធិ

A = ១០.០០០ < ១២.០០០ នាំឲ្យ = ១២.០០០ – ១០.០០០ = ២.០០០ + ១.០០០ = ៣.០០០ ដុល្លារ

B = ៣០.០០០ ≥ ១២.០០០ នាំឲ្យ 0 ដុល្លារ

C = D = E = ១២.000 + ១.000 = ១៣.000 ដុល្លារ

ចំណែកសិទ្ធិខ្វះសរុបរបស់សន្តតិជន = A = B = C = D = E = ៣.000 + ១៣000 + ១៣.000 + ១៣.000 = ៤២.000 ដុល្លារ

**ចំណែកខ្វះសន្តតិជននីមួយៗ = មត៌កពេលចាប់ផ្តើមសន្តតិកម្ម × ចំណែកសិទ្ធិខ្វះ ÷ ចំណែកសិទ្ធិខ្វះសរុប**

A = ២៥.000 × ៣.000 ÷ ៤២.000 = ១.៧៨៥,៧១ ដុល្លារ

C = D = E = ២៥.000 × ១៣.000 ÷ ៤២.000 = ៧.៧៣៨,០៩ ដុល្លារ

B = 0 ដុល្លារ

គណនាបំណុលដែលសន្តតិជនទទួលយក

A = B = C = D = E = បំណុលសរុប ÷ ៥ = ៦.000 ÷ ៥ = ១.២០០ ដុល្លារ

មួយវិញទៀត សហសន្តតិជនត្រូវកំណត់តម្លៃនៃភាគនៃវិភាគទានដោយការពិភាក្សា នៅពេលបែងចែកមត៌ក ក៏ប៉ុន្តែ ប្រសិនបើក្នុងករណីដែលការពិភាក្សានេះមិនចុះសម្រុងគ្នា ជាអាទិ៍ ត្រូវឲ្យតុលាការកំណត់។ ចំពោះករណីនេះភាគច្រើន ការបែងចែកមត៌កជាអាទិ៍ នេះក៏មិនសូវមានការចុះសម្រុងគ្នាទេ ដូច្នេះជាទូទៅពេលដាក់ពាក្យឲ្យសុំធ្វើការវិនិច្ឆ័យនូវការបែងចែកមត៌ក គេច្រើនតែសុំឲ្យតុលាការកំណត់តម្លៃនៃវិភាគទានព្រមគ្នាដែរ។ ក្នុងករណីដែលសហសន្តតិជនទាំងអស់អាចធ្វើការបែងចែកមត៌កបានដោយខ្លួនឯង បន្ទាប់ពីបានកំណត់តម្លៃនៃភាគនៃវិភាគទានរួចរាល់ នោះគេអាចដាក់ត្រឹមតែពាក្យសុំ ឲ្យតុលាការកំណត់បាន ប៉ុន្តែករណីបែបនេះកម្រមានណាស់។

ការកំណត់ចំនួន ឬតម្លៃនៃភាគនៃវិភាគទានគឺសន្តតិជនពិភាក្សាគ្នា ប៉ុន្តែបើការពិភាក្សាមិនទទួលបានលទ្ធផលជាវិជ្ជមានអាចស្នើសុំទៅតុលាការដើម្បីកំណត់ ហើយមានករណីដែលការបែងចែកមត៌កមិនចុះសម្រុងគ្នា តម្រូវឲ្យដាក់ពាក្យសុំបែងចែកមត៌ក និងទាមទារឲ្យតុលាការកំណត់តម្លៃនៃភាគនៃវិភាគទាន។ ក្នុងករណីភាគនៃវិភាគទាន ចំណែកមត៌កដែលមានកំណត់ក្នុងបណ្តាំមត៌កជាគោល យោងតាមមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាលើប្រធានបទស្តីពី «សន្តតិកម្ម» ទាំងមូលរួចមក យើងខ្ញុំសូមធ្វើការសន្និដ្ឋានដូចតទៅៈ

តាមច្បាប់គោរពនូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន បុគ្គលឯកជនទទួលបានបុគ្គលភាពនៅពេលចាប់កំណើត និងបាត់បង់ទៅវិញនៅពេលទទួលមរណភាព ប៉ុន្តែទោះបីជាបាត់បង់បុគ្គលភាពគតិយុត្តនៅពេលទទួលមរណភាពក៏ពិតមែន មានគោលការណ៍ទទួលបន្តមួយចំនួនដូចជាគោលការណ៍គោរពនូវឆន្ទៈរបស់អ្នកស្លាប់ ហេតុដូចនេះហើយបានជានៅគន្ថីទី៨ បានបញ្ញត្តិអំពីសន្តតិកម្ម ដែលគេអាចគោរពទៅតាមឆន្ទៈរបស់ម្ចាស់ទ្រព្យនៅពេលដែលគាត់នៅមានជីវិត ហេតុនេះហើយបានជាមានចែងអំពីសន្តតិកម្មតាមមតកសាសន៍។ ប៉ុន្តែអ្នកខ្លះទៀតមុនទទួលមរណភាពនឹងអាចនឹងគាត់មិនបានរៀបចំទុកជាមុនក្នុងការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលគាត់ទទួលមរណភាពទេ អាចជាការទទួលមរណភាពដោយចៃដន្យ ឬដោយហេតុផលណាមួយដែលគាត់មិនបានគិតគូរទុក ឬជាការស្លាប់ដោយយថាហេតុ ដែលបន្សល់ទ្រព្យហើយអត់បានផ្តាំថាត្រូវឲ្យមានការចាត់ចែងរបៀបណាទេ ទោះបីជាយ៉ាងនេះក្តីមានបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលចែងអំពីការបែងចែកមត៌កតាមច្បាប់។

នៅមុនពេលដែលម្ចាស់បណ្តាំទទួលមរណភាព ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បាននៅពេលណាក៏បានដែរ ប៉ុន្តែនៅពេលដែលធ្វើមតកសាសន៍ តម្រូវឲ្យម្ចាស់បណ្តាំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ត្រិះរិះពិចារណាឲ្យបានច្បាស់លាស់ ដើម្បីសរបញ្ជាក់ឲ្យបានច្បាស់លាស់ថា មតកសាសន៍បានស្តែងចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ ម្ចាស់បណ្តាំ មិនត្រឹមតែអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិទៅឲ្យសន្តតិជនតាមលិខិតមតកសាសន៍នេះប៉ុណ្ណោះទេ ប៉ុន្តែម្ចាស់បណ្តាំក៏អាចធ្វើអច្ច័យទានតាមរយៈលិខិតមតកសាសន៍នេះផង។ មតកសាសន៍ ត្រូវបានបង្កើតឡើងដោយម្ចាស់បណ្តាំដោយឯកតោភាគី ដោយមិនចាំបាច់មានការយល់ព្រមពីសន្តតិជនឡើយ ចំណែកទម្រង់ និងចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ត្រូវធ្វើឡើងតាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញតិយ៉ាងលម្អិតចំពោះសន្តតិកម្មតាមច្បាប់ ធ្វើឲ្យការអនុវត្តទាក់ទងនឹងផ្នែកនេះមានលក្ខណៈងាយស្រួល និងមានប្រសិទ្ធិភាព។

នៅក្នុងសង្គមជាក់ស្តែង ដោយសារកង្វះខាតការយល់ដឹងផ្នែកច្បាប់ ឬផ្នែកពាក់ព័ន្ធទៅនឹងសន្តតិកម្មនេះរបស់ប្រជាពលរដ្ឋមួយចំនួន បានជាធ្វើឲ្យប្រជាពលរដ្ឋមួយចំនួននោះមានទំនាស់ក្នុងការចែកមត៌ករបស់មតកជន ដែលជាហេតុបណ្តាលឲ្យកើតជារឿងទំនាស់គ្រួសារថែមទៀតផង ព្រោះថាសន្តតិជនម្នាក់ៗតែងចង់

ទទួលបានចំណែកមត៌ករបស់ខ្លួនកាន់តែច្រើនកាន់តែល្អ។ អាស្រ័យហេតុនេះ ទាំងសន្តតិកម្មតាមមតកសាសន៍ ទាំងសន្តតិកម្មតាមច្បាប់បានដើរតួនាទីយ៉ាងមានប្រសិទ្ធិភាពក្នុងការពារផលប្រយោជន៍របស់សន្តតិជន ក៏ដូចជាប្រទេសជាតិមានស្ថេរភាពផងដែរ។

ទោះជាយ៉ាងនេះក្តី ការតាក់តែងច្បាប់នីមួយៗមិនអាចបំពេញតម្រូវការ និងសមស្របតាមបរិបទនៃការអនុវត្តល្អឥតខ្ចោះនោះទេ ទោះបីជាការតាក់តែងនោះមានភាពល្អយ៉ាងណាក្តីនាពេលតាក់តែងនោះ ក៏មិនមានន័យថា ការអនុវត្តរបស់វាមានប្រសិទ្ធិភាពគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈនោះដែរ ព្រោះថាបរិបទសង្គមតែងតែមានការផ្លាស់ប្តូរ និងការអភិវឌ្ឍទៅមុខជានិច្ច ដែលជាហេតុធ្វើឲ្យការតាក់តែច្បាប់ក៏ត្រូវទាមទារឲ្យមានការវិវឌ្ឍន៍ឲ្យទាន់សង្គមផងដែរ។

សរុបជារួមមក សន្តតិកម្មតាមមតកសាសន៍ ពិតជាមានសារៈប្រយោជន៍ណាស់ ព្រោះវាមិនត្រឹមតែអាចកាត់បន្ថយជម្លោះក្នុងការបែងចែកមត៌ករវាងសន្តតិជននោះទេ ប៉ុន្តែវាថែមទាំងជាវិធីទូទាត់បំណុលមួយដ៏ល្អផងដែរ។ ការធ្វើសន្តតិកម្មតាមមតកសាសន៍ត្រូវគោរពតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទាំងទម្រង់ និងចំណុចដែលត្រូវសរសេរ ប៉ុន្តែតាមរយៈការស្រាវជ្រាវ យើងសង្កេតឃើញថា មានមាត្រាមិនទាន់មានភាពគ្រប់គ្រាន់ ដែលការចែងមកមានភាពស្រពេចស្រពិល ដូចន្នេះ យើងខ្ញុំសង្ឃឹមថា ចំណុចទាំងនោះនឹងត្រូវពិចារណាកែសម្រួលនាពេលអនាគតជាក់ជាមិនខាន។ រីឯសន្តតិកម្មតាមច្បាប់បានជួយធ្វើឲ្យការបែងចែក ក៏ដូចជាការគ្រប់គ្រងមត៌ករបស់មតកជនមានសមភាព និងយុត្តិធម៌ ដោយធ្វើឲ្យវិវាទទាក់ទងទៅនឹងសន្តតិកម្មមានការថយចុះ វាជាហេតុដើម្បីឲ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលផ្តោតសំខាន់ទៅលើការអភិវឌ្ឍប្រទេសជាតិយើងឲ្យកាន់តែមានភាពល្អប្រសើរ រីកចម្រើន និងភាពរុងរឿងបន្ថែមទៀតផង។ ជាការពិតណាស់ ចំណុចសំខាន់ពិតប្រាកដនោះគឺជាការចូលរួមចំណែករបស់ប្រជាពលរដ្ឋដដែល ដូច្នេះក្នុងកិត្តិយសយើងជាកុលបុត្រកុលធីតាខ្មែរទាំងអស់គ្នា គប្បីស្វែងយល់អំពីផ្នែកនេះទុកជាចំណេះដឹង និងផលប្រយោជន៍នាពេលអនាគត។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់តាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី សន្តតិកម្ម ដែលបង្ហាញខាងលើនេះរួចមក ដើម្បីរួមចំណែកឲ្យប្រព័ន្ធច្បាប់ និងវិស័យយុត្តិធម៌ កាន់តែប្រសើរឡើង យើងខ្ញុំសូមផ្តល់ជាសំណូមពរ និងបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនមួយចំនួនដែលយល់ថាគួរធ្វើការកែលម្អឲ្យកាន់តែប្រសើរឡើង ដើម្បីធ្វើឲ្យជាផលប្រយោជន៍ទាំងអស់គ្នា។

យើងខ្ញុំសូមឲ្យក្រសួង និងស្ថាប័នផ្សេងៗដែលទាក់ទងនឹងវិស័យច្បាប់ ជាពិសេសស្ថាប័ននីតិបញ្ញត្តិ ពិនិត្យ និងអនុម័តច្បាប់ ដើម្បីឲ្យទាន់ពេលវេលា និងការវិវឌ្ឍប្រែប្រួលរបស់សង្គម។ បន្ថែមពីលើនេះទៅទៀត យើងខ្ញុំសូមអំពាវនាវទៅដល់អាជ្ញាធរមានសមត្ថកិច្ច ក្រសួង គ្រប់ជាន់គ្រប់ថ្នាក់ រួមទាំងរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយនូវបទបញ្ញត្តិច្បាប់ផ្សេងៗជាពិសេសទាក់ទងទៅនឹងសន្តតិកម្ម ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹង និងជ្រួតជ្រាបក្នុងន័យចូលរួមកាត់បន្ថយ និងលុបបំបាត់ចោលនូវជម្លោះ ឬទំនាស់ផ្សេងៗ នៅក្នុងសង្គមគ្រួសារ រួមទាំងប្រទេសជាតិ ដោយហេតុថាសង្គមដែលមានការអភិវឌ្ឍទៅបានអាស្រ័យប្រជាជនមានចំណេះដឹងច្រើន និងការអនុវត្តរបស់ពួកគាត់។

ចំពោះប្តីប្រពន្ធ ឪពុកម្តាយ បងប្អូន និងក្រុមគ្រួសារ ដើម្បីកុំឲ្យមានទំនាស់កើតឡើង និងដើម្បីឲ្យគ្រួសារមួយមានសុភមង្គល គឺណាលុះត្រាតែភាគីទាំងអស់គ្នារស់នៅដោយភាពយោគយល់គ្នា សហការគ្នា សង្គ្រោះគ្នាទៅវិញទៅមក ចេះអត់ឱនឲ្យគ្នា ពិចារណាឲ្យបានត្រឹមត្រូវ បំពេញកាតព្វកិច្ចរបស់ខ្លួន ស្មោះត្រង់នឹងគ្នា។ មួយវិញទៀតដើម្បីកុំឲ្យមានការលំបាក ឬផលវិបាកនៅពេលក្រោយ ម្ចាស់ទ្រព្យ ឬមតកជន មុនពេលដែលស្លាប់បាត់បង់ជីវិត ចង់ឲ្យមានការបែងចែកទ្រព្យសម្បត្តិឲ្យទៅសន្តតិជន ឬបន្សល់ជាលិខិតបណ្តាំ ដែលតាមន័យច្បាប់ ហៅថា មតកសាសន៍។

បញ្ហាច្បាប់ពាក់ព័ន្ធជាមួយច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ចំពោះការប្រើពាក្យពេចន៍មិនទាន់មានភាពច្បាស់លាស់ និងមិនទាន់មានសុពលភាពគតិយុត្តនៅ ឡើយ។

ក្រសួងមហាផ្ទៃ និងអង្គការនីតិបញ្ញត្តិគួរតែរៀបចំឲ្យមានការបណ្តុះបណ្តាលទៅដល់មន្ត្រីអត្រានុកូលដ្ឋាន មន្ត្រីផ្សេងៗទៀត ក៏ដូចជាណែនាំឲ្យអនុវត្តនីតិវិធីនៃការបែងចែកមត៌ក ។ មិនត្រឹមតែប៉ុណ្ណោះ ក៏គួរតែមានការផ្សព្វផ្សាយច្បាប់ឲ្យបានទូលាយជាងនេះ និងឲ្យមានការចុះផ្សព្វផ្សាយ បណ្តុះបណ្តាលទៅដល់ប្រជាជនឲ្យយល់ដឹងឲ្យបានច្បាស់ ជាពិសេសជនស្រុកស្រែ ជនបទ ពោលគឺតំបន់ដាច់ស្រយាល។ មួយវិញទៀត យើងខ្ញុំសូមសំណូមពរឲ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ ពង្រឹង និងរិតបន្តឹងទៅលើការអនុវត្តច្បាប់ទាំងប្រជាជន និងអាជ្ញាធរ ដើម្បីលុបបំបាត់អំពើពុករលួយផ្សេងៗនៅក្នុងសង្គម។

ថ្វីត្បិតតែអនុសាសន៍ខាងលើនេះមានភាពមិនគ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ ក៏វាអាចជាកត្តាមួយជួយជម្រុញដល់ ការចូលរួមកាត់បន្ថយនូវវិវាទផ្សេងៗ ដែលទាក់ទងនឹងការបែងចែកមត៌ករបស់មតកជនឲ្យទៅសន្តតិជន រួមទាំងធ្វើឲ្យមានភាពសុខសាន្ត និងសុភមង្គល សុខដុមរមនានៅក្នុងសង្គមគ្រួសារ និងសង្គមជាតិផង ដែលជាហេតុធ្វើឲ្យប្រទេសមានការរីកចម្រើន និងអភិវឌ្ឍន៍។

# ឯកសារយោង

# ឯកសារយោង


## ១.បទដ្ឋានគតិយុត្ត

១.១. រដ្ឋធម្មនុញ្ញ. ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

១.១. ក្រសួងយុត្តិធម៌. ២០០៧ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា. ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ។

១.២. ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦: គន្ថីទី ៨ -ទី ៩,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១០)។

១.៣. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/0៥១១/00៧,៣១ ឧសភា ២០១១។

## ២.សៀវភៅ

២.១. **ជ័យ រិទ្ធី**,សាស្ត្រាចារ្យច្បាប់, លក្ខខណ្ឌទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់, (ភ្នំពេញ៖ ១៤ ឧសភា ២០១៤)។

២.២. **ស្រី វ៉ាន់ធី** សាស្ត្រាចារ្យច្បាប់, នីតិបេតិកភណ្ឌគ្រួសារ។

២.៣. **អ៊ុំ ប៉ូលី**, សន្តតិកម្ម, (ភ្នំពេញ៖ មីនា ២០២០) https://t.me/niteakosal/133។

## ៣.វចនានុក្រម៖

៣.១. វចនានុក្រម សម្តេចសង្ឃ **ជួន ណាត** ។

៣.២. ពុទ្ធសាសន៍បណ្ឌិត. ១៩៦៨. វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ។

៣.៣. ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់. ២០០៧.សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី ។

# ឧបសម្ព័ន្ធ

# គន្ថីទី ៨
# សន្តតិកម្ម

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ការចាប់ផ្ដើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.–** មូលហេតុនៃការចាប់ផ្ដើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្ដាំ ។

**មាត្រា ១១៤៦.–** ទីកន្លែងចាប់ផ្ដើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្ដើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

### ផ្នែកទី ២
### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.–** ការទទួលបន្តនូវមត៌ក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្ដាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

ដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

**មាត្រា ១១៤៨.–** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.–** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.-** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

**មាត្រា ១១៥១.-** ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១១៥២.-** ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

**មាត្រា ១១៥៣.-** ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតក-សាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១១៥៤.-** ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាង

លើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិ-ជន ។

**មាត្រា ១១៥៥.-** ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ជាតិជាខ្មែរទេ មត៌កត្រូវបែងចែក ដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះត្រូវក្លាយជាមត៌ក ហើយនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ជាតិជាខ្មែរ ។ ក្នុងករណីនេះ នីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

# ជំពូកទី ២
# សន្តតិកម្មតាមច្បាប់

## ផ្នែកទី ១
## សន្តតិជន

**មាត្រា ១១៥៦.–** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.–** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៨.–** ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមត៌ក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួន

នោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

**មាត្រា ១១៥៩.–** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.–** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្ដាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្ដាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

# ផ្នែកទី ២
# សន្តតិកម្មរបស់សហព័ទ្ធ

**មាត្រា ១១៦១.-** សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៦២.-** ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឳពុក ម្ដាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឳពុក ម្ដាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឳពុក ឬ ម្ដាយ របស់មតកជនតែម្នាក់នៅរស់ ឳពុក ម្ដាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឳពុក ម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឳពុក ម្ដាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

# ផ្នែកទី ៣
# ការសម្រួលចំណែកមត៌ក

**មាត្រា ១១៦៣.-** ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

**មាត្រា ១១៦៤.-** តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

**មាត្រា ១១៦៥.–** ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថា-ខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

**មាត្រា ១១៦៦.–** ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយ

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.–** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣

## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១

### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.–** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

បោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្ដាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្ដាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.–** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.-** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៦.–** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.–** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៨.–** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.-** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សី គ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.-** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.-** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ក របស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្តីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.-** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.-** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

**មាត្រា ១១៨៥.–** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.–** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.–** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

# ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.–** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.–** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតក-សាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.–** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.–** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថា បានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.–** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.-** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្ដាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.-** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.-** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.–** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.–** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.–** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមត៌ក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមត៌ក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ប្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្តាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយប្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្តាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.–** ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្តាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមតិក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមតិក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.–** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.–** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.-** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២១៤.-** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២១៥.-** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២១៦.-** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២១៧.-** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.-** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.-** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.-** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.-** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.-** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែនៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.–** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមត៌កដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.–** សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះ ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតកសាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមត៌ក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមត៌ក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

# ជំពូកទី ៤
# ភាគបម្រុង

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣០.-** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.-** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែល

ត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

**មាត្រា ១២៣២.–** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ :

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.–** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.–** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារ បានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

## ផ្នែកទី ២
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.–** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

**មាត្រា ១២៣៦.–** លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

**មាត្រា ១២៣៧.–** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់ តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

**មាត្រា ១២៣៨.–** លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

**មាត្រា ១២៣៩.–** ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ។

**មាត្រា ១២៤០.–** បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យ-

លាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

**មាត្រា ១២៤១.–** ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

**មាត្រា ១២៤២.–** ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទាន-កម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

**មាត្រា ១២៤៣.–** ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះ បានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

**មាត្រា ១២៤៤.–** សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសង បាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃ នៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួល ការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ ករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣ (ការកាត់ បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

## ផ្នែកទី ៣

## ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

**មាត្រា ១២៤៥.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ ផ្ដើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផល ប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយ អាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្ដើម សន្តតិកម្ម ។

**មាត្រា ១២៤៦.–** ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ ភាគបម្រុងនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុ- ញ្ញាតពីតុលាការ ។

**មាត្រា ១២៤៧.-** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង របស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

## ជំពូកទី ៥
## ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.-** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្ដើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្ដើម ។

**មាត្រា ១២៥០.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.–** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.-** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.-** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.-** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមត៌កនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតក-ជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.–** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន អាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមត៌ក តាមចំណែកមត៌កនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.–** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.–** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.–** អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្តោះអាសន្ន ដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្តឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្តឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្តោះអាសន្ន ។

**មាត្រា ១២៦៥.–** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.–** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.-** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.-** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.-** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្ដូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.-** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។

២-ក្នុងការបែងចែកមត៌ក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

**មាត្រា ១២៧១.–** ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

**មាត្រា ១២៧២.–** ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានយកកម្មវត្ថុមត៌ក ឬ តាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ ត្រូវស្ថិតនៅក្នុងមត៌ក ។

**មាត្រា ១២៧៣.–** អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

**មាត្រា ១២៧៤.–** ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក

បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

**មាត្រា ១២៧៥.–** ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិ-ជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កនោះបាន ។

**មាត្រា ១២៧៦.–** ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

## ផ្នែកទី ៣
## ការសម្រួលរវាងម្ចាស់បំណុល

**មាត្រា ១២៧៧.–** ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ

ចំពោះករណីដែលផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ច របស់មតកជន ។

**មាត្រា ១២៧៨.–** ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

**មាត្រា ១២៧៩.–** ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌កបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

## ផ្នែកទី ៤
## ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

**មាត្រា ១២៨០.–** ការគ្រប់គ្រងមត៌កនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១២៨១.–** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធាណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

**មាត្រា ១២៨២.-** សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

**មាត្រា ១២៨៣.-** ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ ។

**មាត្រា ១២៨៤.-** ការសងកាតព្វកិច្ចជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែក

ចំណែក) ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះ ដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

**មាត្រា ១២៨៥.–** ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

**មាត្រា ១២៨៦.–** ការប្តូរមត៌កជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មត៌កដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌កនោះ តាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១២៨៧.–** ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីណាផ្សេង

នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសង សំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាត របស់ម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលបាន ទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

**មាត្រា ១២៨៨.–** ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបាន កំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃ មាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែល អ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះ ទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោម មត៌ក ។

**មាត្រា ១២៨៩.–** ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និង សង កាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូច គ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ មានចំនួន ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នក

គ្រប់គ្រង ។

## ជំពូកទី ៧
## នត្ថិភាពនៃសន្តតិជន

**មាត្រា ១២៩០.-** នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល ។

**មាត្រា ១២៩១.-** ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមត៌ក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន ចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩២.-** សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមត៌ក ។ បើមានការចាំបាច់ដើម្បីថែរក្សា និង គ្រប់គ្រងមត៌កនោះ អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬ អាចចាត់ចែងមត៌កនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមត៌កទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា

១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

**មាត្រា ១២៩៣.-** កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្តល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមតិក ឱ្យទៅអ្នកគ្រប់គ្រងបាន ដោយគិតពិចារណាទៅលើស្ថានភាពនៃមតិក និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២៩៤.-** ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមតិកត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ នៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

**មាត្រា ១២៩៥.-** ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩៦.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យ-

លាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមត៌កជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នា បានឡើយ ។

**មាត្រា ១២៩៧.-** ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែ ឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

**មាត្រា ១២៩៨.-** ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិន

អាចដឹងបាន ពុំអាចអនុវត្តសិទ្ធិបានឡើយ ។

**មាត្រា ១២៩៩.–** ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យ នោះ មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

**មាត្រា ១៣០០.–** មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មត៌កដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

# ជំពូកទី ៨
## ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

**មាត្រា ១៣០១.–** គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគ បាន ។

**មាត្រា ១៣០២.–** អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

១-សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមត៌ក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួល តាមកិច្ចសន្យាដែលយកមត៌កធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

**មាត្រា ១៣០៣.–** ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និង ការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម ដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

**មាត្រា ១៣០៤.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌ក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។

# គន្ថីទី ៩

# អវសានប្បញ្ញត្តិ

## ជំពូកទោល

## អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.- កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរល.០៧១២.៦២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខៈ៥៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

453/453